# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ១~ព្រះរាជក្រម


០៣-១២-២០០៩ -ព្រះរាជក្រម នស/រកម/១២០៩/០២៤ ស្តីពី ស៊ុំកូនអន្តរប្រទេស ៩៣៨៥


### ២~ព្រះរាជក្រឹត្យ


៣១-១០-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១០០៩/១០៤៣ ស្តីពី ការតែងតាំង ទីប្រឹក្សា អមព្រះបរមរាជវាំង ចំនួន ០៤ រូប ៩៤១៩

២៣-១១-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១១០៩/១០៨៨ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់ លោក **លី ឈិនឡុង** (LEE CHENG LUNG) ជនជាតិចិន សញ្ជាតិនេប៉ាល់ កើតនៅសាធារណរដ្ឋប្រជាមានិតចិន ៩៤២០

០១-១២-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១២០៩/១១១៨ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់ អ្នកស្រី **ចូ ជីវ៉ុន** (CHO JIWON) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតនៅក្រុងសេអ៊ូលសាធារណរដ្ឋ កូរ៉េ ដោយប្តូរឈ្មោះជា **ចូ ម៉ារីយ៉ា** (CHO MARIA) ៩៤២១

០៥-១២-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១២០៩/១១៣៣ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ថ្នាក់ ឧត្តមសេនីយ៍ត្រី ជូន នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ចំនួន ១១ រូប ៩៤២២

០៥-១២-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១២០៩/១១៣៦ ស្តីពី ការតម្លើងថ្នាក់ជូនមន្ត្រីរាជការតាមកម្រិតសញ្ញាប័ត្រ ក្នុងឋានន្តរស័ក្តិ ឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៃក្រសួងផែនការ ចំនួន ០២ រូប និង ត្រូវបានតម្លើងថ្នាក់ ក្នុងឋានន្តរស័ក្តិ ឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល របស់ក្រសួងសុខាភិបាល ចំនួន ០១ រូប ៩៤២៣

០៨-១២-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១២០៩/១១៤៣ ស្តីពី ការប្រគល់ឋានន្តរស័ក្តិថ្នាក់ ឧត្តមសេនីយឯកជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ចំនួន ០២ រូប និងត្រូវបានតម្លើង ឋានន្តរស័ក្តិ ថ្នាក់ ឧត្តមសេនីយ៍ឯក ជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ចំនួន ០២ រូប ៩៤២៥

០៨-១២-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១២០៩/១១៤៤ ស្តីពី ការតម្លើងឋានន្តរស័ក្តិថ្នាក់ ឧត្តមសេនីយ៍ឯកជូនលោកឧត្តមសេនីយ៍ទោ **ឌិត សារ៉ាត់** នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ៩៤២៦

០៩-១២-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១២០៩/១១៤៥ ស្តីពី ការតែងតាំង ទីប្រឹក្សា អមព្រះរាជលេខាធិការដ្ឋានព្រះមហាក្សត្រ មានឋានៈស្មើ រដ្ឋលេខាធិការ ចំនួន ០១ រូប និង តែងតាំងឯកអគ្គរាជទូត អមព្រះរាជលេខាធិការដ្ឋានព្រះមហាក្សត្រ មានឋានៈស្មើ អនុរដ្ឋលេខាធិការ ចំនួន ០៨ រូប ៩៤២៧

## II-រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ


១១-១២-២០០៩ -អនុក្រឹត្យលេខ ២១៣ អនក្រ.បក ស្ដីពី ការផ្ទេរឥណទានថវិកា ៩៤២៨

១៤-១២-២០០៩ -អនុក្រឹត្យលេខ ២១៤ អនក្រ.បក ស្ដីពី ការកំណត់ប្រាក់ឧបត្ថម្ភចំពោះសមាជិកក្រុមប្រឹក្សា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ៩៤៣០

០៨-១២-២០០៩ -អនុក្រឹត្យលេខ ១៧៣១ អនក្រ.តត ស្ដីពី ការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ ៩៤៣៤

០៨-១២-២០០៩ -អនុក្រឹត្យលេខ ១៧៣២ អនក្រ.តត ស្ដីពី ការតម្លើងឋានន្តរស័ក្តិមន្ត្រីរាជការ ៩៤៣៦

០៨-១២-២០០៩ -អនុក្រឹត្យលេខ ១៧៣៣ អនក្រ.តត ស្ដីពី ការផ្ទេរភារកិច្ច និង តែងតាំងមុខតំណែង នាយនគរបាលជាតិ ៩៤៣៨

០៨-១២-២០០៩ -អនុក្រឹត្យលេខ ១៧៣៤ អនក្រ.តត ស្ដីពី ការជូនមេដាយស្ថាបនាជាតិ ៩៤៤០

០៨-១២-២០០៩ -អនុក្រឹត្យលេខ ១៧៣៥ អនក្រ.តត ស្ដីពី ការជូនមេដាយសុវត្ថារា ៩៤៤១

០៨-១២-២០០៩ -អនុក្រឹត្យលេខ ១៧៣៦ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ៩៤៤២

០៨-១២-២០០៩ -អនុក្រឹត្យលេខ ១៧៣៧ អនក្រ.តត ស្ដីពី ការជូនមេដាយសហមេត្រី ៩៤៥២

១៤-១២-២០០៩ -អនុក្រឹត្យលេខ ១៧៣៨ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ៩៤៥៣

១៤-១២-២០០៩ -អនុក្រឹត្យលេខ ១៧៣៩ អនក្រ.តត ស្ដីពី ការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ ៩៤៥៥

១៤-១២-២០០៩ -អនុក្រឹត្យលេខ ១៧៤០ អនក្រ.តត ស្ដីពី ការផ្ទេរភារកិច្ច និង តែងតាំងមុខតំណែង នាយនគរបាលជាតិ ៩៤៥៧


### ២-សេចក្ដីសម្រេច


១៤-១២-២០០៩ -សេចក្ដីសម្រេចលេខ ៧៦ សសរ ស្ដីពី ការបង្កើតគណៈកម្មការ និង ក្រុមការងារសម្រាប់អនុវត្ត មូលនិធិពហុភាគី និង សម្របសម្រួលអភិក្រម គ្របដណ្ដប់លើវិស័យពាណិជ្ជកម្ម ៩៤៥៨


## III-ការិយាល័យក្រសួង

### ១-ទីស្ដីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ


២៤-១១-២០០៩ -សារាចរណែនាំលេខ ០០៣ សហវ ស្ដីពី ការបិទបញ្ជីចំណូល ចំណាយ និង ធ្វើរបាយការណ៍ បូកសរុបទូទាត់ថវិកា រាជធានី ខេត្ត ឆ្នាំ ២០០៩ ៩៤៦៤


### ២-ធនាគារជាតិ នៃ កម្ពុជា


១៩-១០-២០០៩ -ប្រកាសលេខ ធ៥-០៩-២២៩ ប្រក ស្ដីពី ការដាក់ឱ្យអនុវត្តកិច្ចសន្យាមេ សម្រាប់ប្រតិបត្តិការ ទទួលទិញវិញ ដើម្បីធានាដល់ប្រតិបត្តិការអន្តរធនាគារនៅក្នុងទីផ្សារូបិយវត្ថុ ៩៤៦៩

## ៣~ទីស្ដីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

២៦-០២-២០០៩ -លិខិតបញ្ជាក់លេខ ០៨៨០ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **លីម ម៉េងស្រ៊ុន ឌីវេឡុបមេន គ្រុបខឹង** ៩៤៨៥

២៦-០២-២០០៩ -លិខិតបញ្ជាក់លេខ ០៨៨១ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ប្រាយ ស្ទូខ ឆេ ឌីវេឡុបមេន** ៩៤៨៧

២៦-០២-២០០៩ -លិខិតបញ្ជាក់លេខ ០៨៨២ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឌី & អេស ផេស៊ីហ្វិក អ៊ិនធើណេសិនណល** ៩៤៨៩

២៦-០២-២០០៩ -លិខិតបញ្ជាក់លេខ ០៨៨៣ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខនត្លូអិនស៍ ប្រជេគ មេនេចមេន ប្រាយវេត លីមីធីត** ៩៤៩១

២៦-០២-២០០៩ -លិខិតបញ្ជាក់លេខ ០៨៨៤ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អ៊ីនធើ-ខេម បេស ផាតនើស៊ីប ខូ អិលធីឌី** ៩៤៩៣

២៦-០២-២០០៩ -លិខិតបញ្ជាក់លេខ ០៨៨៦ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សេនតូសា សៀល** ៩៤៩៥

២៦-០២-២០០៩ -លិខិតបញ្ជាក់លេខ ០៨៨៨ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ដាយ ហ៊ីង ដាច** ៩៤៩៧

២៦-០២-២០០៩ -លិខិតបញ្ជាក់លេខ ០៨៨៩ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **គីម លី ហេង គ្រុបខឹង** ៩៤៩៩

២៦-០២-២០០៩ -លិខិតបញ្ជាក់លេខ ០៨៩០ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អិល អិម ម៉ាយ** ៩៥០១

២៦-០២-២០០៩ -លិខិតបញ្ជាក់លេខ ០៨៩១ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេជេ & អេច ឌីវេឡុបមេន** ៩៥០៣

# ព្រះរាជក្រម

នស/រកម/១២០៩/០២៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីសុំកូនអន្តរប្រទេស ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៩ នាសម័យប្រជុំរដ្ឋសភាលើកទី៣ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៩ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៦ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ :

# ច្បាប់

# ស្តីពី

# ស្មុំកូនអន្តរប្រទេស

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះ មានគោលដៅកំណត់ពីគោលការណ៍ លក្ខខណ្ឌ នីតិវិធី ទម្រង់បែបបទ និង អានុភាពនៃសុំកូនអន្តរប្រទេស ។

**មាត្រា ២.-**

ច្បាប់នេះ មានគោលបំណងធានាឧត្តមប្រយោជន៍ និង ការពារសិទ្ធិជាមូលដ្ឋានរបស់កុមារ ដែលជាកម្មវត្ថុនៃសុំកូនអន្តរប្រទេស ។

**មាត្រា ៣.-**

ច្បាប់នេះ មានវិសាលភាពលើការសុំកុមារសញ្ជាតិខ្មែរ ដែលមានលំនៅឋានអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយប្តីប្រពន្ធ ដែលមានលំនៅឋានអចិន្ត្រៃយ៍នៅក្នុងប្រទេសណាមួយផ្សេងទៀត ដើម្បីយកទៅចិញ្ចឹមជាកូន ដែលទទួលស្គាល់ដោយច្បាប់នៅប្រទេសនោះ ។

**មាត្រា ៤.-**

វាក្យស័ព្ទសំខាន់ៗ ដែលប្រើប្រាស់ក្នុងច្បាប់នេះ មាននិយមន័យដូចតទៅ :

- **ការថែទាំជំនួស** សំដៅដល់ការថែទាំ ដែលផ្តល់ទៅឱ្យកុមារកំព្រា និង កុមារងាយរងគ្រោះ ដែលមិនស្ថិតនៅក្រោមការថែទាំរបស់ឪពុកម្តាយបង្កើតនៃកុមារទាំងនោះ ។
- **កុមារដែលត្រូវការនូវការថែទាំពិសេស** សំដៅដល់កុមារពិការផ្នែករាងកាយសម្បទាធ្ងន់ធ្ងរ ឬ ពិការផ្នែកស្មារតី ឬ កុមារដែលមានជំងឺរ៉ាំរ៉ៃ ។
- **កុមារដែលត្រូវបោះបង់ចោល** សំដៅដល់កុមារដែលអាជ្ញាធរមានសមត្ថកិច្ចរកឃើញ ឬ ត្រូវបានសាធារណជនរាយការណ៍ទៅអាជ្ញាធរមានសមត្ថកិច្ច និង ជាកុមារដែលគេមិនស្គាល់ឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬ ជាកុមារដែលឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនបោះបង់ចោល និង រកមិនឃើញអ្នកទាំងនោះ យ៉ាងតិច ៥ (ប្រាំ) ខែជាប់គ្នា ។

- **ជនម្នាក់** សំដៅដល់ជនដែលគ្មានសហព័ទ្ធស្របច្បាប់ ។

- **ទីភ្នាក់ងារសុំកូនអន្តរប្រទេស** សំដៅដល់ទីភ្នាក់ងារដែលបានទទួលការអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចនៃព្រះរាជាណាចក្រកម្ពុជា និង ពីស្ថាប័នមានសមត្ថកិច្ចនៃប្រទេសទទួលកូនសុំ ដើម្បីធ្វើប្រតិបត្តិការក្នុងនីតិវិធីសុំកូនអន្តរប្រទេស ។

- **បុត្តភាព** សំដៅដល់ក្រសែញាតិ ដែលទាក់ទងពីឪពុកម្ដាយទៅកូនបង្កើតរបស់ខ្លួន ។

- **ប្រទេសលំនៅឋានអចិន្ត្រៃយ៍** សំដៅដល់ប្រទេសដែលជនណាមួយកំពុងរស់នៅដោយមានបំណងយកប្រទេសនោះធ្វើជាលំនៅឋានអចិន្ត្រៃយ៍ ។ ជននោះត្រូវបានទទួលស្គាល់ដោយច្បាប់នៃប្រទេសដែលខ្លួនរស់នៅ ថាមានសិទ្ធិរស់នៅជាអចិន្ត្រៃយ៍នៅក្នុងប្រទេសនោះ ។

- **មណ្ឌលកុមារកំព្រា** សំដៅដល់មណ្ឌលរបស់រដ្ឋ ឬ របស់អង្គការមិនមែនរដ្ឋាភិបាល ដែលទទួលស្គាល់ដោយក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច សម្រាប់ចិញ្ចឹមថែទាំ និង ផ្ដល់នូវតម្រូវការជាមូលដ្ឋានគ្រប់យ៉ាងក្នុងការអភិវឌ្ឍរបស់កុមារដែលគ្មានឪពុកម្ដាយ ឬ គ្មានឪពុក ឬ គ្មានម្ដាយ ឬ កុមារ ដែលត្រូវបោះបង់ចោល ឬ កុមារដែលឪពុកម្ដាយ ឬ អ្នកអាណាព្យាបាលពុំមានលទ្ធភាពផ្ដល់ការថែទាំគ្រប់គ្រាន់ ។

- **ប្ដីប្រពន្ធ** សំដៅដល់បុរសម្នាក់ និង ស្ត្រីម្នាក់ដែលមានចំណងអាពាហ៍ពិពាហ៍ស្របច្បាប់ ។

- **សុំកូនដោយសាច់ញាតិ** សំដៅដល់ការសុំកូនដោយអ្នកសុំនូវកុមារដែលត្រូវជាចៅរបស់ខ្លួន ចៅទួតរបស់ខ្លួន ក្មួយរបស់ខ្លួន ឬ កុមារដែលត្រូវជាកូន ចៅ ចៅទួត ឬ ក្មួយរបស់សហព័ទ្ធរបស់ខ្លួន ។

- **សុំកូនពេញលេញ** សំដៅដល់សុំកូនដែលមានអានុភាពបង្កើតនូវទំនាក់ទំនងអចិន្ត្រៃយ៍ ជាឪពុកម្ដាយ និង កូនរវាងឪពុកម្ដាយចិញ្ចឹម ឬ ឪពុកចិញ្ចឹម ឬ ម្ដាយចិញ្ចឹម និងកូនសុំ និង បញ្ចប់សិទ្ធិ និង កាតព្វកិច្ចរវាងកូននិងឪពុកម្ដាយបង្កើត ឬ អ្នកអាណាព្យាបាលសម្រាប់ផលប្រយោជន៍របស់ខ្លួន ។

- **អ្នកសុំ** សំដៅដល់ប្ដីប្រពន្ធដែលកំពុងស្វះស្វែងសុំកុមារយកទៅចិញ្ចឹម ។

- **ឪពុកម្ដាយចិញ្ចឹម** សំដៅដល់ប្ដីប្រពន្ធដែលបានទទួលសិទ្ធិជាផ្លូវការពី

តុលាការមានសមត្ថកិច្ច ឱ្យធ្វើជាឪពុកម្តាយថ្មីនៃកូនសុំស្របតាមបទប្បញ្ញត្តិដូចមានចែងក្នុងច្បាប់នេះ ។

## ជំពូកទី ២

## គោលការណ៍ទូទៅនៃសុំកូនអន្តរប្រទេស

**មាត្រា ៥.-**

សុំកូនអន្តរប្រទេសត្រូវអនុវត្តតាមគោលការណ៍ដូចតទៅ :

១- កុមារត្រូវចម្រើនធំធាត់នៅក្នុងបរិយាកាសគ្រួសារ បរិយាកាសសុភមង្គល សេចក្តីស្រឡាញ់ និង ការយោគយល់ ដើម្បីឱ្យមានការអភិវឌ្ឍពេញលេញ និង យ៉ាងសុខដុមនូវបុគ្គលិកលក្ខណៈរបស់ខ្លួន ។ សុំកូនអន្តរប្រទេស អាចអនុញ្ញាតបានក្រោយពីអស់លទ្ធភាពផ្តល់ការឧបត្ថម្ភគាំទ្រ ដើម្បីឱ្យកុមាររស់នៅក្នុងគ្រួសារកំណើត និង ក្រោយពីបានធ្វើការពិចារណា អំពីសុំកូននៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

២- សុំកូនអន្តរប្រទេស អាចប្រព្រឹត្តទៅបានលុះត្រាតែជាសុំកូនពេញលេញ ដែលបង្កើតនូវទំនាក់ទំនងរវាងអ្នកសុំ និង កូនសុំជាអចិន្ត្រៃយ៍ និង ដែលផ្តល់ដល់កុមារនូវឋានៈ សិទ្ធិ និង កាតព្វកិច្ចដូចជាកូនបង្កើតរបស់ឪពុកម្តាយចិញ្ចឹមនោះ ។

៣- កុមារទាំងឡាយណាដែលបំពេញបាននូវលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ១០ អាចធ្វើជាកម្មវត្ថុនៃសុំកូនអន្តរប្រទេសបានដោយមិនមានការរើសអើងអំពីពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិកំណើត ឋានៈក្នុងសង្គម ធនធាន ពិការភាព ឬ ស្ថានភាពផ្សេងៗទៀតរបស់កុមារ ឬ របស់ឪពុកម្តាយ ឬ របស់ឪពុក ឬ របស់ម្តាយ ឬ របស់អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ ។

៤- រាល់ការសម្រេច និង សកម្មភាពទាក់ទងនឹងដំណើរការសុំកូនអន្តរប្រទេស ត្រូវគិតគូរឱ្យបានច្រើនលើសលប់ដល់ឧត្តមប្រយោជន៍របស់កុមារ ។

៥- តុលាការ និង អាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធក្នុងដំណើរការសុំកូនអន្តរប្រទេសត្រូវធានាថា នៅពេលកំពុងដំណើរការនីតិវិធីសុំកូន កុមារដែលមានសមត្ថភាពអាចយល់ដឹងសព្វគ្រប់ ត្រូវបានពិគ្រោះយោបល់ និង ពន្យល់ណែនាំឱ្យបានត្រឹមត្រូវអំពីអានុភាព

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

0/35 Kol

នានា ដែលកើតចេញពីសុំកូននេះដោយគិតគូរដល់សេចក្តីប្រាថ្នា និង មតិរបស់កុមារ ដើម្បីឧត្តមប្រយោជន៍របស់កុមារ ។

៦- ហាមការធ្វើអាជីវកម្ម ឬ ធ្វើសកម្មភាពយកផលកម្រៃពីសុំកូនអន្តរប្រទេស ។

អាជីវកម្ម ឬ សកម្មភាពយកផលកម្រៃពីសុំកូនអន្តរប្រទេសមាន ៖

- អំពើប្រព្រឹត្តក្នុងគោលដៅចង់បានកម្រៃ ញុះញង់ដោយផ្ទាល់ដល់ឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឱ្យបោះបង់ទារកដែលកើតមកហើយ ឬ ដែលនឹងកើតដើម្បីឱ្យប្រគល់កូនតាមរយៈសុំកូនអន្តរប្រទេស

- អំពើប្រព្រឹត្តក្នុងគោលដៅចង់បានកម្រៃ ធ្វើជាអន្តរការីរវាងប្តីប្រពន្ធដែលចង់សុំកូនយកមកចិញ្ចឹមតាមរយៈសុំកូនអន្តរប្រទេស និង ឪពុក ឬ ម្តាយដែលចង់បោះបង់កូនដែលកើតមកហើយ ឬ ដែលនឹងកើត និង

- អំពើប្រព្រឹត្តក្នុងគោលដៅចង់បានកម្រៃធ្វើជាអន្តរការីរវាងប្តីប្រពន្ធដែលចង់សុំកូនយកមកចិញ្ចឹមតាមរយៈសុំកូនអន្តរប្រទេស និង ស្ត្រីម្នាក់យល់ព្រមពពោះដើម្បីនឹងប្រគល់កូននោះទៅឱ្យអ្នកសុំ ។

៧- អាជ្ញាធរមានសមត្ថកិច្ច ដែលពាក់ព័ន្ធក្នុងនីតិវិធីសុំកូនអន្តរប្រទេស ត្រូវធានាថាដំណើរការសុំកូនអន្តរប្រទេស មិនបណ្តាលឱ្យមានការទទួលផលកម្រៃផ្នែកហិរញ្ញវត្ថុដោយមិនស្របច្បាប់ និង ត្រូវបង្ការមិនឱ្យមានការចាប់ពង្រត់ ការលក់ និង ការជួញដូរកុមារក្នុងពេលកំពុងដំណើរការសុំកូនអន្តរប្រទេស ។ មានតែប្រាក់ចំណាយ សោហ៊ុយ និងវិភាគទាន ដែលកំណត់ដោយបទប្បញ្ញត្តិនៃច្បាប់នេះដែលត្រូវបង់ ។

## ជំពូកទី ៣

## អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស

**មាត្រា ៦.–**

ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច បំពេញតួនាទីជាអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

**មាត្រា ៧.-**

អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសមានតួនាទី និង ភារកិច្ចដូចតទៅ :

១- រៀបចំ និង ត្រួតពិនិត្យការអនុវត្តគោលនយោបាយ ច្បាប់ បទបញ្ញា និង នីតិវិធីទាក់ទងនឹងការសម្រេចលើកិច្ចការសុំកូនអន្តរប្រទេស ។

២-ធ្វើសហប្រតិបត្តិការ និង ធ្វើការសម្របសម្រួលលើការប្រាស្រ័យទាក់ទងគ្នា ទាក់ទងនឹងកិច្ចការសុំកូនអន្តរប្រទេសជាមួយក្រសួង ស្ថាប័ន និង ទីភ្នាក់ងារដែលមានសមត្ថកិច្ចដោះស្រាយកិច្ចការសុំកូនអន្តរប្រទេស នៅក្នុងព្រះរាជាណាចក្រកម្ពុជា និង ជាមួយអាជ្ញាធរកណ្តាល និង អាជ្ញាធរមានសមត្ថកិច្ច ទទួលបន្ទុកសុំកូនអន្តរប្រទេស នៃប្រទេសទទួល ។

៣- ចាត់វិធានការសមស្របដើម្បីបង្ការ និង ទប់ស្កាត់ ការទទួលផលកម្រៃផ្នែកហិរញ្ញវត្ថុដោយមិនសមស្រប ឬ ផលចំណេញផ្សេងៗទៀតទាក់ទងនឹងសុំកូនអន្តរប្រទេស ។

៤- រៀបចំបណ្តុះបណ្តាលជំនាញកិច្ចការសុំកូនអន្តរប្រទេសដល់មន្ត្រីពាក់ព័ន្ធ។

៥- ពិនិត្យលើសំណើរបស់រដ្ឋបាលសុំកូនអន្តរប្រទេស ទាក់ទងនឹងករណីសុំកូនអន្តរប្រទេសនីមួយៗតាមការចាំបាច់ ។

៦- ធ្វើអធិការកិច្ចលើកិច្ចការពាក់ព័ន្ធសុំកូនអន្តរប្រទេស ។ គ្មានជនណាអាចរារាំង បង្អាក់ ឬ ជ្រៀតជ្រែកក្នុងការងារអធិការកិច្ចដែលបានធ្វើឡើងត្រឹមត្រូវតាមច្បាប់បានឡើយ ។

៧- បំពេញភារកិច្ចផ្សេងៗទៀតដែលក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច យល់ថាចាំបាច់សម្រាប់អនុវត្តកិច្ចការសុំកូនអន្តរប្រទេស ដោយអនុលោមទៅតាមច្បាប់ និង បទបញ្ញាជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៨.-**

អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស មានរដ្ឋបាលសុំកូនអន្តរប្រទេសជាសេនាធិការ ។

មន្ត្រីបម្រើការក្នុងរដ្ឋបាលសុំកូនអន្តរប្រទេសរួមមាន អ្នកធ្វើការងារផ្នែកសង្គមកិច្ច អ្នកចិត្តសាស្ត្រ និង អ្នកជំនាញខាងច្បាប់បានទទួលការបណ្តុះបណ្តាលពិសេស ស្តីពីសុំកូន និង សិទ្ធិកុមារ ។

ការរៀបចំ និង ការប្រព្រឹត្តទៅរបស់រដ្ឋបាលស៊ុំកូនអន្តរប្រទេស ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។

**មាត្រា ៩.-**

រដ្ឋបាលស៊ុំកូនអន្តរប្រទេស មានតួនាទី និង ភារកិច្ចដូចតទៅ :

១-រៀបចំ ថែរក្សាបញ្ជីសម្គាល់ និង សំណុំឯកសាររបស់កុមារដែលមានលក្ខណសម្បត្តិសមស្របសម្រាប់ស៊ុំកូនអន្តរប្រទេស ។

២-វាយតម្លៃស្ថានភាពកុមារទាំងអស់ ដែលមានឈ្មោះក្នុងបញ្ជីសម្គាល់ដើម្បីកំណត់ទម្រង់នៃការចិញ្ចឹមថែទាំសមស្របបំផុតសម្រាប់កុមារ និង ធានាថាកុមារទាំងនោះទទួលបានការចិញ្ចឹមថែទាំតាមតម្រូវការ ។

៣-ប្រឹងប្រែងរកដំណោះស្រាយឱ្យអស់លទ្ធភាពក្នុងប្រទេស ក្នុងការថែទាំជាអចិន្ត្រៃយ៍នៅតាមគ្រួសារ ឬ នៅជាមួយអ្នកអាណាព្យាបាល មុននឹងដំណើរការស៊ុំកូនអន្តរប្រទេស ។

៤-ទទួលពិនិត្យ និង ចាត់ការពាក្យស៊ុំកូនអន្តរប្រទេស និង ឯកសារពាក់ព័ន្ធផ្សេងៗទៀតរបស់អ្នកសុំ ។

៥-ផ្គូផ្គងអ្នកសុំជាមួយកុមារដែលមានលក្ខណសម្បត្តិសមស្របសម្រាប់ស៊ុំកូនអន្តរប្រទេស និង ផ្តល់មតិយោបល់លើករណីស៊ុំកូនអន្តរប្រទេស ជូនរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។

៦-ផ្តល់ដំណឹងទៅអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ច ឬ ទីភ្នាក់ងារស៊ុំកូនអន្តរប្រទេសដែលបានទទួលការអនុញ្ញាតពីប្រទេសទទួល អំពីនីតិវិធីស៊ុំកូន និង ការវិវឌ្ឍនៃករណីស៊ុំកូន ។

៧-សម្របសម្រួលការប្រគល់កុមារទៅឱ្យអ្នកសុំ និង រៀបចំឯកសារ ដើម្បីឱ្យកុមារធ្វើដំណើរចូលទៅប្រទេសរបស់អ្នកសុំ ។

៨-ផ្តល់ ឬ សម្របសម្រួលការផ្តល់សេវាក្រោយស៊ុំកូនសមស្របដល់កុមារ គ្រួសារអ្នកសុំ និង គ្រួសារបង្កើតតាមការចាំបាច់ ។

៩-ផ្តល់មតិយោបល់ទាក់ទងនឹងការផ្តល់ការអនុញ្ញាតឱ្យទីភ្នាក់ងារស៊ុំកូនអន្តរ-

ប្រទេស ធ្វើប្រតិបត្តិការសុំកូនអន្តរប្រទេស ឬ ការដកហូតការអនុញ្ញាត ជូនអាជ្ញាធរកណ្តាល ទទួលខុសត្រូវកិច្ចការសុំកូនអន្តរប្រទេស ។

១០- បំពេញភារកិច្ចផ្សេងៗទៀតទាក់ទងនឹងសុំកូនអន្តរប្រទេសតាមការចាំបាច់ ដោយអនុលោមទៅតាមច្បាប់ និង បទបញ្ញា របស់ព្រះរាជាណាចក្រកម្ពុជា និង តាមការប្រគល់អំណាចរបស់អាជ្ញាធរកណ្តាល ។

## ជំពូកទី ៤
## លក្ខខណ្ឌសម្រាប់សុំកូន
### ផ្នែកទី ១
### កូនសុំ

**មាត្រា១០.-**

កុមារដែលអាចជាកម្មវត្ថុនៃសុំកូនអន្តរប្រទេសបាន ត្រូវឆ្លើយតបនឹងលក្ខខណ្ឌទាំងអស់ ដូចខាងក្រោម ៖

១- កុមារសញ្ជាតិខ្មែរដែលមានលំនៅឋានជាអចិន្ត្រៃយ៍ក្នុងព្រះរាជាណាចក្រកម្ពុជា ។

២-កុមារមានអាយុក្រោម៨ (ប្រាំបី) ឆ្នាំ គិតត្រឹមថ្ងៃទទួលពាក្យសុំ លើកលែងតែករណីកុមារត្រូវការទូវការថែទាំពិសេស ដែលអាចអនុញ្ញាតបានដល់អាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ។ ក្នុងករណី កុមារមានបងប្អូនបង្កើតច្រើននាក់ ហើយម្នាក់មានអាយុក្រោម ៨ (ប្រាំបី) ឆ្នាំ អាចអនុញ្ញាតឱ្យសុំកុមារនោះរួមជាមួយនឹងបងប្អូនបង្កើតដែលមានអាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ។

៣- កុមារកំពុងរស់នៅក្នុងមណ្ឌលកុមារកំព្រា ឬ រស់នៅក្រោមការទុកដាក់សមស្របផ្សេងទៀត ដែលត្រួតពិនិត្យដោយក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។

៤- កុមារទាំងនោះស្ថិតក្រោមអាណាព្យាបាលសម្រាប់អនីតិជន ឬ កុមារដែលស្ថិតនៅក្រោមអំណាចមេបាដែលមានស្ថានភាពលំបាកបំផុត ។

៥- កុមារនោះត្រូវបានប្រកាសថាអាចសុំជាកូនចិញ្ចឹមបាន ដោយអនុលោមតាមមាត្រា ១៣ នៃច្បាប់នេះ ។

ក្នុងករណីស៊ុំកូនដោយសាច់ញាតិ ស៊ុំកូនអាចអនុញ្ញាតបានចំពោះកុមារមានអាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ដែលរស់នៅក្នុង ឬ ក្រៅមណ្ឌលកុមារកំព្រា ។

**មាត្រា ១១.-**

ករណីមានកុមារត្រូវបានរកឃើញ និង បញ្ជូនមកមណ្ឌលកុមារកំព្រា ហើយរកមិនឃើញឪពុកម្ដាយ ឬ ឪពុក ឬ ម្ដាយ ឬ សាច់ញាតិ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជននោះ ប្រធានមណ្ឌលកុមារកំព្រា ត្រូវជូនដំណឹងទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត អំពីវត្តមានរបស់កុមារ ដែលបានចូលមកស្នាក់នៅក្នុងមណ្ឌល យ៉ាងយូរបំផុតរយៈពេល ៧ (ប្រាំពីរ) ថ្ងៃ នៃថ្ងៃធ្វើការ គិតពីពេលដែលកុមារមកដល់មណ្ឌល ។ មន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ត្រូវជូនដំណឹងជាបន្ទាន់ទៅក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ដើម្បីបញ្ចូលឈ្មោះកុមារទៅក្នុងបញ្ជី ស្ដីពីកុមារដែលត្រូវបានរាយការណ៍ថាត្រូវបានគេបោះបង់ចោល ។

មន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ត្រូវប្រឹងប្រែងគ្រប់លទ្ធភាពដើម្បីស្វែងរកឪពុកម្ដាយ ឬ ឪពុក ឬ ម្ដាយ ឬ សាច់ញាតិ និង អ្នកអាណាព្យាបាលសម្រាប់អនីតិជនមុន នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ដោយប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសាធារណៈទៅតាមលទ្ធភាពដូចជា ទូរទស្សន៍ វិទ្យុ ឬ សារព័ត៌មាន និង រូបភាពរបស់កុមារនោះ ។ ជនណាដែលអះអាងថាខ្លួនជាឪពុកម្ដាយ ឬ ឪពុក ឬ ម្ដាយ ឬ សាច់ញាតិ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ ជននោះត្រូវបង្ហាញភស្តុតាងផ្សេងៗ ដែលបញ្ជាក់ថាខ្លួនមានជាប់ទាក់ទងជាសាច់ញាតិ ឬ អ្នកអាណាព្យាបាល សម្រាប់អនីតិជនជាមួយកុមារស្របទៅតាមបទប្បញ្ញត្តិជាធរមាន ។

បន្ទាប់ពីការផ្សព្វផ្សាយដំណឹងរយៈពេល ៥ (ប្រាំ) ខែ នៅតែរកមិនឃើញឪពុកម្ដាយ ឬ ឪពុក ឬ ម្ដាយ ឬ សាច់ញាតិ និង អ្នកអាណាព្យាបាល សម្រាប់អនីតិជនមុននោះ មន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ត្រូវធ្វើរបាយការណ៍ស្ដីពីការខិតខំស្រាវជ្រាវនេះ ហើយត្រូវធ្វើមួយច្បាប់ទៅក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ដើម្បីចុះឈ្មោះកុមារទៅក្នុងសៀវភៅកត់ត្រាកុមារដែលត្រូវបោះបង់ចោល ។

11/35

Ksl

ចាប់ពីពេលដែលកុមារត្រូវបានរកឃើញ រហូតដល់តុលាការបានជ្រើសតាំងអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ ប្រធានមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត គឺជាអ្នកអាណាព្យាបាលសម្រាប់អនីតិជនបណ្តោះអាសន្ន ។ បញ្ញត្តិស្តីពីអាណាព្យាបាលសម្រាប់អនីតិជនដែលមានចែងក្នុងក្រមរដ្ឋប្បវេណី ត្រូវយកអនុវត្តផងដែរ ចំពោះអ្នកអាណាព្យាបាលសម្រាប់អនីតិជនបណ្តោះអាសន្ន ។ អ្នកអាណាព្យាបាលសម្រាប់អនីតិជនបណ្តោះអាសន្ន គ្មានសិទ្ធិផ្តល់ការយល់ព្រមលើសុំកូនទេ ។

ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ត្រូវរៀបចំបញ្ជី និង បញ្ចូលព័ត៌មានថ្មីៗឱ្យបានទៀងទាត់ស្តីពីកុមារដែលត្រូវបោះបង់ចោល ។

ករណីកុមារដែលត្រូវបោះបង់ចោលពុំអាចរកឃើញឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ សាច់ញាតិ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ហើយពុំមានសំបុត្រអត្រានុកូលដ្ឋានកំណើត ប្រធានមណ្ឌលកុមារកំព្រា ត្រូវសុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើតកុមារនោះទៅតាមបទប្បញ្ញត្តិច្បាប់ជាធរមាន ។

**មាត្រា១២.–**

ប្រសិនបើ អ្នកអនុវត្តអំណាចមេបាដែលស្ថិតនៅក្នុងស្ថានភាពលំបាកបំផុត បានធ្វើការទុកដាក់កុមារឱ្យនៅក្រោមការថែទាំរបស់ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចនោះ ត្រូវបញ្ចូលឈ្មោះកុមារទៅក្នុងសៀវភៅកត់ត្រាកុមារ ដែលត្រូវបានធ្វើការទុកដាក់ឱ្យនៅក្រោមការថែទាំរបស់ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។

ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចត្រូវរៀបចំបញ្ជី និង បញ្ចូលព័ត៌មានថ្មីៗឱ្យបានទៀងទាត់ស្តីពីកុមារដែលអ្នកអនុវត្តអំណាចមេបារបស់ខ្លួន បានធ្វើការទុកដាក់កុមារឱ្យនៅក្រោមការថែទាំរបស់ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។

**មាត្រា១៣.–**

ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ត្រូវខិតខំឱ្យអស់លទ្ធភាពក្នុងការបញ្ជូនកុមារទៅគ្រួសារកំណើត ហើយបើមិនអាចធ្វើទៅបានទេ ត្រូវទុកដាក់កុមារតាមរយៈសុំកូនក្នុងស្រុកនៅក្នុងព្រះរាជាណាចក្រកម្ពុជា មុននឹងពិនិត្យរកលក្ខណសម្បត្តិសុំកូនអន្តរប្រទេសរបស់កុមារ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL * ព្រះបរមរាជវាំង

នៅពេលវិធានការនានា ដូចមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ត្រូវបានបញ្ចប់ កុមារអាចនឹងត្រូវបានបញ្ចូលឈ្មោះទៅក្នុងបញ្ជីស្តីពីកុមារដែលកំណត់ថាមានលក្ខណ-សម្បត្តិសមស្របសម្រាប់សុំកូនអន្តរប្រទេស ។

## ផ្នែកទី ២
## ការយល់ព្រមលើសុំកូន

**មាត្រា ១៤.-**

ដំណើរការសុំកូនអាចប្រព្រឹត្តទៅបានលុះត្រាតែមានការយល់ព្រមរបស់ឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារតាមករណីដូចខាងក្រោមនេះ :

ក- ក្នុងករណីកុមារមានចំណងបុត្តភាពជាមួយឪពុក និង ម្តាយ ការយល់ព្រមត្រូវផ្តល់ដោយឪពុក និង ម្តាយរបស់កុមារនោះ ។

ខ- ក្នុងករណីដែលឪពុក ឬ ម្តាយណាមួយរបស់កុមារបានស្លាប់ ឬ ស្ថិតក្នុងស្ថានភាពដែលមិនអាចបង្ហាញឆន្ទៈបាន ឬ ត្រូវបានដកហូតអំណាចមេបា ការយល់ព្រមត្រូវផ្តល់ដោយឪពុក ឬ ម្តាយតែម្ខាងដែលមានអំណាចមេបាជាការគ្រប់គ្រាន់ ។

គ- ក្នុងករណីដែលឪពុកម្តាយរបស់កុមារបានស្លាប់ ឬ ស្ថិតនៅក្នុងស្ថានភាពដែលមិនអាចបង្ហាញឆន្ទៈបាន ឬ ត្រូវបានដកហូតអំណាចមេបា ការយល់ព្រមត្រូវផ្តល់ដោយអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារនោះ ។

**មាត្រា ១៥.-**

ការយល់ព្រមខាងលើត្រូវផ្តល់ឱ្យដោយសេរី និង ច្បាស់លាស់ដោយមិនត្រូវមានវិការៈណាមួយដូចជា ការបង្ខិតបង្ខំ ការឆបោក ឬ ការបញ្ឆុះបញ្ចូលតាមរយៈការផ្តល់ ឬ ការសន្យាផ្តល់ប្រាក់ រង្វាន់ សំណង ឬ ផលប្រយោជន៍ណាមួយឡើយ និង ដោយបានដឹងច្បាស់អំពីវិបាកនៃការយល់ព្រមរបស់ខ្លួនចំពោះសុំកូនអន្តរប្រទេស ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

13/35 [illegible]

**មាត្រា ១៦.-**

ឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ ត្រូវទទួលនូវការពិគ្រោះយោបល់ពីភ្នាក់ងារសង្គមកិច្ចមានសមត្ថកិច្ច ដែលបានទទួលការអនុញ្ញាតជាមុនសិន មុននឹងផ្តល់ការយល់ព្រម ។ ភ្នាក់ងារសង្គមកិច្ចមានសមត្ថកិច្ច ត្រូវប្រាប់យ៉ាងច្បាស់លាស់ ដល់អ្នកដែលត្រូវផ្តល់ការយល់ព្រមអំពីអានុភាពនៃការយល់ព្រម ការបញ្ចប់នូវបុត្តភាព ព្រមទាំងការបញ្ចប់សិទ្ធិនិងកាតព្វកិច្ចជាអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន និង ត្រូវប្រាប់អំពីបែបបទ និង រយៈពេលបញ្ឈប់ការយល់ព្រមដូចមានចែងក្នុងមាត្រា ១៧ នៃច្បាប់នេះ ។ ភ្នាក់ងារសង្គមកិច្ចមានសមត្ថកិច្ច ត្រូវធ្វើកំណត់ហេតុជាលាយលក្ខណ៍អក្សរ អំពីការសម្ភាសន៍របស់ខ្លួនជាមួយឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ ។

ទោះក្នុងករណីណាក៏ដោយ ការយល់ព្រមត្រូវផ្តល់សក្ខីកម្មជាលាយលក្ខណ៍អក្សរ នៅចំពោះមុខមេឃុំ ឬ ចៅសង្កាត់ខាងទីលំនៅរបស់ឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ ។

មេឃុំ ឬ ចៅសង្កាត់ និងភ្នាក់ងារសង្គមកិច្ចមានសមត្ថកិច្ចត្រូវធានាថា រាល់ការយល់ព្រមរបស់ឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ជាការយល់ព្រមដែលគោរពទៅតាមខ្លឹមសារនៃមាត្រា ១៥ នៃច្បាប់នេះ ។

មេឃុំ ឬ ចៅសង្កាត់ ត្រូវចាត់ចែងធ្វើកំណត់ហេតុជាលាយលក្ខណ៍អក្សរ អំពីការយល់ព្រមនេះ ក្រោយពីបានពិនិត្យថា ភ្នាក់ងារសង្គមកិច្ចមានសមត្ថកិច្ចបានពិគ្រោះយោបល់ជាមុនជាមួយឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ និង បានប្រាប់យ៉ាងត្រឹមត្រូវអំពីអានុភាពនៃការយល់ព្រមនេះ ។

**មាត្រា ១៧.-**

ឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ អាចបញ្ឈប់ការយល់ព្រមរបស់ខ្លួនវិញបាន រហូតដល់មុនពេលសេចក្តីសម្រេចរបស់តុលាការស្តីពីសុំកូនចិញ្ចឹមជាស្ថាពរ ។ ការបញ្ឈប់ការយល់ព្រមរបស់ឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជននេះ អាចធ្វើជាលាយលក្ខណ៍អក្សរ ឬ ដោយផ្ទាល់មាត់ នៅចំពោះមុខមេឃុំ ឬ ចៅសង្កាត់ខាងលំនៅឋានរបស់ខ្លួន ។ មេឃុំ ឬ ចៅសង្កាត់ខាង

Kh35h Ksl

លំនៅឋានរបស់ឪពុកម្ដាយ ឬ ឪពុក ឬ ម្ដាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ ត្រូវធ្វើកំណត់ហេតុអំពីកិច្ចការនេះ ហើយត្រូវបញ្ជូនកំណត់ហេតុនេះទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ប្រធានមណ្ឌលកុមារកំព្រាដែលពាក់ព័ន្ធ និង ត្រូវប្រគល់កំណត់ហេតុចម្លងដែលមានសេចក្ដីបញ្ជាក់នៅលើកំណត់ហេតុនោះ ទៅឱ្យឪពុកម្ដាយ ឬ ឪពុក ឬ ម្ដាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជននោះ ។

**មាត្រា ១៨.-**

ដំណើរការសុំកូនអាចប្រព្រឹត្តទៅបាន លុះត្រាតែផុតកំណត់ពេល ៩០ (កៅសិប) ថ្ងៃ នៃថ្ងៃធ្វើការ ក្រោយការយល់ព្រមរបស់ឪពុកម្ដាយ ឬ ឪពុក ឬ ម្ដាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ ។

**មាត្រា ១៩.-**

ករណីឪពុកម្ដាយ ឬ ឪពុក ឬ ម្ដាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារបដិសេធការយល់ព្រម ឬ បញ្ឈប់ការយល់ព្រមរបស់ខ្លួន ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច អាចប្ដឹងសុំឱ្យតុលាការប្រកាសដកហូតអំណាចមេបាពីឪពុកម្ដាយ ឬ ឪពុក ឬ ម្ដាយ ឬ បញ្ឈប់ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ និងជ្រើសតាំងអ្នកអាណាព្យាបាលថ្មីសម្រាប់អនីតិជនរបស់កុមារ ក្នុងករណីពិនិត្យឃើញថា ការបដិសេធ ឬ ការបញ្ឈប់ការយល់ព្រមនេះ ធ្វើឱ្យ បាត់បង់ផលប្រយោជន៍របស់កុមារ ឬ បណ្ដាលឱ្យប៉ះពាល់ដល់សុខភាព សុវត្ថិភាព ឬ សីលធម៌របស់កុមារ ។ ពាក្យបណ្ដឹងទៅតុលាការត្រូវធ្វើក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃ នៃថ្ងៃធ្វើការ ក្រោយពីឪពុកម្ដាយ ឬ ឪពុក ឬ ម្ដាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ បដិសេធ ឬ បញ្ឈប់ការយល់ព្រមរបស់ខ្លួន ។

**មាត្រា ២០.-**

ឪពុកម្ដាយ ឬ ឪពុក ឬ ម្ដាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ ដែលយល់ថា ការយល់ព្រមរបស់ខ្លួនបានមកពីការបង្ហាញឆន្ទៈដែលមានវិការៈ ឪពុកម្ដាយ ឬ ឪពុក ឬ ម្ដាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ អាចបញ្ឈប់ ឬ លុបចោលការយល់ព្រមរបស់ខ្លួនបាន រហូតដល់មុនដីកាសម្រេចរបស់តុលាការលើសុំកូនចូល

## ផ្នែកទី ៣

## អ្នកសុំ

**មាត្រា ២១.-**

អ្នកសុំដែលអាចអនុញ្ញាតឱ្យសុំកុមារយកទៅចិញ្ចឹមជាកូនបាន ត្រូវឆ្លើយតបនឹងលក្ខខណ្ឌ ដូចតទៅ :

១-អ្នកសុំជាប្តីប្រពន្ធត្រូវមានអាយុចាប់ពី ៣០(សាមសិប)ឆ្នាំ និង មានអាយុលើសកូនសុំយ៉ាងតិច ២២(ម្ភៃពីរ)ឆ្នាំ និង យ៉ាងច្រើនបំផុត ៤៥(សែសិបប្រាំ)ឆ្នាំ គិតត្រឹមកាលបរិច្ឆេទដាក់ពាក្យសុំកូន ។

២-ក្នុងករណីដែលអ្នកសុំមិនបានបំពេញតាមចំណុច ១ ខាងលើ ហើយក្នុងករណីសុំកូនឆ្លើយតបនឹងឧត្តមប្រយោជន៍របស់កុមារ សុំកូនអាចអនុញ្ញាតឱ្យ បាន ក្នុងស្ថានភាពដូចតទៅ :

ក-អ្នកសុំមានដើមកំណើតសញ្ជាតិខ្មែរ សុំកុមារដែលជាសាច់ញាតិរបស់ខ្លួន ឬ

ខ-អ្នកសុំជាសហព័ទ្ធដែលសុំកូននៃសហព័ទ្ធម្ខាងទៀត ឬ

គ-អ្នកសុំ សុំកុមារដែលត្រូវការការថែទាំពិសេស ឬ ស្ថានភាពផ្សេងទៀត ដែលបម្រើឧត្តមប្រយោជន៍របស់កុមារ ។

៣-ក្នុងករណីអ្នកសុំមានប្តី ឬ ប្រពន្ធ ការសុំកូនត្រូវធ្វើដោយសហព័ទ្ធទាំងពីររួមគ្នា លើកលែងតែករណីដែលសហព័ទ្ធណាម្ខាង សុំកូនបង្កើតនៃសហព័ទ្ធម្ខាងទៀត ។

៤-ច្បាប់ជាតិរបស់អ្នកសុំនីមួយៗ និង ច្បាប់ប្រទេសនៃលំនៅឋានអចិន្ត្រៃយ៍របស់អ្នកសុំបានទទួលស្គាល់ និង អនុញ្ញាតនូវបុត្តភាពនៃសុំកូនពេញលេញ ។

៥-ប្រទេសនៃសញ្ជាតិ ឬ ប្រទេសលំនៅឋានអចិន្ត្រៃយ៍នៃអ្នកសុំ ត្រូវតែជាប្រទេសដែលមានទំនាក់ទំនងការទូតជាមួយព្រះរាជាណាចក្រកម្ពុជា ។

៦-អ្នកសុំត្រូវមានលក្ខណសម្បត្តិ និង លក្ខខណ្ឌជាសារវន្តនានាសម្រាប់សុំកូនស្របទៅតាមច្បាប់ប្រទេសលំនៅឋានអចិន្ត្រៃយ៍របស់ខ្លួន ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

ព្រះបរមរាជវាំង

4/35

Kol

៧-អ្នកសុំត្រូវតែជាជនពុំធ្លាប់ត្រូវបានផ្តន្ទាទោស ឬ កំពុងត្រូវបានប្តឹងអំពីកំហុសទាក់ទងទៅនឹងកិរិយាមារយាទ ឬ ការប្រព្រឹត្តបទល្មើសឧក្រិដ្ឋ ឬ មជ្ឈិមណាមួយនៅក្នុងប្រទេសនៃសញ្ជាតិរបស់ខ្លួន ឬ ប្រទេសលំនៅឋានអចិន្ត្រៃយ៍ ឬ ក្នុងប្រទេសណាមួយដែលខ្លួនបានស្នាក់នៅចុងក្រោយ ។

៨-អ្នកសុំត្រូវតែជាអ្នកមានសមត្ថភាពផ្តល់ការថែទាំសមស្រប និង ការគាំទ្រចាំបាច់ដល់កូនសុំ ។

៩-អ្នកសុំត្រូវបានអនុញ្ញាតឱ្យសុំកូនបាន លុះត្រាតែអ្នកសុំកូនគ្មានកូន ឬ មានកូនតែម្នាក់នៅក្នុងបន្ទុក ។ អ្នកសុំអាចសុំកូនបានតែម្នាក់ប៉ុណ្ណោះ លើកលែងតែកុមារដែលមានបងប្អូនបង្កើតអាចអនុញ្ញាតឱ្យសុំច្រើននាក់បាន ។

## ជំពូកទី ៥
## នីតិវិធីសុំកូន
### ផ្នែកទី ១
### នីតិវិធីរដ្ឋបាល

**មាត្រា ២២.-**

រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវរៀបចំសំណុំឯកសារផ្ទាល់ខ្លួនរបស់កុមារម្នាក់ៗដែលមានលក្ខណសម្បត្តិសម្រាប់សុំកូនអន្តរប្រទេសរួមមាន ព័ត៌មានចាំបាច់អំពីអត្តសញ្ញាណរបស់កុមារ ភាពអាចសុំជាកូនចិញ្ចឹម សាវតារជាតិរបស់កុមារ បរិយាកាសសង្គមរបស់កុមារ ប្រវត្តិគ្រួសាររបស់កុមារ ប្រវត្តិសុខភាពរបស់កុមារ និង ប្រវត្តិសុខភាពគ្រួសាររបស់កុមារ និង សេចក្តីត្រូវការជាពិសេសណាមួយរបស់កុមារ ។

ក្នុងករណីកុមារត្រូវបានបោះបង់ចោល រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវធានាថា ការខិតខំប្រឹងប្រែងដើម្បីស្វះស្វែងរកឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ សាច់ញាតិ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារត្រូវបានធ្វើរួចហើយ ។

រដ្ឋបាលសុំកូនអន្តរប្រទេសក៏ត្រូវធានាផងដែរថា រាល់ការយល់ព្រមចាំបាច់ទាំងឡាយត្រូវបានធ្វើឡើងស្របទៅតាមបទប្បញ្ញត្តិនានានៃច្បាប់នេះ ។

សំណុំឯកសារផ្ទាល់ខ្លួនរបស់កុមារ រាប់បញ្ចូលទាំងភស្តុតាងបង្ហាញពីការយល់ព្រម និង/ឬ ការខិតខំប្រឹងប្រែងដើម្បីស្វះស្វែងរកឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ សាច់ញាតិ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារផងដែរ ។

**មាត្រា ២៣.-**

អ្នកសុំត្រូវដាក់ពាក្យសុំកូនទៅអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសនៃព្រះរាជាណាចក្រកម្ពុជាដោយភ្ជាប់មកជាមួយនូវឯកសាររួមមាន :

១-ភស្តុតាងដែលបញ្ជាក់ថា អាជ្ញាធរកណ្តាលនៃប្រទេសដើមរបស់ខ្លួន ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬ ទីភ្នាក់ងារសុំកូនអន្តរប្រទេសនៃប្រទេសលំនៅឋានអចិន្ត្រៃយ៍ចាត់ទុកថា អ្នកសុំមានលក្ខណសម្បត្តិ និង មានភាពសមស្រប សម្រាប់សុំកូនដោយផ្អែកលើការវាយតំលៃលើជីវប្រវត្តិផ្ទាល់ខ្លួន ប្រវត្តិគ្រួសារ ប្រវត្តិសុខភាព បរិយាកាសគ្រួសារ បរិយាកាសសង្គម មូលហេតុសុំកូន និងលទ្ធភាពនៃការទទួលបន្ទុកថែរក្សាចំពោះសុំកូនអន្តរប្រទេស ។

២-ព័ត៌មានចាំបាច់ទាក់ទងនឹងការឆ្លើយតបទៅនឹងលក្ខខណ្ឌនានាដែលមានចែងក្នុងមាត្រា ២១ នៃច្បាប់នេះ ។

៣-ព័ត៌មានទាក់ទងនឹងអត្តសញ្ញាណរបស់អ្នកសុំ ដែលក្នុងនោះរួមមានឯកសារទាក់ទងនឹងអត្រានុកូលដ្ឋាន ។

៤-ព័ត៌មានទាក់ទងនឹងលក្ខណសម្បត្តិផ្សេងៗរបស់កុមារ ដែលអ្នកសុំអាចនឹងមានលក្ខណសម្បត្តិថែទាំបាន ។

៥-ភស្តុតាងទទួលបានពីអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសទទួលដែលបញ្ជាក់ថា នៅពេលពាក្យសុំកូនរបស់ខ្លួនត្រូវបានយល់ព្រមហើយ កូនសុំនោះត្រូវបានអនុញ្ញាតឱ្យចូលទៅរស់នៅជាអចិន្ត្រៃយ៍ក្នុងប្រទេសទទួល ។

ឯកសារទាំងអស់ ត្រូវបញ្ជាក់ដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសលំនៅឋានអចិន្ត្រៃយ៍របស់អ្នកសុំ ។

ឯកសារច្បាប់ដើមទាំងអស់ត្រូវភ្ជាប់មកជាមួយនូវការបកប្រែជាភាសាអង់គ្លេស ឬ ភាសាបារាំងដែលមានការបញ្ជាក់ត្រឹមត្រូវ ។

18/35 Kol

**មាត្រា ២៤.-**

ពាក្យសុំដូចមានចែងក្នុងមាត្រា ២៣ នៃច្បាប់នេះ ត្រូវបញ្ជូនមកក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ តាមរយៈអាជ្ញាធរកណ្តាល ស្ថានទូត ឬ ស្ថានតំណាងនៃប្រទេសទទួលប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ដែលបានបញ្ជាក់ពីភាពត្រឹមត្រូវនៃឯកសារទាំងនោះ ។ ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ត្រូវពិនិត្យផ្តល់យោបល់ និង ត្រូវបញ្ជូនសំណុំឯកសារសុំកូនអន្តរប្រទេស ទៅក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ គិតពីថ្ងៃបានទទួលពាក្យសុំ ។ ក្នុងរយៈពេលយ៉ាងយូរបំផុត ១៥ (ដប់ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការ គិតពីថ្ងៃបានទទួលពាក្យសុំពីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវឆ្លើយតបជាលាយលក្ខណ៍អក្សរទៅអ្នកសុំ តាមរយៈអាជ្ញាធរកណ្តាលនៃប្រទេសដើមរបស់អ្នកសុំ ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬ តាមរយៈទីភ្នាក់ងារសុំកូនអន្តរប្រទេសនៃប្រទេសលំនៅឋានអចិន្ត្រៃយ៍ ដោយបញ្ជាក់ថា ខ្លួនបានទទួលពាក្យសុំកូន ។

**មាត្រា ២៥.-**

អ្នកសុំត្រូវបង់ប្រាក់ចំណាយ សោហ៊ុយ និងវិភាគទាននានា សម្រាប់ជួយឧបត្ថម្ភដល់ជីវីសនានានៃការថែទាំជិនួស និង ការជួយឧបត្ថម្ភទូទៅដល់មណ្ឌលកុមារកំព្រារបស់រដ្ឋទូទាំងប្រទេស និង កម្រៃសេវាចាំបាច់ផ្សេងៗទៀតទាក់ទងនឹងសុំកូនអន្តរប្រទេសដែលនឹងកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។ ក្រៅពីនេះ មិនត្រូវយកថ្លៃសោហ៊ុយសុំកូនពីអ្នកសុំកូន ឬ ទីភ្នាក់ងាររបស់អ្នកសុំកូន ។ មិនអនុញ្ញាតឱ្យអ្នកសុំកូន ឬ ទីភ្នាក់ងាររបស់អ្នកសុំកូនបង់ថ្លៃសោហ៊ុយសុំកូនទៅតាមកុមារម្នាក់ៗ ឬ ទៅតាមសោហ៊ុយសុំកូនមួយៗដែលនឹងត្រូវបញ្ជូនទៅឱ្យមណ្ឌលកុមារកំព្រាណាមួយ ឬ មិនអនុញ្ញាតឱ្យអ្នកសុំកូន ឬ ទីភ្នាក់ងាររបស់អ្នកសុំកូនធ្វើការផ្តល់សោហ៊ុយ អំណោយ ឬ ការទូទាត់ ទោះក្នុងរូបភាពណាក៏ដោយឱ្យទៅមណ្ឌលកុមារកំព្រា ដែលកុមារនៅទីនោះត្រូវបានសុំយកទៅចិញ្ចឹម ឬ ទៅឱ្យបុគ្គលិក នាយក ឬ សមាជិកនៃគណៈគ្រប់គ្រងទោះជាដោយផ្ទាល់ ឬ ដោយប្រយោលក្តី ។

**មាត្រា ២៦.-**

រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវពិនិត្យសំណុំលិខិតសុំកូនក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីថ្ងៃដែលក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចទទួលសំណុំលិខិតសុំកូន ដូចមានចែងក្នុងមាត្រា ២៣ នៃច្បាប់នេះ ។ ក្នុងករណីសំណុំលិខិតមានលក្ខណៈគ្រប់គ្រាន់ហើយ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវបញ្ជាក់ថា អ្នកសុំបានបំពេញលក្ខខណ្ឌត្រឹមត្រូវតាមច្បាប់នេះហើយ ។

ក្នុងករណីដែលសំណុំលិខិតដាក់ជូនរដ្ឋបាលសុំកូនអន្តរប្រទេស មិនទាន់គ្រប់គ្រាន់ ឬ មិនទាន់ត្រឹមត្រូវ រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវជូនដំណឹងទៅអ្នកសុំជាលាយលក្ខណ៍អក្សរអំពីឯកសារដែលនៅខ្វះ ឬ មិនទាន់ត្រឹមត្រូវ តាមរយៈអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬ ទីភ្នាក់ងារសុំកូនអន្តរប្រទេសដែលបានទទួលការអនុញ្ញាតនៃប្រទេសទទួល ។ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវពិនិត្យសំណុំលិខិតសុំកូនក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលឯកសារដែលនៅខ្វះ ឬ កែតម្រូវរួច។

ក្នុងករណីអ្នកសុំខកខានមិនបានផ្តល់ឯកសារដែលនៅខ្វះ ឬ មិនទាន់ត្រឹមត្រូវក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃ នៃថ្ងៃធ្វើការ គិតពីថ្ងៃរដ្ឋបាលសុំកូនអន្តរប្រទេសបានជូនដំណឹងអំពីឯកសារដែលមិនទាន់គ្រប់គ្រាន់ ឬ មិនទាន់ត្រឹមត្រូវ នោះពាក្យសុំកូនអន្តរប្រទេសត្រូវទុកជាមោឃៈ ។

ក្នុងករណីបដិសេធពាក្យសុំ ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ត្រូវមានបញ្ជាក់អំពីមូលហេតុជាលាយលក្ខណ៍អក្សរ ។

**មាត្រា ២៧.-**

ក្នុងករណីសំណុំលិខិតមានលក្ខណៈគ្រប់គ្រាន់ និង ត្រឹមត្រូវ ហើយអ្នកសុំបានបំពេញទៅតាមលក្ខខណ្ឌនៃច្បាប់នេះ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវពិនិត្យពិចារណាទៅលើសំណុំឯកសាររបស់កុមារទាំងឡាយដែលមានលក្ខណសម្បត្តិសម្រាប់សុំកូនអន្តរប្រទេសបាន និង ត្រូវផ្តល់អំពីលក្ខណសម្បត្តិរបស់អ្នកសុំណាដែលត្រូវគ្នាល្អបំផុតនឹងលក្ខណសម្បត្តិរបស់កុមារ ។

ក្នុងការផ្គូផ្គងដោយគិតគូរដល់ឧត្តមប្រយោជន៍របស់កុមារ រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវពិចារណាឱ្យបានសមស្របទៅលើអត្ថប្រយោជន៍នៃការបន្តឱ្យមានការបីបាច់ ថែរក្សាកុមារ ដូចពេលកន្លងមក ព្រមទាំងពិចារណាទៅលើសាវតារសង្គម ជាតិពន្ធុ សាសនា និងវប្បធម៌របស់កុមារ ។

**មាត្រា ២៨.-**

រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវផ្ញើសំណុំឯកសាររបស់កុមារដែលត្រូវបានផ្គូផ្គង រួមទាំងភស្តុតាងដែលបង្ហាញថា រាល់ការយល់ព្រមចាំបាច់នានា ត្រូវបានទទួលរួចហើយ និងមូលហេតុដែលខ្លួនកំណត់ទុកដាក់កុមារជាមួយអ្នកសុំនោះទៅអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ច ទទួលបន្ទុកសុំកូនអន្តរប្រទេស ឬ ទីភ្នាក់ងារសុំកូនអន្តរប្រទេសនៃប្រទេសទទួល ដើម្បីពិនិត្យនិងបញ្ជូនទៅអ្នកសុំដោយមិនចាំបាច់ជូនដំណឹងអំពីអត្តសញ្ញាណឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារឡើយ លើកលែងតែករណីសុំកូនដោយសាច់ញាតិ ។

**មាត្រា ២៩.-**

អ្នកសុំត្រូវឆ្លើយតបទៅរដ្ឋបាលសុំកូនអន្តរប្រទេសជាលាយលក្ខណ៍អក្សរ អំពីការយល់ព្រមសុំកុមារ ដែលរដ្ឋបាលសុំកូនអន្តរប្រទេសបានផ្គូផ្គងឱ្យតាមរយៈអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬ ទីភ្នាក់ងារសុំកូនអន្តរប្រទេសនៃប្រទេសទទួល ។

ក្នុងករណីអ្នកសុំមិនបានឆ្លើយតបមករដ្ឋបាលសុំកូនអន្តរប្រទេសក្នុងរយៈពេល ៦០ (ហុបសិប) ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃដែលរដ្ឋបាលសុំកូនអន្តរប្រទេសបានផ្ញើសំណុំឯកសាររបស់កុមារ រដ្ឋបាលសុំកូនអន្តរប្រទេសអាចចាត់ទុកថា អ្នកសុំបានបញ្ឈប់ពាក្យសុំរបស់ខ្លួន ហើយរដ្ឋបាលសុំកូនអន្តរប្រទេសអាចផ្គូផ្គងកុមារនោះឱ្យទៅអ្នកសុំផ្សេងទៀតបាន ។ ប្រាក់ចំណាយ សោហ៊ុយ និង វិភាគទានទាក់ទងនឹងការដាក់ពាក្យសុំមិនត្រូវបានប្រគល់ជូនវិញឡើយ ។

ក្នុងករណីអ្នកសុំបានឆ្លើយតបថាមិនទទួលយកកុមារដែលបានផ្តល់ឱ្យខ្លួននៅលើកទីមួយទេ អ្នកសុំនោះអាចស្នើសុំឱ្យរដ្ឋបាលសុំកូនអន្តរប្រទេសផ្តល់កុមារជាលើកទីពីរបាន ។ ការផ្តល់នេះមិនត្រូវអនុញ្ញាតឱ្យធ្វើជាលើកទីបីឡើយ ។

ចំពោះអ្នកសុំដែលមិនបានឆ្លើយតបក្នុងរយៈពេលកំណត់ដូចមានចែងក្នុងកថាខណ្ឌទី ២ នៃមាត្រានេះ អ្នកសុំនោះអាចដាក់ពាក្យសុំកូនសាជាថ្មីស្របតាមនីតិវិធីនៃច្បាប់នេះ ។ ក្នុងការសម្រេចអំពីការសុំឱ្យមានការផ្តល់សាជាថ្មី ឬ ការទទួលពាក្យសុំកូនសាជាថ្មី រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវពិចារណាអំពីមូលហេតុដែលអ្នកសុំខកខានមិនបានឆ្លើយតប ឬ ឆ្លើយតបថា មិនមានបំណងសុំកុមារដែលបានផ្តល់ពីលើកមុននាពេលកន្លងមក ។

**មាត្រា ៣០.-**

បន្ទាប់ពីអ្នកសុំ បានបញ្ជាក់ការយល់ព្រមរបស់ខ្លួនស្របតាមបទប្បញ្ញត្តិក្នុងមាត្រា ២៩ នៃច្បាប់នេះ ហើយអាជ្ញាធរកណ្តាលនៃប្រទេសទទួល បានយល់ព្រមលើការសម្រេចនេះ រដ្ឋបាលសុំកូនអន្តរប្រទេសតាមរយៈអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬ ទីភ្នាក់ងារសុំកូនអន្តរប្រទេសនៃប្រទេសទទួល ត្រូវរៀបចំឱ្យមានការជួបគ្នារវាងអ្នកសុំ និង កុមារដែលត្រូវបានផ្តល់រួចហើយ ។

ការជួបគ្នានេះត្រូវប្រព្រឹត្តទៅតាមកាលបរិច្ឆេទមួយសមស្របសម្រាប់អ្នកសុំ និង រដ្ឋបាលសុំកូនអន្តរប្រទេស និង ត្រូវមានវត្តមានមន្ត្រីសង្គមកិច្ចមានសមត្ថកិច្ចមួយរូបផង ។ ការជួបគ្នានេះ ត្រូវធ្វើក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីកាលបរិច្ឆេទទទួលការយល់ព្រមពីអ្នកសុំ ។

មុនការជួបគ្នារវាងអ្នកសុំ និង កុមារ រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវធ្វើសម្ភាសន៍អ្នកសុំ និង ធានាថា អ្នកសុំ និង កុមារត្រូវបានរៀបចំខ្លួនជាស្រេចតាមរយៈការពិគ្រោះយោបល់ ការផ្លាស់ប្តូរព័ត៌មាន ការផ្លាស់ប្តូររូបថត និងវិធានការចាំបាច់ផ្សេងៗទៀត ដើម្បីការជួបគ្នានេះ ។

ករណីមានសហព័ទ្ធ បើសហព័ទ្ធណាម្ខាងមិនអាចមកបាន សហព័ទ្ធនោះត្រូវធ្វើលិខិតប្រគល់សិទ្ធិឱ្យទៅសហព័ទ្ធម្ខាងទៀត ធ្វើជាអ្នកតំណាងរបស់ខ្លួន ដើម្បីធ្វើសកម្មភាពក្នុងការសុំកូននោះ ។ លិខិតប្រគល់សិទ្ធិត្រូវមានការបញ្ជាក់ពីអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ចរបស់ប្រទេសទទួល ។

ក្នុងករណីអ្នកសុំមិនមកក្នុងរយៈពេលដូចបានកំណត់ក្នុងកថាខណ្ឌទី ២ ខាងលើ ដោយគ្មានមូលហេតុត្រឹមត្រូវ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវចាត់ទុកថា អ្នកសុំបានបញ្ឈប់ពាក្យសុំរបស់ខ្លួន ។

រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវសាកសួរយោបល់របស់កុមារដែលអាចដឹងខុសត្រូវបាន ព្រមទាំងប្រាប់កុមារឱ្យបានដឹងអំពីអានុភាពដែលកើតចេញពីសុំកូននេះ ហើយត្រូវស្តាប់កុមារបញ្ចេញមតិយោបល់របស់ខ្លួន ដោយគ្មានវត្តមានរបស់ភាគីផ្សេងទៀតឡើយ ។ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវយល់ដឹងឱ្យបានច្បាស់ អំពីទស្សនៈកុមារលើរាល់បញ្ហាដែលពាក់ព័ន្ធដល់សុំកូន ក្នុងនោះមានជាអាទិ៍ ការជ្រើសរើសអ្នកសុំ ហើយមតិយោបល់របស់កុមារត្រូវយកទៅគិតគូរពិចារណាដោយផ្អែកទៅតាមវ័យ និង កម្រិតយល់ដឹងរបស់កុមារ ។ សំអាងស្តីពីការយល់ព្រមរបស់កុមារត្រូវធ្វើជាលាយលក្ខណ៍អក្សរ ។

រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវធ្វើកំណត់ហេតុជាលាយលក្ខណ៍អក្សរ អំពីការសម្ភាសន៍ និង ការជួបគ្នាខាងលើនេះ ។

**មាត្រា ៣១.–**

បទប្បញ្ញត្តិ ដែលមានចែងក្នុងជំពូកនេះត្រូវយកមកអនុវត្តផងដែរចំពោះសុំកូនដោយសាច់ញាតិ ។

**មាត្រា ៣២.–**

ក្នុងករណីរដ្ឋបាលសុំកូនអន្តរប្រទេសពិនិត្យឃើញថា អ្នកសុំ និង កុមារបំពេញបាននូវលក្ខណៈវិនិច្ឆ័យ និង លក្ខខណ្ឌសម្រាប់សុំកូនអន្តរប្រទេស ហើយសុំកូននេះពិតជាបានឆ្លើយតបទៅនឹងឧត្តមប្រយោជន៍របស់កុមារ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវផ្តល់មតិយោបល់ជាវិជ្ជមានក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីការជួបគ្នារវាងអ្នកសុំ និង កុមារ ។

រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវដាក់សំណុំលិខិតទាំងនេះ ជូនរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ដើម្បីសុំការពិនិត្យ និង ផ្តល់អនុសាសន៍លើដំណើរការសុំកូន ។

**មាត្រា ៣៣.–**

ក្រោយពីទទួលអនុសាសន៍លើដំណើរការសុំកូនពីរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច អ្នកសុំត្រូវសហការជាមួយអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬ ទីភ្នាក់ងារសុំកូនអន្តរប្រទេសនៃប្រទេសទទួល ដាក់ពាក្យសុំកូនដែលបានផ្គូផ្គងរួច តាមរយៈរដ្ឋបាលសុំកូនអន្តរប្រទេសទៅសាលាដំបូងរាជធានីភ្នំពេញដើម្បីសុំដីកាសម្រេចសុំកូន ។ រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវបញ្ជូនពាក្យសុំកូនទៅសាលាដំបូងរាជធានីភ្នំពេញដោយភ្ជាប់មកជាមួយនូវសំណុំឯកសាររបស់កុមារ និង អ្នកសុំ ព្រមទាំងអនុសាសន៍របស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃនៃថ្ងៃធ្វើការ គិតពីកាលបរិច្ឆេទទទួលពាក្យសុំ ។ ឯកសារចាំបាច់ទាំងអស់ត្រូវបកប្រែជាភាសាខ្មែរ និង មានការបញ្ជាក់ពីរដ្ឋបាលសុំកូនអន្តរប្រទេស ។

ក្នុងករណីអ្នកសុំមិនបានដាក់ពាក្យសុំក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីទទួលបានអនុសាសន៍របស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ត្រូវចាត់ទុកថាអ្នកសុំនោះបានបញ្ឈប់ពាក្យសុំរបស់ខ្លួន ។

## ផ្នែកទី ២
## នីតិវិធីតុលាការ

**មាត្រា ៣៤.–**

សាលាដំបូងរាជធានីភ្នំពេញ មានយុត្តាធិការលើរឿងក្តីសុំកូនអន្តរប្រទេស ។

តុលាការដែលមានយុត្តាធិការលើរឿងក្តីសុំកូនអន្តរប្រទេស ត្រូវយកបទប្បញ្ញត្តិស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណី ដែលមិនមែនជាបណ្តឹងមកអនុវត្តចំពោះនីតិវិធីតុលាការទាក់ទងនឹងសុំកូនអន្តរប្រទេស លើកលែងតែមានបទប្បញ្ញត្តិពិសេសដូចមានចែងនៅក្នុងច្បាប់នេះ ។

**មាត្រា ៣៥.–**

អ្នកសុំត្រូវបង់ប្រាក់សរុបចំនួន ១.០០០.០០០ (មួយលាន) រៀល ដើម្បីទ្រទ្រង់សោហ៊ុយការដាក់ពាក្យសុំ ការពិនិត្យភស្តុតាង ការចេញដីកាសម្រេច ការបញ្ជូនឯកសារ ការផ្សព្វផ្សាយសេចក្តីជូនដំណឹង ការស្រាវជ្រាវអង្គហេតុ និង សកម្មភាពខាងនីតិវិធីផ្សេងៗទៀត

ដែលទាក់ទងនឹងកិច្ចការសុំកូនអន្តរប្រទេស ។ តុលាការត្រូវបង្គាប់ឱ្យអ្នកសុំបង់ចំនួនទឹកប្រាក់នោះជាមុន ។ ក្នុងករណីដែលសោហ៊ុយចាំបាច់ដែលបានកំណត់ខាងលើនេះ លើសពី ១.០០០.០០០ (មួយលាន) រៀល តុលាការអាចកំណត់ចំនួនសោហ៊ុយបន្ថែម និង បង្គាប់ឱ្យអ្នកសុំបង់សោហ៊ុយបន្ថែមនោះជាមុន ។ ចំនួនទឹកប្រាក់នេះមិនអាចបង្វិលជូនវិញទេ ។

**មាត្រា ៣៦.-**

ជាគោលការណ៍ សំណុំឯកសារ និង របាយការណ៍ដែលដាក់ជូនតុលាការដោយក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ត្រូវសន្មតជាភស្តុតាងនៃអង្គហេតុពិតទាក់ទងនឹងលក្ខណសម្បត្តិ សុំកូនរបស់កុមារ និង ភាពសមស្របសម្រាប់សុំកូនរបស់អ្នកសុំលើកលែងតែមានភស្តុតាងផ្ទុយមកបញ្ជាក់ ។

ក្នុងករណីចាំបាច់ តុលាការអាចបង្គាប់ឱ្យអ្នកតំណាងរដ្ឋបាលសុំកូនអន្តរប្រទេសមកបំភ្លឺបន្ថែមអំពីលទ្ធផលនៃការស្រាវជ្រាវ និង អនុសាសន៍របស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ទាក់ទងនឹងករណីសុំកូនអន្តរប្រទេសរួមទាំងឯកសារ របាយការណ៍ និង ភស្តុតាងជាឯកសារពាក់ព័ន្ធដែលគាំទ្រលទ្ធផលនៃការស្រាវជ្រាវខាងលើ ។

**មាត្រា ៣៧.-**

តុលាការត្រូវពិនិត្យផ្ទៀងផ្ទាត់ថា :

ក- លក្ខណវិនិច្ឆ័យ ឬ លក្ខខណ្ឌទាំងអស់នៃសុំកូនអន្តរប្រទេសត្រូវបានបំពេញ ។

ខ- ការពិគ្រោះយោបល់ជាចាំបាច់នានាត្រូវបានធ្វើមុននឹងផ្តល់ការយល់ព្រម ។

គ- ការយល់ព្រមចាំបាច់នានាត្រូវបានផ្តល់ ដោយគោរពតាមខ្លឹមសារផ្នែកទី ២ ជំពូកទី ៤ នៃច្បាប់នេះ ។

ឃ- មានការពិចារណាត្រឹមត្រូវលើគ្រប់លទ្ធភាពក្នុងការទុកដាក់កុមារនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ង- អាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ច ឬ ទីភ្នាក់ងារសុំកូនអន្តរប្រទេសដែលបានទទួលការអនុញ្ញាតនៃប្រទេសទទួល យល់ព្រមលើការទុកដាក់កុមារ ។

ច- កុមារនឹងត្រូវបានអនុញ្ញាតឱ្យចូលទៅរស់នៅជាអចិន្ត្រៃយ៍នៅក្នុងប្រទេស

ឆ- សុំកូនអន្តរប្រទេសនេះពិតជាឧត្តមប្រយោជន៍របស់កុមារ ។

**មាត្រា ៣៨.-**

តុលាការសម្រេចសេចក្តីអំពីរឿងក្តីដែលទាក់ទងនឹងសុំកូនអន្តរប្រទេស ដោយពុំចាំបាច់ឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់ឡើយ ។

ក្នុងករណីមានភាពចាំបាច់ដាច់ខាតត្រូវបំភ្លឺអង្គហេតុពាក់ព័ន្ធ តុលាការអាចអញ្ជើញអ្នកសុំ ឬ អ្នកតំណាង ឬ អ្នកមានអំណាចមេបាម្ខាង ឬ ទាំងពីរ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ អ្នកតំណាងទីភ្នាក់ងារសុំកូនអន្តរប្រទេសពាក់ព័ន្ធ និងសាក្សីផ្សេងទៀត ដើម្បីផ្តល់ភស្តុតាងជាលាយលក្ខណ៍អក្សរ ឬ ដោយផ្ទាល់មាត់ទាក់ទងនឹងអត្ថិភាព ឬ នត្ថិភាពនៃអង្គហេតុ ។

**មាត្រា ៣៩.-**

តុលាការត្រូវលើកយកសំណុំរឿងសុំកូនអន្តរប្រទេសមកវិនិច្ឆ័យ និងចេញដីកាសម្រេចក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលពាក្យសុំកូន ។ តុលាការត្រូវបញ្ជូនដីកាសម្រេចនេះទៅអ្នកសុំ អ្នកតំណាងដែលច្បាប់បានកំណត់របស់កូនសុំ និងក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។

ដីកាសម្រេចនេះមិនត្រូវចូលជាស្ថាពរនៅមុនពេលផុតអំឡុងពេលសម្រាប់ការប្តឹងជំទាស់ ដែលបានកំណត់នៅក្នុងមាត្រា ៤០ នៃច្បាប់នេះ ។ ក្នុងករណីមានការប្តឹងជំទាស់ចំពោះដីកាសម្រេចនេះ ដីកាសម្រេចនេះមិនត្រូវចូលជាស្ថាពររហូតដល់ពេលមានដីកាសម្រេចអំពីបណ្តឹងជំទាស់នោះ ។

**មាត្រា ៤០.-**

បុគ្គលដែលមានសិទ្ធិ ឬ ផលប្រយោជន៍របស់ខ្លួនត្រូវបានបំពានដោយដីកាសម្រេចលើពាក្យសុំកូនអន្តរប្រទេស អាចប្តឹងជំទាស់ទៅសាលាឧទ្ធរណ៍ ចំពោះដីកាសម្រេចនោះបាន ។

ក្នុងករណីដែលបុគ្គលអាចប្តឹងជំទាស់ជាជនដែលត្រូវទទួលបានការជូនដំណឹងអំពីដីកាសម្រេចខាងលើ បណ្តឹងជំទាស់ត្រូវធ្វើឡើងក្នុងអំឡុងពេល ១៥ (ដប់ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ គិតពីថ្ងៃដែលខ្លួនទទួលបានការជូនដំណឹងអំពីដីកាសម្រេច ។

ក្នុងករណីដែលបុគ្គលអាចប្តឹងជំទាស់ មិនមែនជាជនដែលត្រូវទទួលបានការជូនដំណឹងអំពីដីកាសម្រេចខាងលើ បណ្តឹងជំទាស់ត្រូវធ្វើឡើងក្នុងអំឡុងពេល ១៥ (ដប់ប្រាំ)

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

26/35 Kol

ថ្ងៃនៃថ្ងៃធ្វើការ គិតពីថ្ងៃដែលអ្នកសុំបានទទួលការជូនដំណឹងអំពីដីកាសម្រេច ។

អំឡុងពេល ១៥ (ដប់ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ ដែលកំណត់ក្នុងកថាខណ្ឌទី ២ និង ទី ៣ ខាងលើមិនអាចពន្យារបានឡើយ ។

សាលាឧទ្ធរណ៍ត្រូវលើកយកពាក្យបណ្តឹងជំទាស់នោះមកវិនិច្ឆ័យ និង ចេញដីកាសម្រេចក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលពាក្យបណ្តឹងជំទាស់ ។

ដីកាសម្រេចរបស់សាលាឧទ្ធរណ៍លើបណ្តឹងជំទាស់មិនអាចប្តឹងជំទាស់ទៀតបានឡើយ ។

## ជំពូកទី ៦
## អានុភាពនៃស្មុំកូន

**មាត្រា ៤១.-**

ស្មុំកូនអន្តរប្រទេសត្រូវតែជាស្មុំកូនពេញលេញ ។ ស្មុំកូនអន្តរប្រទេសមានអានុភាពបង្កើតនូវទំនាក់ទំនងញាតិភាពរវាងឪពុកម្តាយ និង កូនជាអចិន្ត្រៃយ៍ ដោយផ្តល់ដល់កុមារនូវឋានៈ សិទ្ធិ និង កាតព្វកិច្ចដូចជាកូនបង្កើតរបស់ឪពុកម្តាយចិញ្ចឹម ហើយវាបញ្ចប់ញាតិភាពរវាងកុមារ និង ឪពុកម្តាយបង្កើតរបស់ខ្លួន ។

**មាត្រា ៤២.-**

អានុភាពផ្សេងទៀតនៃស្មុំកូនអន្តរប្រទេស ត្រូវគ្រប់គ្រងដោយច្បាប់ជាតិរបស់អ្នកសុំ ឬ ប្រសិនបើគ្មានច្បាប់រួមមួយទេ ត្រូវគ្រប់គ្រងដោយច្បាប់នៃប្រទេសលំនៅឋានអចិន្ត្រៃយ៍របស់អ្នកសុំ ។

## ជំពូកទី ៧
## ការជូនដំណឹងពីចំណាត់ការ និង នីតិវិធី
## បន្ទាប់ពីបញ្ចប់ដំណើរការស្មុំកូនអន្តរប្រទេស

**មាត្រា ៤៣.-**

រដ្ឋជាដៃគូស្មុំកូនអន្តរប្រទេស ត្រូវជូនដំណឹងអំពីការប្រព្រឹត្តទៅនៃនីតិវិធីស្មុំកូន វិធានការដែលអាជ្ញាធរមានសមត្ថកិច្ចបានចាត់ការ និង ការវិវត្តនៃការសុំកូននៅគ្រប់

ដំណាក់កាលរបស់នីតិវិធីសុំកូនឱ្យបានទៀងទាត់ ទៅអ្នកសុំតាមរយៈអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ច ឬ ទីភ្នាក់ងារសុំកូនអន្តរប្រទេសដែលបានទទួលការអនុញ្ញាត ។

**មាត្រា ៤៤.-**

ក្រោយពីដីកាសម្រេចរបស់តុលាការចូលជាស្ថាពរ ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ត្រូវជូនដំណឹងទៅក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ អំពីដីកាសម្រេចនេះ ។

នៅពេលដែលនីតិវិធីសុំកូនអន្តរប្រទេសត្រូវបានបញ្ចប់ ដោយអនុលោមទៅតាមអនុសញ្ញាក្រុងឡាអេ ស្តីពីការការពារកុមារ និង សហប្រតិបត្តិការ ទាក់ទងនឹងសុំកូនអន្តរប្រទេស ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ត្រូវចេញលិខិតបញ្ជាក់អនុលោមតាមមាត្រា ២៣ នៃអនុសញ្ញានេះ ។

រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវរៀបចំពិធីប្រគល់កុមារ និង លិខិតបញ្ជាក់ស្តីពីការប្រគល់កូនជាផ្លូវការទៅអ្នកសុំ ។ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវជួយសម្របសម្រួលជាមួយអាជ្ញាធរមានសមត្ថកិច្ច ក្នុងការរៀបចំ និង ផ្តល់នូវលិខិតឆ្លងដែន ទិដ្ឋាការ និង ឯកសារចាំបាច់នានា ដើម្បីឱ្យកុមារធ្វើដំណើរចូលទៅប្រទេសលំនៅឋានអចិន្ត្រៃយ៍របស់អ្នកសុំ ។

ការធ្វើដំណើររបស់កុមារទៅកាន់ប្រទេសទទួល ត្រូវអមដំណើរដោយអ្នកសុំ ។ រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវធានាថាការផ្ទេរកុមារទៅកាន់ប្រទេសទទួល ប្រព្រឹត្តទៅក្នុងកាលៈទេសៈមានសុវត្ថិភាព ដោយមានការគិតគូរដល់សេចក្តីត្រូវការនានារបស់កុមារ ។

**មាត្រា ៤៥.-**

រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវសម្របសម្រួលជាមួយអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬ ទីភ្នាក់ងារសុំកូនអន្តរប្រទេសនៃប្រទេសទទួល ដើម្បីផ្តល់ ឬ សម្របសម្រួលសេវាក្រោយសុំកូនសមស្របដល់កុមារ គ្រួសារចិញ្ចឹម និង គ្រួសារបង្កើតតាមការចាំបាច់ ។

ក្រោយពីកុមារត្រូវបានទទួលការអនុញ្ញាតឱ្យធ្វើជាកូន ឪពុកម្តាយចិញ្ចឹមត្រូវផ្តល់របាយការណ៍អំពីស្ថានភាពវិវឌ្ឍន៍របស់កុមារមករដ្ឋបាលសុំកូនអន្តរប្រទេសជារៀងរាល់ ៦ (ប្រាំមួយ) ខែម្តង ក្នុងរយៈពេល ៣ (បី) ឆ្នាំ បន្ទាប់មកត្រូវផ្តល់របាយការណ៍ ១ ឆ្នាំម្តង រហូតដល់កុមារអាយុ ១៨ ឆ្នាំ ។

ឪពុកម្តាយចិញ្ចឹមត្រូវផ្ញើរបាយការណ៍ជាលាយលក្ខណ៍អក្សរទៅរដ្ឋបាលសុំកូនអន្តរប្រទេសដោយផ្ទាល់ ឬ តាមរយៈអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬ ទីភ្នាក់ងារសុំកូនអន្តរប្រទេស ដែលបានទទួលការអនុញ្ញាតនៃប្រទេសទទួល ឬ ប្រទេសជាលំនៅឋានអចិន្ត្រៃយ៍របស់ខ្លួនទៅតាមស្ថានភាពសមស្រប ។

**មាត្រា ៤៦.-**

រដ្ឋបាលសុំកូនអន្តរប្រទេស និង សាលាដំបូងរាជធានីភ្នំពេញ ត្រូវរក្សាទុកសំណុំឯកសារសុំកូនអន្តរប្រទេសក្នុងរយៈពេល ៦០ (ហុកសិប) ឆ្នាំ គិតពីកាលបរិច្ឆេទដែលដីកាសម្រេចសុំកូនអន្តរប្រទេសនោះចូលជាស្ថាពរ ។

សំណុំឯកសារ និង កំណត់ហេតុទាំងអស់ទាក់ទងនឹងករណីសុំកូនអន្តរប្រទេសជាក់លាក់ណាមួយ ទោះជារក្សាទុកនៅតុលាការ រដ្ឋបាលសុំកូនអន្តរប្រទេស ទីភ្នាក់ងារសុំកូនអន្តរប្រទេស មណ្ឌលកុមារកំព្រា និង អ្នកជំនាញផ្សេងៗទៀតដែលពាក់ព័ន្ធនឹងនីតិវិធីសុំកូនអន្តរប្រទេសត្រូវរក្សាទុកជាការសម្ងាត់ ។ ក៏ប៉ុន្តែសំណុំឯកសារនិងកំណត់ហេតុ ឬ ព័ត៌មានទាំងឡាយដែលមាននៅក្នុងសំណុំឯកសារ និង កំណត់ហេតុទាំងនោះអាចនឹងត្រូវបញ្ចេញទៅតាមការស្នើសុំ ឬ ការបង្គាប់ជាលាយលក្ខណ៍អក្សររបស់អាជ្ញាធរមានសមត្ថកិច្ច នៅក្នុង ឬ ក្រៅព្រះរាជាណាចក្រកម្ពុជា ក្នុងករណីមានតម្រូវការទាក់ទងនឹងករណី ឬ នីតិវិធីតុលាការដែលកំពុងតែប្រព្រឹត្តទៅ ឬ កាលៈទេសៈពិសេសដទៃទៀត ។

ឪពុកម្តាយចិញ្ចឹមអាចដាក់ពាក្យសុំទៅក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ដើម្បីសុំច្បាប់ចម្លងនៃសំណុំលិខិត ដែលរួមមានអត្តសញ្ញាណរបស់ឪពុកម្តាយបង្កើតរបស់កូនសុំក្រោយពីដីកាសម្រេចសុំកូនរបស់តុលាការចូលជាស្ថាពរ ។ កូនសុំដែលដល់អាយុដឹងខុសត្រូវគ្រប់គ្រាន់អំពីផលវិបាកនៃការដឹងអត្តសញ្ញាណរបស់ខ្លួន អាចត្រូវបានអនុញ្ញាតឱ្យមើលសំណុំលិខិតរបស់ខ្លួនរួមទាំងអត្តសញ្ញាណរបស់ឪពុកម្តាយបង្កើតបាន ដោយធ្វើការស្នើសុំជាលាយលក្ខណ៍អក្សរមកអាជ្ញាធរកណ្តាលនៃព្រះរាជាណាចក្រកម្ពុជា ក្នុងករណីការមើលនេះជាឧត្តមប្រយោជន៍របស់កូនសុំ ។ កូនសុំដែលឈានចូលអាយុនីតិភាពមានសិទ្ធិមើលសំណុំឯកសារ និង កំណត់ហេតុទាក់ទងនឹងអត្តសញ្ញាណខ្លួន ។ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវធានាថា កូនសុំទទួលបានការពិគ្រោះយោបល់សមស្របមុននឹងមើលព័ត៌មាននៅក្នុងសំណុំលិខិតរបស់ខ្លួន ។

29/35

## ជំពូកទី ៨

## ការផ្តល់ការអនុញ្ញាតដល់ទីភ្នាក់ងារ

**មាត្រា ៤៧.-**

មានតែទីភ្នាក់ងារដែលបានទទួលការអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច នៃព្រះរាជាណាចក្រកម្ពុជា និង ពីស្ថាប័នមានសមត្ថកិច្ចនៃប្រទេសទទួល ស្របតាមមាត្រាជាបន្តបន្ទាប់ដូចខាងក្រោមប៉ុណ្ណោះ ដែលមានសិទ្ធិធ្វើប្រតិបត្តិការក្នុងនីតិវិធីសុំកូនអន្តរប្រទេស ។

ចំនួនទីភ្នាក់ងារមកពីប្រទេសទទួលនីមួយៗ ដែលអនុញ្ញាតឱ្យផ្តល់សេវានៅក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវកំណត់ដោយកិច្ចព្រមព្រៀងរួមគ្នាមួយរវាងក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច និង អាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសទទួល ។

**មាត្រា ៤៨.-**

ដើម្បីសុំការអនុញ្ញាតធ្វើប្រតិបត្តិការសុំកូនអន្តរប្រទេសពីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចនៃព្រះរាជាណាចក្រកម្ពុជា ទីភ្នាក់ងារត្រូវមានលក្ខណសម្បត្តិដូចតទៅ :

១- មានការអនុញ្ញាតពីស្ថាប័នមានសមត្ថកិច្ចនៃប្រទេសទទួល ។

២- មានទិសដៅមិនស្វែងរកផលចំណេញ និង បានបំពេញនូវលក្ខខណ្ឌដែលមានចែងក្នុងបទប្បញ្ញត្តិច្បាប់ទាក់ទងនឹងនីតិបុគ្គលមិនយកចំណេញ សមាគម ឬ អង្គការមិនមែនរដ្ឋាភិបាល ឬ បទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀតទាក់ទងនឹងលក្ខណៈនៃទីភ្នាក់ងារនោះ ។

៣- មានអ្នកដឹកនាំនិងមានបុគ្គលិកដែលមានសមត្ថភាពប្រកបដោយគុណធម៌ និង សីលធម៌ ព្រមទាំងបានទទួលការបណ្តុះបណ្តាល និង មានបទពិសោធន៍ធ្វើការងារក្នុងវិស័យសុំកូនអន្តរប្រទេស ។

ទីភ្នាក់ងារដែលធ្វើប្រតិបត្តិការក្នុងដំណើរការសុំកូនអន្តរប្រទេស នៅក្នុងព្រះរាជាណាចក្រកម្ពុជា មិនត្រូវបានអនុញ្ញាតឱ្យបើក ឬ យកមណ្ឌលកុមារកំព្រា ជាប្រភពដើម្បីផ្គត់ផ្គង់ទារក និង កុមារកំព្រា នៅក្នុងព្រះរាជាណាចក្រកម្ពុជាឡើយ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

Kol

**មាត្រា ៤៩.-**

ទីភ្នាក់ងារនីមួយៗត្រូវបានចុះបញ្ជីតាមបទប្បញ្ញត្តិច្បាប់ជាធរមាន របស់ព្រះរាជាណាចក្រកម្ពុជា ទាក់ទងនឹងនីតិបុគ្គលមិនយកចំណេញ សមាគម ឬ អង្គការមិនមែនរដ្ឋាភិបាល ឬ បទប្បញ្ញត្តិពាក់ព័ន្ធផ្សេងៗទៀត ទាក់ទងនឹងលក្ខណៈនៃទីភ្នាក់ងារនោះ មុនពេលដាក់ពាក្យសុំការអនុញ្ញាតធ្វើជាទីភ្នាក់ងារសុំកូនអន្តរប្រទេស ទៅក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច តាមរយៈរដ្ឋបាលសុំកូនអន្តរប្រទេស ។ ទីភ្នាក់ងារសុំកូនអន្តរប្រទេសត្រូវចុះកិច្ចសន្យាស្តីពីប្រតិបត្តិការសុំកូនអន្តរប្រទេស និង បំពេញបែបបទផ្សេងៗទៀត តាមការកំណត់របស់ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។

**មាត្រា ៥០.-**

ពាក្យសុំការអនុញ្ញាតធ្វើជាទីភ្នាក់ងារសុំកូនអន្តរប្រទេស នៅព្រះរាជាណាចក្រកម្ពុជា ដែលដាក់ជូនរដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវភ្ជាប់មកជាមួយនូវសំណុំឯកសារដូចខាងក្រោម :

១- ពាក្យសុំការអនុញ្ញាតដោយមានការយល់ព្រម និង ទទួលស្គាល់ពីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ។

២- ឯកសារសង្ខេបអំពីប្រវត្តិ និង សកម្មភាពរបស់ទីភ្នាក់ងារ ។

៣- ច្បាប់ចម្លងដែលមានបញ្ជាក់ត្រឹមត្រូវអំពីការអនុញ្ញាតឱ្យបើកទីភ្នាក់ងារពីប្រទេសទទួលរបស់ខ្លួន ចំពោះទីភ្នាក់ងារអន្តរជាតិ ។

៤- ច្បាប់ចម្លងលិខិតចុះបញ្ជីដែលមានបញ្ជាក់ត្រឹមត្រូវដូចមានចែងក្នុងមាត្រា ៤៩ នៃច្បាប់នេះ ។

៥- លក្ខន្តិកៈ និង បទបញ្ជាផ្ទៃក្នុងរបស់ទីភ្នាក់ងារ ។

៦- ជីវប្រវត្តិសង្ខេបនិងរូបថតរបស់សមាជិកក្រុមប្រឹក្សាភិបាល ឬ គណៈគ្រប់គ្រង ។

៧- ជីវប្រវត្តិសង្ខេបរបស់បុគ្គលដែលបានទទួលការអនុញ្ញាតឱ្យធ្វើជាអ្នកតំណាងទីភ្នាក់ងារចំពោះកិច្ចការសុំកូនអន្តរប្រទេស ។ អ្នកតំណាងទាំងនេះមិនត្រូវឱ្យលើសពីពីរនាក់ និងមិនមែនជានាយក នាយករង ឬ បុគ្គលិកនៃមណ្ឌលកុមារកំព្រាណាមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជាឡើយ ។

៨- ឯកសារភស្តុតាងនានាដែលបញ្ជាក់ថាអ្នកតំណាងដូចមានចែងក្នុងចំណុចទី ៧ ខាងលើ គ្មានជាប់ឈ្មោះក្នុងបញ្ជីថ្កោលទោសនៅប្រទេសដើមរបស់ខ្លួន និង នៅប្រទេសចុងក្រោយដែលខ្លួនរស់នៅ ក្នុងករណីប្រទេសខុសគ្នា ។

៩- កិច្ចព្រមព្រៀងទ្វេភាគីស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យសុំកូនអន្តរប្រទេស រវាងព្រះរាជាណាចក្រកម្ពុជា និង ប្រទេសរបស់ទីភ្នាក់ងារសុំកូនអន្តរប្រទេស ក្នុងករណីដែលប្រទេសនោះមិនមែនជារដ្ឋភាគីនៃអនុសញ្ញាក្រុងឡាអេ ស្តីពីការការពារកុមារ និង សហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេសទេ ។

១០- របាយការណ៍ហិរញ្ញវត្ថុដែលត្រូវបានធ្វើសវនកម្មឯករាជ្យ និង កិច្ចព្រមព្រៀងផ្តល់ជំនួយមនុស្សធម៌ ឬ ការជួយឧបត្ថម្ភដល់កុមារកំព្រានានា នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

១១- តម្រូវការផ្សេងៗទៀតដែលក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចយល់ថាចាំបាច់ ដើម្បីជាឧត្តមប្រយោជន៍របស់កុមារ ដូចមានចែងនៅក្នុងនីតិវិធីទាក់ទងនឹងការផ្តល់ការអនុញ្ញាត ។

ច្បាប់ចម្លងចំនួនមួយច្បាប់នៃពាក្យសុំ និង សំណុំលិខិតសុំការអនុញ្ញាតធ្វើជាទីភ្នាក់ងារ ត្រូវផ្ញើជូនស្ថានទូត ឬ ស្ថានតំណាងនៃប្រទេសទទួល ដែលទីភ្នាក់ងារធ្វើប្រតិបត្តិការនៅទីនោះ ។

**មាត្រា ៥១.-**

ក្នុងកំឡុងពេល ៦០ (ហុកសិប) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលពាក្យសុំការអនុញ្ញាតធ្វើជាទីភ្នាក់ងារសុំកូនអន្តរប្រទេស ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចត្រូវឆ្លើយតបជាលាយលក្ខណ៍អក្សរទៅទីភ្នាក់ងារវិញអំពីការសម្រេចជាផ្លូវការរបស់ខ្លួន ។ ក្នុងករណីមានការបដិសេធ ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ត្រូវបញ្ជាក់អំពីមូលហេតុឱ្យ បានច្បាស់លាស់ ។

**មាត្រា ៥២.-**

មានតែអ្នកតំណាងដែលមានឈ្មោះក្នុងសំណុំឯកសារពាក្យសុំការអនុញ្ញាតតែប៉ុណ្ណោះ ដែលមានសិទ្ធិធ្វើជាអ្នកតំណាងទីភ្នាក់ងារនៅក្នុងដំណើរការសុំកូនអន្តរប្រទេស ។ ក្នុងករណីអ្នកតំណាងដែលបានទទួលការអនុញ្ញាត ត្រូវជំនួសដោយអ្នកផ្សេងនោះ ទីភ្នាក់

ងារត្រូវដាក់ពាក្យសុំទៅក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ដើម្បីសុំការអនុញ្ញាតជាថ្មីឡើងវិញ។

**មាត្រា ៥៣.-**

ការអនុញ្ញាតឱ្យធ្វើប្រតិបត្តិការសុំកូនអន្តរប្រទេស ត្រូវផ្ដល់ឱ្យសម្រាប់រយៈពេល ២ (ពីរ) ឆ្នាំ ហើយអាចអនុញ្ញាតឱ្យបន្តទៀតបាន ដោយទីភ្នាក់ងារត្រូវដាក់ពាក្យសុំសាជាថ្មី និងត្រូវបំពេញតាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ៤៨ មាត្រា ៤៩ និង មាត្រា ៥០ នៃច្បាប់នេះ ដរាបណាសេវារបស់ទីភ្នាក់ងារសុំកូនអន្តរប្រទេស នៅតែចាំបាច់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ៩

## ទោសប្បញ្ញត្តិ

**មាត្រា ៥៤.-**

ដោយមិនទាន់គិតដល់ទោសប្បញ្ញត្តិដែលមានចែងនៅក្នុងច្បាប់ជាធរមាន ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច អាចព្យួរ ឬ ដកហូតការទទួលស្គាល់ ឬ បដិសេធការទទួលស្គាល់ ទីភ្នាក់ងារសុំកូនអន្តរប្រទេសសាជាថ្មី ប្រសិនបើមានភស្តុតាងបង្ហាញឱ្យឃើញថា ទីភ្នាក់ងារសុំកូនអន្តរប្រទេស ជាប់ពាក់ព័ន្ធនឹងអំពើណាមួយដូចតទៅ :

១- អំពើប្រព្រឹត្តក្នុងគោលដៅចង់បានកម្រៃ ញុះញង់ដោយផ្ទាល់ឱ្យឪពុកម្ដាយ ឬ ឪពុក ឬ ម្ដាយបោះបង់ទារកដែលកើតមកហើយ ឬ ដែលនឹងកើត ដើម្បីឱ្យប្រគល់កូនតាមរយៈសុំកូនអន្តរប្រទេស ។

២- អំពើប្រព្រឹត្តក្នុងគោលដៅចង់បានកម្រៃ ធ្វើជាអន្តរការីរវាងប្ដីប្រពន្ធដែលចង់សុំកូនយកមកចិញ្ចឹមតាមរយៈសុំកូនអន្តរប្រទេស និង ឪពុកម្ដាយ ឬឪពុក ឬ ម្ដាយដែលចង់បោះបង់កូនដែលកើតមកហើយ ឬ ដែលនឹងកើត ។

៣- អំពើប្រព្រឹត្តក្នុងគោលដៅចង់បានកម្រៃ ធ្វើជាអន្តរការីរវាងប្ដីប្រពន្ធដែលចង់សុំកូនយកមកចិញ្ចឹមតាមរយៈសុំកូនអន្តរប្រទេស និង ស្ត្រីម្នាក់យល់ព្រមពពោះដើម្បីនឹងប្រគល់កូននោះទៅឱ្យអ្នកសុំ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

37/35

៤- អំពើក្លែងបន្លំ ឬ សមគំនិតក្លែងបន្លំស្ថានភាពលំបាកបំផុត ដើម្បីទទួលបានការយល់ព្រមពីឪពុកម្ដាយបង្កើត ឬ ឪពុកបង្កើត ឬ ម្ដាយបង្កើត ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ ។

៥- អំពើរៀបចំឱ្យមានការយល់ព្រមរបស់ឪពុកម្ដាយ ឬ ឪពុក ឬ ម្ដាយ ឬ របស់អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារដោយការបង្ខិតបង្ខំ ការគំរាមកំហែង ការឆបោក ឬ ការបញ្ចុះបញ្ចូលតាមរយៈការផ្ដល់ ឬ សន្យាផ្ដល់ប្រាក់ រង្វាន់ សំណង ឬ ផលប្រយោជន៍ណាមួយ ។

៦- ការបញ្ចេញសំណុំឯកសារ និង កំណត់ហេតុទាំងអស់ ឬ មួយផ្នែកទាក់ទងនឹងករណីសុំកូនអន្តរប្រទេសជាក់លាក់ណាមួយ ដោយគ្មានការអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ឬ តុលាការមានសមត្ថកិច្ច ។

៧- ការបង្គាប់ ឬ ការទទួលដោយផ្ទាល់ ឬ ដោយប្រយោល នូវថ្នូរប្រាក់កាស ទំនិញ ឬ សេវា ដោះដូរនឹងការបម្រុងទុកកុមារណាមួយសម្រាប់សុំកូន ។

៨- ការផ្ដល់ប្រាក់កាស ទំនិញ ឬ សេវាទៅឱ្យមន្ត្រី ឬ អ្នកតំណាងណាមួយនៃរដ្ឋបាលសុំកូនអន្តរប្រទេស ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច អាជ្ញាធរកណ្ដាលទទួលខុសត្រូវកិច្ចការសុំកូនអន្តរប្រទេស ឬ មន្ត្រីពាក់ព័ន្ធផ្សេងទៀត ដើម្បីឱ្យផ្ដល់នូវសិទ្ធិជាអាទិភាពនៅក្នុងនីតិវិធីសុំកូនអន្តរប្រទេសដល់អ្នកសុំ ។

៩- ការផ្សាយពាណិជ្ជកម្ម ឬ ការបោះពុម្ពផ្សាយនូវអត្តសញ្ញាណ ឬ រូបថតរបស់កុមារណាមួយដែលជាកម្មវត្ថុសុំកូន ក្នុងគោលបំណងបញ្ចុះបញ្ចូលបុគ្គលណាមួយឱ្យដាក់ពាក្យសុំកូន ។

១០- ការតែងតាំង ឬ ចាត់តាំងអ្នកតំណាងណាមួយដោយមិនមានការឯកភាពពីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។

១១- ការចូលរួមក្នុងការរៀបចំការផ្គូផ្គង ឬ ការទាក់ទងគ្នារវាងអ្នកសុំ និង ឪពុកម្ដាយបង្កើត ឬ ឪពុកបង្កើត ឬ ម្ដាយបង្កើត ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារក្នុង គោលបំណងកំណត់ទុកជាមុននូវកុមារណាមួយដែលនឹងត្រូវសុំ ។

១២- ការរំលោភបំពានដល់បទប្បញ្ញត្តិនៃច្បាប់នេះ បទដ្ឋានអប្បបរមានៃការធ្វើជំនួញចំពោះកុមារ និង បទប្បញ្ញត្តិផ្សេងទៀតជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៥៥.-**

ទីភ្នាក់ងារដែលធ្វើប្រតិបត្តិការក្នុងដំណើរការសុំកូនអន្តរប្រទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយមិនអនុវត្តតាមកថាខណ្ឌទី ១ មាត្រា ៤៧ ឬ កថាខណ្ឌទី ២ មាត្រា ៤៨ នៃច្បាប់នេះ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។ ការដាក់ពិន័យអន្តរការណ៍ ជាសមត្ថកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។ ប្រាក់ពិន័យអន្តរការណ៍នេះត្រូវបង់ចូលទៅក្នុងមូលនិធិសម្រាប់ទ្រទ្រង់វិស័យសុខុមាលភាពកុមារ ។

ក្នុងករណីទីភ្នាក់ងារមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍នេះទេ ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចអាចបញ្ជូនសំណុំរឿងទៅតុលាការ ។

**មាត្រា ៥៦.-**

បទល្មើសពាក់ព័ន្ធទៅនឹងច្បាប់ស្តីពីសុំកូនអន្តរប្រទេស ត្រូវផ្តន្ទាទោសដោយយោងតាមច្បាប់ និង បទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ១០

## អវសានប្បញ្ញត្តិ

**មាត្រា ៥៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥៨.-**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៩

នស/រកម.០៩១២.០១៩

**ព្រះហស្តលេខា និងព្រះរាជលញ្ចករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី

ហត្ថលេខា

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

ហត្ថលេខា

អ៊ិត សំហេង

លេខៈ ១០៥៩ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
ឈួន សុភេន

# ព្រះរាជក្រឹត្យ

នស/រកត/១០០៩/១០៤៣

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

**ត្រាស់បង្គាប់**

- តែងតាំង **ទីប្រឹក្សា អមព្រះបរមរាជវាំង** ចំពោះ :

១- ឯកឧត្តម **អ៊ុនផេង ពុធចិសាល** ជា **ទីប្រឹក្សា អមព្រះបរមរាជវាំង** មានឋានៈស្មើ **រដ្ឋលេខាធិការ**

២- ឯកឧត្តម **សួ ស៊ីនួន** ជា **ទីប្រឹក្សា អមព្រះបរមរាជវាំង** មានឋានៈស្មើ **រដ្ឋលេខាធិការ**

៣- ឯកឧត្តម **ស៊ិន ឌីម** ជា **ទីប្រឹក្សា អមព្រះបរមរាជវាំង** មានឋានៈស្មើ **អនុរដ្ឋលេខាធិការ**

៤- លោកជំទាវ **គង់ បញ្ញា** ជា **ទីប្រឹក្សា អមព្រះបរមរាជវាំង** មានឋានៈស្មើ **អនុរដ្ឋលេខាធិការ**

- ប្រគល់ភារកិច្ចជូន **សម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីង្គារ គង់ សំអុល** ឧបនាយករដ្ឋមន្ត្រី និងជា រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង រៀបចំភារកិច្ចជូន ឯកឧត្តម និង លោកជំទាវទាំង ០៤ រូប នេះ ។

នរោត្តម សីហមុនី (ហត្ថលេខា)

**នរោត្តម សីហមុនី**

៣៧. ០៩១០. ១០៦៤

**បានឡូវចាប់ព្រះរាជលញ្ឆករហើយ**

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០០៩*

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**

លេខ: ១១៤/០៩... រ.ធច

រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០០៩

សម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីង្គារ

ឧបនាយករដ្ឋមន្ត្រី និងជា រដ្ឋមន្ត្រីព្រះបរមរាជវាំង

ROYAUME DU CAMBODGE — LE MINISTRE DU PALAIS ROYAL

គង់ សំអុល

# ព្រះរាជក្រឹត្យ

នស/រកត/១១០៩/១០៩៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **លី ឈិនឡុង** (LEE CHENG LUNG) ជនជាតិចិន សញ្ជាតិនេប៉ាល់ កើតថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ១៩៥៩ នៅសាធារណរដ្ឋប្រជាមានិតចិន ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៤៧.០៩១១.១១០៩

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០០៩*

លេខ:១០៧៤ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ... ខែ វិច្ឆិកា ឆ្នាំ២០០៩
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឃុន ហ៊ុនកេន**

នស/រកត/១២០៩/១១១៨

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរជ្ជបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ /នស /៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស / រកម / ១០៩៦ / ៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ញាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១ :** ផ្តល់សញ្ញាតិខ្មែរ តាមសញ្ញាតូបនីយកម្មដល់អ្នកស្រី **ចូ ជីវ៉ុន** (CHO JIWON) ជនជាតិកូរ៉េ សញ្ញាតិកូរ៉េ កើតថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ១៩៦៣ នៅក្រុងសេអ៊ូល សាធារណរដ្ឋកូរ៉េ ដោយប្តូរឈ្មោះជា **ចូ ម៉ារីយ៉ា** (CHO MARIA) ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រល.០៩១២.១១៤០

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០៩

លេខៈ១០៣៦ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ២០០៩
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**ឃុន ចិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/១២០៩/១១៣៣

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត /០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានដំឡើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ត្រី** ជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ដូចមាន ឈ្មោះខាងក្រោម :

| | | | |
|---|---|---|---|
| ១- លោកវរសេនីយ៍ឯក | **ចាន់ ប្រុកប** | អត្តលេខ | ០៤៥២ |
| ២- លោកវរសេនីយ៍ឯក | **គី ជារ៉ា** | អត្តលេខ | ០៥៥៧ |
| ៣- លោកវរសេនីយ៍ឯក | **ស៊ុម សារម៉េត** | អត្តលេខ | ០៣២២ |
| ៤- លោកវរសេនីយ៍ឯក | **សួន ថណ្ណា** | អត្តលេខ | ០៩០៤ |
| ៥- លោកវរសេនីយ៍ឯក | **ម៉ិន សុផាត** | អត្តលេខ | ០២១៧២ |
| ៦- លោកវរសេនីយ៍ឯក | **តួន ឡុង** | អត្តលេខ | ០២២១៨ |
| ៧- លោកវរសេនីយ៍ឯក | **ហ៊ឹម សុធារិទ្ធ** | អត្តលេខ | ០២២២១ |
| ៨- លោកវរសេនីយ៍ឯក | **ម៉ី សុខឡាយ** | អត្តលេខ | ០១៥១២ |
| ៩- លោកវរសេនីយ៍ឯក | **ម៉ៃ យុវណ្ណល** | អត្តលេខ | ៥៤៨៦៣ |
| ១០- លោកស្រីវរសេនីយ៍ឯក | **យក់ សុខា** | អត្តលេខ | ០២២៥៧ |
| ១១- លោកស្រីវរសេនីយ៍ឯក | **សុខ ចន្ធីរ៉ា** | អត្តលេខ | ០២២២៥ ។ |

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រល.០៩១២.១១៥៩

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ. ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០៩

លេខៈ ១០៦៦ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
ឃុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/១២០៩/១១៣៦

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជ្យបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពី លក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *
ព្រះបរមរាជវាំង

**មាត្រា ១ :** ត្រូវបានដំឡើងថ្នាក់ជូនមន្ត្រីរាជការតាមកម្រិតសញ្ញាប័ត្រ ក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល របស់ក្រសួងផែនការ ចំនួន ០២ នាក់ ដូចមាននាមខាងក្រោម :

| | | | | |
|---|---|---|---|---|
| ១ | **ឆង្យ សារ៉ុន** | ប | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៤ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៣ |
| ២ | **នុត ចន្ទសុខា** | ប | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៤ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៣ |

**មាត្រា ២ :** ត្រូវបានដំឡើងថ្នាក់ ក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល របស់ក្រសួងសុខាភិបាល ចំនួន ០១ នាក់ គិតចាប់ពី ថ្ងៃទី **១៣** ខែ **មេសា** ឆ្នាំ **២០១០** ដូចមាននាមខាងក្រោម :

| | | | | |
|---|---|---|---|---|
| ១ | **សុខ ផេង** | ប | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៥ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៤ |

**មាត្រា ៣ :** មន្ត្រីដែលត្រូវបានដំឡើងថ្នាក់ដូចមាត្រា ១ ខាងលើ ត្រូវបានរក្សាទុកអតីតភាពសម្រាប់ឡើងថ្នាក់តាមវេនជ្រើសរើស និងវេនអតីតភាពដដែល ។

**មាត្រា ៤ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៦ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

៣វល. ០៩១៧. ១១៦១

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០៩*

លេខ: ១០៦៥ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ២០០៩

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ឌិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/១២០៩/១១៤៣

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា ក្សត្រខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត /០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានប្រគល់ឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ឯក** ជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ដូចមានឈ្មោះខាងក្រោម :

១-ឯកឧត្តម **សៅ វ៉ានី** អត្តលេខ ០៤០៤

២-ឯកឧត្តម **ថាច គឹមឡុង** អត្តលេខ ០១៣៩ ។

**មាត្រា ២ :** ត្រូវបានដំឡើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ឯក** ជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ដូចមានឈ្មោះខាងក្រោម :

១-លោកឧត្តមសេនីយ៍ទោ **មៀច សុផាន់ណា** អត្តលេខ ០២៥២

២-លោកឧត្តមសេនីយ៍ទោ **ស៊ូ ធាន** អត្តលេខ ០១៣៤១ ។

**មាត្រា ៣ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣រល. ០៩១២.១១៦៨

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៩*

លេខ:១០៦៨ច.ល

[illegible]ចម្លងចែក

[illegible]ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ២០០៩

អគ្គ[illegible]ការរងរាជរដ្ឋាភិបាល

[illegible]ខែនកេន

# ព្រះរាជក្រឹត្យ

នស/រកត/១២០៩/១១៤៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត /០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានដំឡើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ឯក** ជូនលោកឧត្តមសេនីយ៍ទោ **និត សារ៉ាត់** អត្តលេខ ០៨២២ នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបន្ទុកអនុវត្ត អោយបានសំរេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ៕

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខ:១០៦៩ច.ល

៣រល.០៩១៤.១១៦៩

**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ,ថ្ងៃទី១៩ ខែ ធ្នូ ឆ្នាំ២០០៩
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៩*

**ចិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/១២០៩/១១៤៥

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

## តែងតាំង

I- ឧត្តមសេនីយ៍ព្រះរាជលេខាធិការដ្ឋានព្រះមហាក្សត្រ មានឋានៈស្មើ រដ្ឋលេខាធិការ

១- ព្រះអង្គម្ចាស់ក្សត្រីយ៍ ស៊ីសុវត្ថិ សុផាណា

II- ឯកអគ្គរាជទូតអមព្រះរាជលេខាធិការដ្ឋានព្រះមហាក្សត្រ មានឋានៈស្មើ អនុរដ្ឋលេខាធិការ

១- អ្នកអង្គម្ចាស់ នរោត្តម ចក្រាវុធ
២- អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ មុនីសារោ
៣- អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ សុទ្ធារោ
៤- អ្នកអង្គម្ចាស់ក្សត្រីយ៍ ស៊ីសុវត្ថិ មុនីវង្សី
៥- អ្នកអង្គម្ចាស់ នរោត្តម ណារ៉ាវង្ស
៦- ឯកឧត្តម សុខ ចមរោននិទ្ធ
៧- លោកជំទាវ ឡុង ឌីយ៉ាត
៨- ឯកឧត្តម តូ សាតីន

៣រល.០៩១២ៗ.១១៧០

**បានប្រថាប់ព្រះរាជលញ្ឆករហើយ**

**នរោត្តម សីហមុនី**

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ.ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០០៩

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
លេខ ១១៥/០៩ រ.ធច
រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០០៩
សម្តេចចៅហ្វាវាំង វេង្សជ័យ អធិបតីស្រីធ្លារ
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង
គង់ សំអុល

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ : ២១៣ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការផ្ទេរឥណទានថវិកា

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ , ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ,ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៨/០២០ , ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៩
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក , ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៣ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក , ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក.ចុះថ្ងៃទី ២៨ ខែមីនា ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែមនិង កែសំរួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ១៣៤ អនក្រ.បក.ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងឋានៈការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និង រតនាគារជាតិនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អោយទៅជាអគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៣៨ អនក្រ.បក ,ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៨ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូកនៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៩
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**មាត្រា១:** ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកាចំនួន ៧៥១ លានរៀល (ប្រាំពីររយហាសិបមួយលានរៀលគត់) ពីជំពូក ០៩ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ៦១ (សេវាខាងក្រៅ) របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៩ ។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះ តាមគណនី និង អនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សម្រាប់ទូទាត់ថ្លៃប្រើប្រាស់សេវារថយន្តប្រណិតជូនក្រុមហ៊ុន Royal Cambodia Limousine Services Co., Ltd ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០០៩

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

**បានយកសេចក្តីគោរពជូន**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**គាត ឈន់**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ២១៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកំណត់ប្រាក់ឧបត្ថម្ភចំពោះសមាជិក ក្រុមប្រឹក្សា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៨/០២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០០៩
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០១ ស្តីពីបៀវត្សមូលដ្ឋាននិងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ១៨ អនក្រ.ប្រក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០០៩ ស្តីពីការកំណត់ចំនួនសមាជិកក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ សម្រាប់អាណត្តិទី១
- បានឃើញអនុក្រឹត្យលេខ៥៩ អនក្រ.បក ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តរបបសោធននិវត្តន៍និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈចំពោះមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០២ ស្តីពីការកែសម្រួលការអនុវត្តរបបសោធននិវត្តន៍និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈចំពោះមន្ត្រីរាជការស៊ីវិល តាមប្រព័ន្ធបៀវត្សថ្មី
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៩

## សម្រេច

**មាត្រា១ .-**

អនុក្រឹត្យនេះមានគោលដៅកំណត់ប្រាក់ឧបត្ថម្ភសម្រាប់សមាជិកក្រុមប្រឹក្សារាជធានី សមាជិកក្រុមប្រឹក្សាខេត្ត សមាជិកក្រុមប្រឹក្សាក្រុង សមាជិកក្រុមប្រឹក្សាស្រុក សមាជិកក្រុមប្រឹក្សាខណ្ឌ ដោយអនុលោមតាមមាត្រា២៨នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨។

**មាត្រា២ .-**

អនុក្រឹត្យនេះមានគោលបំណងកំណត់÷

- ចំនួនទឹកប្រាក់ដែលត្រូវឧបត្ថម្ភប្រចាំខែជូនសមាជិកក្រុមប្រឹក្សារាជធានី សមាជិកក្រុមប្រឹក្សាខេត្ត សមាជិកក្រុមប្រឹក្សាក្រុង សមាជិកក្រុមប្រឹក្សាស្រុក សមាជិកក្រុមប្រឹក្សាខណ្ឌម្នាក់ៗ
- វិធាននៃការផ្តល់ប្រាក់ឧបត្ថម្ភជូនសមាជិកក្រុមប្រឹក្សាដែលជាមន្ត្រីរាជការមិនទាន់ចូលនិវត្តន៍ មន្ត្រីរាជការចូលនិវត្តន៍ និងជូនសមាជិកក្រុមប្រឹក្សាដែលមិនមែនជាមន្ត្រីរាជការ។

**មាត្រា៣ .-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះតែសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលកំពុងស្ថិតក្នុងមុខតំណែងប៉ុណ្ណោះ។

**មាត្រា៤ .-**

ប្រាក់ឧបត្ថម្ភប្រចាំខែជូនសមាជិកក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ត្រូវបានកំណត់ដូចខាងក្រោម ÷

- ប្រធានក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ១ 000 000(មួយលាន)រៀល ក្នុងមួយខែ
- សមាជិកក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្នុងមួយនាក់ ៨00 000 (ប្រាំបីរយពាន់)រៀល ក្នុងមួយខែ
- ប្រធានក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ៧00 000 (ប្រាំពីររយពាន់)រៀល ក្នុងមួយខែ
- សមាជិកក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ក្នុងមួយនាក់ ៥00 000 (ប្រាំរយពាន់)រៀល ក្នុងមួយខែ។

**មាត្រា៥ .-**

ការផ្តល់ប្រាក់ឧបត្ថម្ភដូចមានចែងក្នុងមាត្រា៤នៃអនុក្រឹត្យនេះត្រូវអនុវត្តតាមវិធានដូចខាងក្រោម ÷

- សមាជិកក្រុមប្រឹក្សាគ្រប់ប្រភេទដែលជាមន្ត្រីរាជការមិនទាន់ចូលនិវត្តន៍នៅទទួលបានប្រាក់បៀវត្ស មូលដ្ឋាន ប្រាក់ហានិភ័យ ប្រាក់វិភាជន៍គ្រួសារ ព្រមទាំងប្រាក់ឧបត្ថម្ភនេះ។ ក្នុងករណីសាមីខ្លួនជាសមាជិកក្រុមប្រឹក្សាក្នុងមុខតំណែងមកពីមន្ត្រីរាជការដែលនឹងត្រូវចូលនិវត្តន៍ក្នុងក្របខ័ណ្ឌដើមរបស់ខ្លួនឬបាត់បង់សម្បទាវិជ្ជាជីវៈឬបាត់បង់សមត្ថភាពការងារ សាមីខ្លួនត្រូវទទួលបានប្រាក់សោធននិវត្តន៍ឬប្រាក់បាត់បង់សម្បទាវិជ្ជាជីវៈឬប្រាក់បាត់បង់សមត្ថភាពការងារ និងប្រាក់ឧបត្ថម្ភផ្សេងៗ ទៅតាមការកំណត់ដែលមានចែងនៅក្នុងលិខិតបទដ្ឋានគតិយុត្តជាធរមាន។
- សមាជិកក្រុមប្រឹក្សាដែលជាមន្ត្រីរាជការចូលនិវត្តន៍ទទួលបាននូវប្រាក់សោធននិវត្តន៍គ្រប់ចំនួនតាមគោលការណ៍កំណត់និងប្រាក់ឧបត្ថម្ភនេះ
- សមាជិកក្រុមប្រឹក្សាគ្រប់ប្រភេទដែលមិនមែនជាមន្ត្រីរាជការ ទទួលបានត្រឹមតែប្រាក់ឧបត្ថម្ភនេះប៉ុណ្ណោះ។

**មាត្រា៦ .-**

សមាជិកក្រុមប្រឹក្សានៅក្នុងមុខតំណែង ត្រូវទទួលប្រាក់ឧបត្ថម្ភដែលត្រូវបើកចេញពីគម្រោងថវិកាប្រចាំឆ្នាំរបស់ក្រុមប្រឹក្សានោះ។

នៅក្នុងដំណាក់កាលអន្តរកាល ប្រាក់ឧបត្ថម្ភប្រចាំខែរបស់សមាជិកក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ត្រូវបើកផ្តល់ដោយថវិកាប្រចាំឆ្នាំរបស់ខេត្តសាមី។

ការបើកផ្តល់ប្រាក់ឧបត្ថម្ភប្រចាំខែរបស់សមាជិកក្រុមប្រឹក្សាគ្រប់ប្រភេទ ត្រូវអនុវត្តចាប់ពីខែកក្កដា ឆ្នាំ២០០៩។

**មាត្រា៧ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា៨ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ក្រុមប្រឹក្សារាជធានី គណៈអភិបាលរាជធានី ក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត ក្រុមប្រឹក្សាក្រុង គណៈអភិបាលក្រុង ក្រុមប្រឹក្សាស្រុក គណៈអភិបាលស្រុក និងក្រុមប្រឹក្សាខណ្ឌ គណៈអភិបាលខណ្ឌ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ៩ ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ:១៧៣១.អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការដំឡើងឋានន្តរស័ក្តិនាយនគរបាលជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត /០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ស ម្រេ ច

**មាត្រា ១ :** ត្រូវបានដំឡើងឋានន្តរស័ក្តិថ្នាក់ **វរសេនីយ៍ឯក** ជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ចំនួន ៣៣ នាក់ ដូចមានរាយនាមខាងក្រោម :

១- លោកវរសេនីយ៍ទោ **រស់ សុខធឿន** អត្តលេខ ០៧៧៣
២-លោកវរសេនីយ៍ទោ **ម៉ុក សាម៉ាត** អត្តលេខ ០៨៧៩
៣-លោកវរសេនីយ៍ទោ **ម៉ែន ចន្ថា** អត្តលេខ ០១០៧៨
៤-លោកវរសេនីយ៍ទោ **សុខ លីណា** អត្តលេខ ០១៣៣៥
៥-លោកវរសេនីយ៍ទោ **ចាន់ ម៉ាន់ធឿន** អត្តលេខ ០២១៥៩
៦- លោកវរសេនីយ៍ទោ **គង់ មនោ** អត្តលេខ ១៥៨៣១
៧-លោកវរសេនីយ៍ទោ **ខ្លូត តារា** អត្តលេខ ០១១៤៩
៨-លោកវរសេនីយ៍ទោ **វ៉ាន់ ចន្នី** អត្តលេខ ០៥១០៤
៩-លោកវរសេនីយ៍ទោ **ប៊ុល សុខនាង** អត្តលេខ ០៦១៣១ ./.

១០-លោកវរសេនីយ៍ទោ ជួង សិរិទ្ធ អត្តលេខ ០៩២១៦
១១-លោកវរសេនីយ៍ទោ លី ជាឫទ្ធ អត្តលេខ ៩៤៤៧៧
១២-លោកវរសេនីយ៍ទោ លឹម ជាឫទ្ធ អត្តលេខ ០៣៩១៨
១៣-លោកវរសេនីយ៍ទោ តាន់ សុចិន្ដា អត្តលេខ ០៩៥៥៥
១៤-លោកវរសេនីយ៍ទោ គង់ សារី អត្តលេខ ០៧៤៦២
១៥-លោកវរសេនីយ៍ទោ ម៉ៅ ម៉ុន អត្តលេខ ០៥១០៦
១៦-លោកវរសេនីយ៍ទោ អ៊ុំ ប៊ុនថន អត្តលេខ ០១២៨០
១៧-លោកវរសេនីយ៍ទោ តាន់ ផា អត្តលេខ ០៥០៤៣
១៨-លោកវរសេនីយ៍ទោ តាំ សុខាន់ អត្តលេខ ០៦២៨៧
១៩-លោកវរសេនីយ៍ទោ សួស សុភាព អត្តលេខ ៦២៧៤០
២០-លោកវរសេនីយ៍ទោ ឡាយ ប៊ុនថន អត្តលេខ ០៣៦៩៥
២១-លោកវរសេនីយ៍ទោ លី ឡាយឫទ្ធិ អត្តលេខ ០៧៤៥៨
២២-លោកវរសេនីយ៍ទោ ហ៊ិន សុផល អត្តលេខ ០៩១៣
២៣-លោកវរសេនីយ៍ទោ ពេជ្រ យ៉ុន អត្តលេខ ០១៣១៥
២៤-លោកវរសេនីយ៍ទោ យី ចន្ថា អត្តលេខ ០៦៩៩
២៥-លោកវរសេនីយ៍ទោ ទឹម នឿន អត្តលេខ ០១៩៦១
២៦-លោកវរសេនីយ៍ទោ ម៉ុល ផាន់ណា អត្តលេខ ០៦៥១៧
២៧-លោកវរសេនីយ៍ទោ គួន ផល អត្តលេខ ០១៥០៦
២៨-លោកវរសេនីយ៍ទោ ចិញ ឡា អត្តលេខ ០៥៨៤៥
២៩-លោកវរសេនីយ៍ទោ គឹម សារិទ្ធ អត្តលេខ ២០៤១៦
៣០-លោកវរសេនីយ៍ទោ ឈឹម សុផល អត្តលេខ ២០៤៥៧
៣១-លោកវរសេនីយ៍ទោ ចាន់ឡុ ធី អត្តលេខ ០៥៨៤១
៣២-លោកវរសេនីយ៍ទោ ចាម សុធានិត អត្តលេខ ៥៥៧៧១
៣៣-លោកវរសេនីយ៍ទោ ខូច លី អត្តលេខ ៦៤២៦៦ ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធនិងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ.ថ្ងៃទី ០៩ ខែ ៨ ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ១៧៣៧- អនក្រ.បក**

# អនុក្រឹត្យ
# ស្តីពី
# ការដំឡើងឋានន្តរស័ក្តិមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើប្រាស់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មិនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល

-បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន

-តាមសំណើរបស់ក្រសួងបរិស្ថាន

## ស ម្រេ ច

**មាត្រា ១ :** ត្រូវបានតំឡើងឋានន្តរស័ក្តិមន្ត្រីរាជការក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល របស់ក្រសួងបរិស្ថាន ដូចមានរាយនាមខាងក្រោម :

| | | | | |
|---|---|---|---|---|
| ១ | **អ៊ុក សីហា** | ស | ពីអនុមន្ត្រីថ្នាក់ លេខ ៦ | ទៅវរមន្ត្រី ថ្នាក់លេខ ៧ |
| ២ | **ធិន ពន្លក** | ប | ពីអនុមន្ត្រី ថ្នាក់លេខ ៧ | ទៅវរមន្ត្រី ថ្នាក់លេខ ៨ |

| | | | | |
|---|---|---|---|---|
| ៣ | **ចាន់ សុមាលី** | ស | ពីអនុមន្ត្រី ថ្នាក់លេខ ១០ | ទៅវរមន្ត្រី ថ្នាក់លេខ ១០ |
| ៤ | **កែន សេរីរដ្ឋា** | ប | ពីអនុមន្ត្រី ថ្នាក់លេខ ១១ | ទៅវរមន្ត្រី ថ្នាក់លេខ ១០ |
| ៥ | **ស៊ុំ រ៉ាមុនី** | ប | ពីអនុមន្ត្រី ថ្នាក់លេខ ១០ | ទៅវរមន្ត្រី ថ្នាក់លេខ ១០ |
| ៦ | **ស្រី ម៉ារីណា** | ប | ពីអនុមន្ត្រី ថ្នាក់លេខ ១១ | ទៅវរមន្ត្រី ថ្នាក់លេខ ១០ |

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ត្រូវ អនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

***កន្លែងទទួល:***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច* ✓
- *ឯកសារ-កាលប្បវត្តិ*

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ ៨ ឆ្នាំ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១៧៣៣ - អនក្រ-បក

# អនុក្រឹត្យ
# ស្តីពី
# ការផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងនាយនគរបាលជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត /០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ស ំ រ េ ច

**មាត្រា ១ :** ត្រូវបានផ្ទេរភារកិច្ចនិងតែងតាំងមុខតំណែងនាយនគរបាលជាតិចំនួន ០៤ នាក់ នៃក្រសួងមហាផ្ទៃ ដូចខាងក្រោម :

១-លោកឧត្តមសេនីយ៍ទោ **ម៉ន អ៊ីម** អត្តលេខ ០០៣២ ពីអនុប្រធានទី១ នាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈ ទៅជាអគ្គនាយករងភស្តុភារនិងហិរញ្ញវត្ថុ ។

២- លោកឧត្តមសេនីយ៍ត្រី **សំ មូរ** អត្តលេខ ០៩៥៣ ពីអនុប្រធាននាយកដ្ឋានកណ្តាលមធ្យោបាយ ទៅជាអនុប្រធាននាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈ ។

៣- លោកឧត្តមសេនីយ៍ត្រី **តៅ លីមទី** អត្តលេខ ០២១៥ ពីអនុប្រធាននាយកដ្ឋាននគរបាលព្រហ្មទណ្ឌ ទៅជាអនុប្រធាននាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈ ។

៤- លោកឧត្តមសេនីយ៍ត្រី **សុន ធុន្ទី** អត្តលេខ ០៥៦៧ ពីអនុប្រធានមន្ទីរចាត់ការ ទៅជានាយកមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈអនុរក្សពន្ធនាគារ ។

**មាត្រា ២:** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល :***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:.១៣៣៤...អនក្រ.ពក

# អនុក្រឹត្យ

## ស្ដីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.—**

ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និង ជូនសប្បុរសជនចំនួន ០៦ រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាង ឧបដ្ឋានសាលា កុដិ ផ្លូវក្រាលបេតុង និង រោងម៉ាស៊ីនភ្លើង នៅ**វត្តកន្ទីយារាម** ស្ថិតក្នុងឃុំព្រែកលួង ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល ដែលមានរាយព្រះនាម និងនាមដូចខាងក្រោម :

**ក~ មេដាយមាសស្ថាបនាជាតិចំនួន ០១ គ្រឿង ប្រគេនជូន**

ព្រះតេជគុណ **ឈិន សំអូន** ព្រះចៅអធិការវត្តកន្ទីយារាម បច្ច័យចំនួន ១២.៣០០ ដុល្លារ

**ខ~ មេដាយសំរិទ្ធស្ថាបនាជាតិចំនួន ០៥ គ្រឿង ផ្ដល់ជូន :**

| | | | |
|---|---|---|---|
| ១-លោក | **សុខ លុច** | សប្បុរសជននៅខេត្តកណ្ដាល | ថវិកាចំនួន ២.៥០០ ដុល្លារ |
| ២-លោក | **ម៉ុក រ៉ាវី** | សប្បុរសជននៅខេត្តកណ្ដាល | ថវិកាចំនួន ១.២៥០ ដុល្លារ |
| ៣-លោក | **ហ៊ុយ សៀង** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១.២០០ ដុល្លារ |
| ៤-លោក | **យក្ស សារឹម** | សប្បុរសជននៅខេត្តកណ្ដាល | ថវិកាចំនួន ១.១០០ ដុល្លារ |
| ៥-លោក | **ហៀប សុគន្ធ** | សប្បុរសជននៅខេត្តកណ្ដាល | ថវិកាចំនួន ១.០៤០ ដុល្លារ |

**មាត្រា ២.—**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលខេត្តកណ្ដាល និងសាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៨

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:១៧៣៥ . អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយសុវត្ថារា

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

### សម្រេច

**មាត្រា១.-**

ត្រូវបានបំពាក់ **មេដាយសុវត្ថារា** ថ្នាក់ **អស្សឫទ្ធិ** ជូនមន្ត្រីរាជការនៃក្រសួងអភិវឌ្ឍន៍ជនបទ ចំនួន០២រូប ដែលមានស្នាដៃល្អ និងសកម្មក្នុងការអនុវត្តការងារ លើវិស័យអភិវឌ្ឍន៍ជនបទ ដូចមានរាយនាមខាងក្រោម :-

១-លោក អ៊ុក ធូរេន អនុប្រធាននាយកដ្ឋានរដ្ឋបាល និងបុគ្គលិក

២-លោក សោម ផូ អនុប្រធានមន្ទីរអភិវឌ្ឍន៍ជនបទខេត្តស្វាយរៀង

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ ធ្នូ ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា១ និង មាត្រា២

-រាជកិច្ច

-ឯកសារ- កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:១៧៣៦ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

**សម្រេច**

- បង្កើតកម្មវិធីកសាងសមត្ថភាព ស្ថាប័នរដ្ឋនៅមូលដ្ឋាន និងផលិតករអំពីបទដ្ឋានអនាម័យ និងភូតគាមអនាម័យ
- ផ្តល់ការគាំទ្រ និងលើកកំពស់ការអភិវឌ្ឍអាជីវកម្ម និងភាពជាម្ចាស់របស់សហគ្រិន ដើម្បីបង្កើនសមត្ថភាពនាំចេញរបស់សហគ្រាសធុនតូច និងមធ្យមនៅកម្ពុជា

- បង្កើតកម្មវិធី និងលើកសំណើ ដើម្បីកសាងក្របខ័ណ្ឌច្បាប់ និងប្រព័ន្ធផ្តល់ឥណទាន ដើម្បីពង្រឹងការផ្តល់ហិរញ្ញប្បទានដល់ការវិនិយោគខ្នាតតូច
- វិះរកវិធានការណ៍ និងស្វែងរកប្រភពធនធាន និងបច្ចេកទេស ដើម្បីជួយអ្នកផលិតនៅថ្នាក់មូលដ្ឋាន
- រៀបចំការងារពាក់ព័ន្ធនឹងការអភិវឌ្ឍសម្រាប់ការនាំចេញផ្សេងទៀត ។

គ) ធ្វើកិច្ចការផ្សេងទៀត តាមការប្រគល់ដោយគណៈកម្មការអនុវត្តមូលនិធិពហុភាគី ។

**ប្រការ ៧.-**

ក្រុមការងារអភិវឌ្ឍន៍សមត្ថភាពពាណិជ្ជកម្ម មានភារកិច្ចដូចតទៅ :

ក) ផ្សៀងផ្ទាត់ធនធានដែលមានស្រាប់ និងធនធានទទួលបានពីដៃគូអភិវឌ្ឍន៍នានា ជាមួយគម្រោងអាទិភាពដែលបានកំណត់ និងដែលបានឯកភាពរួច ។

ខ) រៀបចំផែនការបណ្តុះបណ្តាលធនធានមនុស្ស ដែលចាំបាច់សម្រាប់ធានាឱ្យមានកំណើនក្នុងវិស័យពាណិជ្ជកម្ម និងវិស័យពាក់ព័ន្ធនៅកម្ពុជា

គ) រៀបចំកម្មវិធីការងារលំអិត ដែលនឹងត្រូវគាំទ្រដោយរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានា ដោយផ្តោតលើវិស័យសំខាន់ៗ ដូចតទៅ :

- ពង្រឹងសមត្ថភាពមន្ត្រីក្រសួងពាណិជ្ជកម្ម និងមន្ត្រីក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីគាំទ្រសកម្មភាពពាណិជ្ជកម្មផ្សេងៗ
- ពង្រឹងសមត្ថភាពមន្ត្រីបម្រើការងារនៅក្នុងផ្នែកស្រាវជ្រាវ និងវិភាគពាណិជ្ជកម្ម
- លើកកំពស់ការអភិវឌ្ឍសមត្ថភាពសម្រាប់ការចរចាពាណិជ្ជកម្ម និងការវិនិយោគពាក់ព័ន្ធនឹងវិស័យពាណិជ្ជកម្មរបស់ក្រសួងពាណិជ្ជកម្ម និងក្រសួង ស្ថាប័នដែលគាំទ្រវិស័យពាណិជ្ជកម្ម ។

ឃ) ធ្វើកិច្ចការផ្សេងទៀត តាមការប្រគល់ដោយគណៈកម្មការអនុវត្តមូលនិធិពហុភាគី ។

**ប្រការ ៨.-**

ប្រធានក្រុមការងារនីមួយៗ ត្រូវរៀបចំរបាយការណ៍ស្តីពីសកម្មភាពនានារបស់ក្រុមការងារសម្រាប់ជូនអង្គប្រជុំនីមួយៗរបស់គណៈកម្មការអនុវត្តមូលនិធិពហុភាគី ។

**ប្រការ ៩.-**

នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ នៃអគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិរបស់ក្រសួងពាណិជ្ជកម្ម ត្រូវបំពេញការងារជាលេខាធិការដ្ឋានគណៈកម្មការអនុវត្តមូលនិធិពហុភាគី ព្រមទាំងធ្វើការងារសម្របសម្រួលជាមួយក្រុមការងារទាំង៣ ។

**ប្រការ ១០.-**

គណៈកម្មការអនុវត្តមូលនិធិពហុភាគី មានសិទ្ធិប្រើត្រារបស់ក្រសួងពាណិជ្ជកម្ម និងមានកញ្ចប់ថវិកាជាឧបសម្ព័ន្ធថវិការបស់ក្រសួងពាណិជ្ជកម្ម ។

**ប្រការ ១១.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ ១២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងកិច្ចការនារី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ៨ ឆ្នាំ ២០០៩

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ១២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទំព័រទី ១

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០០៣......សហវ.....

លិខិតចូល
ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ 2009

# សារាចរណែនាំ
## ស្តីពីការបិទបញ្ជីចំណូល ចំណាយ និងធ្វើរបាយការណ៍
## បូកសរុបទូទាត់ថវិការាជធានី ខេត្ត ឆ្នាំ២០០៩

យោងមាត្រា ១២ នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ខេត្ត ក្រុង ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រមលេខ ជស/រកម/០២៩៨/០៣ ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ និងប្រការ ៣២ ប្រការ ៣៣ នៃប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលេខ ២០៣ ប្រក.សហវ.ថ ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៩៩ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមធ្វើការណែនាំស្តីពីនីតិវិធីបច្ចេកទេសក្នុងការបិទបញ្ជីចំណូល ចំណាយ និងធ្វើរបាយការណ៍សំរេចទូទាត់ថវិការាជធានី ខេត្ត ឆ្នាំ២០០៩ ដូចខាងក្រោម ៖

**១.** អភិបាលរាជធានី ខេត្ត ដែលជាអាណាប័កដើមខ្សែ ត្រូវខិតខំជំរុញចំណូលសារពើពន្ធ និងប្រមូលចំណូលមិនមែនសារពើពន្ធ ដែលស្ថិតនៅក្នុងសមត្ថកិច្ចរបស់ខ្លួន បង់ចូលថវិការាជធានី ខេត្ត ទាំងអស់យ៉ាងយូរត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៩ ។ ប្រសិនបើមានកាយឺតយ៉ាវក្រោយថ្ងៃកំណត់នេះ រតនាគាររាជធានី ខេត្ត ត្រូវកត់ត្រាចូលជាចំណូលថវិការាជធានី ខេត្ត ឆ្នាំ ២០១០។

**២.** ការស្នើសុំថវិកាឧបត្ថម្ភតុល្យភាព ក្រុមហិរញ្ញវត្ថុរបស់សាលារាជធានី ខេត្ត ទាំងអស់ ត្រូវបញ្ជូនសំណុំលិខិតស្នើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ យ៉ាងយូរត្រឹមថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០០៩ ។

**៣.** ការធ្វើនិយ័តភាពឥណទានដែលពាក់ព័ន្ធដល់ការសុំអនុញ្ញាតពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រុមហិរញ្ញវត្ថុរបស់សាលារាជធានី ខេត្ត ទាំងអស់ត្រូវបញ្ជូនសំណុំលិខិតស្នើសុំមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ យ៉ាងយូរត្រឹមថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០០៩ ។

**៤.** ចំពោះឥណទានដែលបានធ្វើនិយ័តកម្ម និងបានការអនុញ្ញាតដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ត្រូវខិតខំរៀបចំគំរោងអោយបានសមស្រប ក្នុងការអនុវត្តនីតិវិធីលទ្ធកម្ម ដើម្បីអោយការអនុវត្តគំរោងអាចសំរេចបានទាន់ពេលវេលា ។

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com

៥. រតនាគាររាជធានី ខេត្ត ត្រូវបញ្ឈប់ការទទួលអាណត្តិបើកប្រាក់នៅម៉ោង ១៧ និង៣០នាទី នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៩ ។ ដូច្នេះក្រុមហិរញ្ញវត្ថុរបស់សាលារាជធានី ខេត្ត ត្រូវប្រមូលសរាល់ប្រមូលសក្ខីប័ត្រ និងលិខិតយុត្តិការ ដើម្បីធ្វើអាណត្តិ (ទាំងអាណត្តិទូទាត់ត្រង់ ទាំងអាណត្តិទូទាត់រជ្ជទេយ្យបុរេប្រទាន) បញ្ជូនទៅផ្នែងទិដ្ឋាការមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ រួចដាក់ជូនឯកឧត្តមអភិបាលរាជធានី ខេត្ត ចុះហត្ថលេខា និងបញ្ជូនទៅរតនាគាររាជធានី ខេត្ត អោយបានមុនម៉ោង ១៧ និង៣០នាទី នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៩។

៦. នៅចុងថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៩ រតនាគាររាជធានី ខេត្ត ត្រូវដំណើរការផ្ទេរសមតុល្យគណនីចំណូល ចំណាយរបស់សាលារាជធានី ខេត្ត ចូលទៅក្នុងគណនីលទ្ធផលនៃការិយបរិច្ឆេទ ។ ប្រសិនបើមានអតិរេក រតនាគាររាជធានី ខេត្ត ត្រូវជូនដំណឹងទៅសាលារាជធានី ខេត្ត អោយធ្វើសលាកប័ត្រចំណូលបង់ប្រាក់ចូលថវិកាជាតិឆ្នាំ ២០០៩ ជាបន្ទាន់ក្នុងករណីមានការយឺតយ៉ាវស្ថិតនៅចន្លោះពីថ្ងៃទី ០១ ដល់ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១០ នោះកាលបរិច្ឆេទនៃការបង់ត្រូវចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៩ដែរ ។ ផ្ទុយទៅវិញប្រសិនបើហួសកាលកំណត់ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១០ ហើយសាលារាជធានី ខេត្ត នៅតែពុំទាន់បានបង់ទេនោះ គឺរតនាគាររាជធានី ខេត្ត ត្រូវម្ចាស់ការផ្ទេរដោយស្វ័យប្រវត្តិចូលជាចំណូលថវិកាជាតិ ហើយត្រូវជូនដំណឹងទៅសាលារាជធានី ខេត្ត អោយបានជ្រាប ។ កាលបរិច្ឆេទនៃការផ្ទេរនេះ ក៏ត្រូវចាត់ទុកថា ជាកិច្ចប្រតិបត្តិការថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៩ ដែរ ។

៧. កិច្ចប្រតិបត្តិការនិយ័តភាវូបនីយកម្មរបស់រតនាគារ សំរាប់ថវិការាជធានី ខេត្ត ឆ្នាំ២០០៩ ត្រូវបន្តរហូតដល់ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១០ ។ កិច្ចប្រតិបត្តិការនេះ ត្រូវបានពិនិត្យកត់ត្រាជាលេខនាបន្ថែមនៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៩ ដែលទាក់ទងទៅនឹង :

- ការកត់ត្រាជាស្ថាពរនៃចំណូលឬនៃចំណាយ ដែលបានពិនិត្យកត់ត្រាជាលេខនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៩ ជាអាទិ៍ចូលគណនីកត់ត្រាបណ្តោះអាសន្ន ។

- អាណត្តិនិយ័តភាវូបនីយកម្ម ដែលទាក់ទងដល់ចំណាយដែលបានទូទាត់ដោយរជ្ជទេយ្យបុរេប្រទានមុនថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៩ ។

- ការកែប្រែលេខនាខុស ។

៨. ចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១០ រាល់កិច្ចប្រតិបត្តិការចំណូល ចំណាយថវិការាជធានី ខេត្ត ឆ្នាំថ្មី ត្រូវកត់ត្រាចូលក្នុងគណនីថវិការាជធានី ខេត្ត ឆ្នាំ ២០១០ ។

៩. ចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១០ រតនាគាររាជធានី ខេត្ត និងក្រុមហិរញ្ញវត្ថុរបស់សាលារាជធានី ខេត្ត ត្រូវដំណើរការបូកសរុបនិងផ្ទៀងផ្ទាត់អំពីការអនុវត្តន៍ចំណូល ចំណាយថវិការាជធានី ខេត្ត ឆ្នាំ២០០៩

ដោយរតនាគាររាជធានី ខេត្ត ត្រូវបង្កើតតារាងតុល្យភាពគណនីប្រចាំឆ្នាំ និងក្រុមហិរញ្ញវត្ថុរបស់សាលារាជធានី ខេត្ត ត្រូវធ្វើតារាងបូកសរុប ចំណូល ចំណាយថវិការាជធានី ខេត្ត តាមមាតិកាថវិកា រួចធ្វើកំណត់បង្ហាញដាក់ជូនឯកឧត្តមអភិបាលរាជធានី ខេត្ត ពិនិត្យសំរេច និងចុះហត្ថលេខា ។ អភិបាលរាជធានី ខេត្ត ត្រូវធ្វើលិខិតបញ្ជូនតារាងតុល្យភាពគណនីប្រចាំឆ្នាំ តារាងបូកសរុបចំណូល ចំណាយ និងកំណត់បង្ហាញខាងលើ ទៅក្រសួងមហាផ្ទៃ ចំនួន ០១ច្បាប់ និង មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំនួន ០២ច្បាប់(នាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន ០១ច្បាប់ និងអគ្គនាយកដ្ឋានរតនាគារជាតិ ០១ច្បាប់) អោយបានមុនថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១០ ដើម្បីនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ធ្វើការបូកសរុប និងរៀបចំនូវរបាយការណ៍សំរេចទូទាត់ថវិការាជធានី ខេត្ត រួមមួយ ដើម្បីដាក់បញ្ចូលទៅក្នុងសេចក្តីព្រាងច្បាប់ ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៩ ។

អភិបាលរាជធានី ខេត្ត ត្រូវយកចិត្តទុកដាក់អនុវត្តអោយបានតាមការកំណត់ដូចខាងលើ ដើម្បីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានលទ្ធភាពធ្វើការបូកសរុបរៀបចំសេចក្តីព្រាងច្បាប់ ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៩ ដាក់ជូនគណៈរដ្ឋមន្ត្រីពិនិត្យសំរេច និងរដ្ឋសភា ព្រឹទ្ធសភា ពិនិត្យអនុម័តអោយបានទាន់ពេលវេលា ។

រាជធានីភ្នំពេញ,ថ្ងៃទី២៤ ខែ វិច្ឆិកា ឆ្នាំ ២០០៩

ឧបនាយករដ្ឋមន្ត្រី



រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

**ចម្លងជូនៈ**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- អគ្គនាយកដ្ឋានរតនាគារជាតិ
- សាលារាជធានី ខេត្ត
- មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត
- រតនាគាររាជធានី ខេត្ត
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត ............

លេខកូដ............

# តារាងបូកសរុបចំណូលថវិការាជធានី ខេត្ត

# សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៩

តារាងឧបសម្ព័ន្ធ១

| ជំពូក | គណនី | អនុគណនី | បរិយាយ<br>ចំណាត់ថ្នាក់ចំណូល | ច្បាប់<br>ហិរញ្ញវត្ថុដើមឆ្នាំ | អនុវត្ត<br>ជាក់ស្តែង | សមាមាត្រ<br>ប្រៀបធៀប | សេចក្តីផ្សេងៗ |
|---|---|---|---|---|---|---|---|
| | | | ១ | ២ | ៣ | ៤=៣ / ២ | |
| | | | | | | | |
| | | | សរុបរួម | | | | |

ហត្ថលេខា និងត្រា
អភិបាលរាជធានី ខេត្ត

ហត្ថលេខា និងត្រា
ប្រធានតេនាគាររាជធានី ខេត្ត

ហត្ថលេខា និងត្រា
ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
រាជធានី ខេត្ត

ហត្ថលេខា
អ្នកធ្វើតារាង

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត .........

លេខកូដ...........

# តារាងបូកសរុបចំណាយថវិការាជធានី ខេត្ត

## សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៩

តារាងឧបសម្ព័ន្ធ២

| ជំពូក | គណនី | អនុគណនី | បរិយាយចំណាត់ថ្នាក់ចំណាយ | ច្បាប់ហិរញ្ញវត្ថុដើមឆ្នាំ | ចលនាឥណទាន | | | ឥណទានអនុញ្ញាត | អនុវត្តជាក់ស្តែង | សមាមាត្រប្រៀបធៀប | សេចក្តីផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ថែម | កើន | ថយ | | | | |
| | | | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨=៧/៦ | |
| | | | | | | | | | | | |
| | | | សរុបរួម | | | | | | | | |

ហត្ថលេខា និងត្រា

អភិបាលរាជធានី ខេត្ត

ហត្ថលេខា និងត្រា

ប្រធានរតនាគាររាជធានី ខេត្ត

ហត្ថលេខា និងត្រា

ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

រាជធានី ខេត្ត

ហត្ថលេខា

អ្នកធ្វើតារាង

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៥-០៩-២២៩ ប្រ.ក

លិខិតចូល
ថ្ងៃទី១៨ ខែ ធ្នូ ឆ្នាំ2009

# ប្រកាស

## ស្តីពី

## ការដាក់ឱ្យអនុវត្តកិច្ចសន្យាមេសម្រាប់ប្រតិបត្តិការទទួលទិញវិញ ដើម្បីធានាដល់ប្រតិបត្តិការអន្តរធនាគារនៅក្នុងទីផ្សាររូបិយវត្ថុ

**ទេសាភិបាលធនាគារជាតិ នៃ កម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស /រកម/០១៩៦ /២៧ ចុះថ្ងៃទី ២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩ /១៣ ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស /រកម/១២០៦ /០៣៦ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៤ និងមាត្រា ៥៧ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៨/៥២៦ ចុះថ្ងៃទី ១៣ ខែឧសភា ឆ្នាំ២០០៨ ស្តីពីការតែងតាំងឯកឧត្តម ជា ចាន់តូ ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា មានឋានៈស្មើទេសរដ្ឋមន្ត្រី
- យោងតាមស្មារតីនៃអង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០០៩

**ស ម្រេ ច**

**ប្រការ ១ .-**

ដាក់ឱ្យប្រើប្រាស់កិច្ចសន្យាមេសម្រាប់ប្រតិបត្តិការទទួលទិញវិញ ដើម្បីផ្តល់ដល់អ្នកចូលរួមក្នុងទីផ្សារនូវក្របខ័ណ្ឌកិច្ចសន្យាដែលមានការធានា ក្នុងគោលបំណងជម្រុញប្រតិបត្តិការកម្ចីអន្តរធនាគារ ដោយមានវត្ថុបញ្ចាំ ដូចមានឧបសម្ព័ន្ធភ្ជាប់ជាមួយនេះ ។ នៅក្នុងន័យនៃប្រកាសនេះ ពាក្យថាទទួលទិញវិញ (Repos) សំដៅដល់ពាក្យប៉ង់ស្យុង ដូចមានចែងនៅក្នុងមាត្រា ២៦ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា ។

នៅពេលដែលចុះហត្ថលេខាលើកិច្ចសន្យាមេ ភាគីទាំងពីរព្រមព្រៀងថា ប្រតិបត្តិការទទួលទិញវិញទាំងអស់

ដែលត្រូវបានធ្វើរវាងភាគីទាំងពីរ ត្រូវតែអនុលោមតាមគោលការណ៍ដែលមានចែងក្នុងកិច្ចសន្យាមេនេះ លើកលែងតែភាគីទាំងពីរ បានព្រមព្រៀងជាក់លាក់ផ្សេងពីនេះ ។ លើសពីនេះ ប្រតិបត្តិការទទួលទិញវិញនិមួយៗដែលធ្វើរវាងភាគីទាំងពីរ ត្រូវតែបានបញ្ជាក់ដោយមធ្យោបាយសមស្រប និងជាលាយលក្ខណ៍អក្សរ ។

តាមកាលៈទេសៈតម្រូវ កិច្ចសន្យាមេបង្កើនភាពទន់ភ្លន់ក្នុងការគ្រប់គ្រងហានិភ័យនៃសមតុល្យឥណទានតាមរយៈការគណនាចំនួនសុទ្ធនៃឥណទានដែលនៅសល់ដោយរួមបញ្ចូលនូវរាល់ស្ថានភាពហានិភ័យនៃប្រតិបត្តិការទទួលទិញវិញទាំងអស់ ដែលស្ថិតក្រោមវិធាននៃកិច្ចសន្យាមេ ។

**ប្រការ ២ .-**

ក្រោមកាលៈទេសៈធម្មតា កិច្ចសន្យាមេនៃប្រតិបត្តិការទទួលទិញវិញ ត្រូវបានចាត់ទុកជាសំខាន់ថាជាមធ្យោបាយដើម្បីគ្រប់គ្រងហានិភ័យគូភាគី ដោយប្រមើលទុកជាមុននូវកំរិតកំណត់ដែលបើសិនជាថ្លៃទីផ្សារឡើង ឬចុះដល់ ឬហួសកំរិតកំណត់នោះ នឹងអាចនាំឱ្យភាគីដែលទទួលរងហានិភ័យ ទាមទារវត្ថុបញ្ចាំបន្ថែម ឬមួយក្នុងទម្រង់ជា Margin Call ជាមូលបត្រ ឬ Margin Calls ជាសាច់ប្រាក់ ។ នៅពេលសមស្រប និងនៅពេលដែលភាគីទាំងពីរព្រមព្រៀងគ្នាលើបែបបទខាងលើ ការកាត់បន្ថយហានិភ័យគូភាគី អាចនឹងបានមកដោយសារការផ្គួបគ្នានូវ ការបន្ថែម Margin Calls ជាមូលបត្រនិង Margin Calls ជាសាច់ប្រាក់ ។

បើគ្មានហេតុការណ៍ខកខានទេ ភាគីទាំងពីរនឹងបំពេញរាល់កាតព្វកិច្ចទាក់ទងនឹងប្រតិបត្តិការទទួលទិញវិញនិមួយៗក្រោមកិច្ចសន្យាមេ ដោយអនុលោមតាមលក្ខខណ្ឌជាក់លាក់នៃការបញ្ជាក់ទៅវិញទៅមក ដែលចេញដោយភាគីទាំងពីរ ។

ដូច្នេះ ប្រតិបត្តិការទទួលទិញវិញនិមួយៗ ដែលស្ថិតក្រោមកិច្ចសន្យាមេ គឺជាការផ្គួបគ្នានូវប្រតិបត្តិការពីរដែលត្រូវតែបានធ្វើឡើងព្រមគ្នាក្នុងពេលតែមួយ ។ ប្រតិបត្តិការម្ខាង គឺភាគីឱ្យខ្ចីប្រាក់ផ្តល់ឥណទានដល់ភាគីខ្ចីប្រាក់ និងប្រតិបត្តិការម្ខាងទៀត ភាគីខ្ចីប្រាក់លក់កម្មសិទ្ធិពេញលេញនៃមូលបត្រទៅឱ្យភាគីឱ្យខ្ចីប្រាក់ ដោយប្តេជ្ញាទទួលទិញមូលបត្រវិញនាកាលវសាន តាមថ្លៃព្រមព្រៀងគ្នា ដែលបានបញ្ជាក់ជាមុនក្នុងកិច្ចសន្យា ។ ផ្នែកម្ខាងៗនៃប្រតិបត្តិការទទួលទិញវិញត្រូវបានចាត់ទុកថា ជាការផ្តល់ការធានាដល់ភាគីនិមួយៗនៃកិច្ចសន្យា ។

**ប្រការ ៣ .-**

ភាគីទាំងពីរនៃកិច្ចសន្យាមេ ត្រូវតែព្រមព្រៀងគ្នាលើមូលបត្រ សម្រាប់ប្រតិបត្តិការទទួលទិញវិញ ។ យោងទៅលើការវិវត្តរបស់ទីផ្សារ ភាគីទាំងពីរត្រូវតែធ្វើបញ្ជីមូលបត្រ ហើយបញ្ជីនោះត្រូវចាត់ទុកជាកិច្ចសន្យាបន្ថែមទៅលើកិច្ចសន្យាមេ ។

មូលបត្រទាំងនោះអាចក្លាយជាកម្មវត្ថុនៃហានិភ័យថ្លៃ ដូច្នេះវាត្រូវតែឆ្លើយតប និងអនុលោមទៅនឹងការរារាំងនិងការហាមឃាត់ដែលបានកំណត់នៅក្នុងកិច្ចសន្យាមេ ជាពិសេស ចំពោះការផ្លាស់ប្តូរអត្រាការប្រាក់នៅក្នុង

ទីផ្សារ ។ ដូច្នេះ ភាគីទាំងពីរត្រូវតែព្រមព្រៀងគ្នាលើគ្រាដែលត្រូវធ្វើការវាយតម្លៃវត្ថុបញ្ចាំតាមតម្លៃទីផ្សារ និងប្រភពព័ត៌មានថ្លៃ ដែលត្រូវប្រើសម្រាប់វាយតម្លៃនោះ ។ លើសពីនេះ ស្ថានភាពហានិភ័យគូភាគីត្រូវតែបានព្រមព្រៀងគ្នា ហើយមូលបត្រដែលពាក់ព័ន្ធ និង /ឬ Margin Calls ជាសាច់ប្រាក់ត្រូវតែបានបញ្ជាក់ ។

ចំពោះស្ថានភាពហានិភ័យឥណទានដែលនៅសល់ដែលគ្មានការធានា អ្នកចូលរួមទីផ្សារត្រូវបង្កើតគោលនយោបាយ និងនីតិវិធីសមស្រប ក៏ដូចជា ដំណើរការឱ្យបានគ្រប់គ្រាន់ ដើម្បីពិនិត្យនិងគ្រប់គ្រងស្ថានភាពហានិភ័យ និងដំណើរការបញ្ជាក់របស់ភាគីទាំងសងខាង ។

**ប្រការ ៤ .-**

អ្នកចូលរួមទីផ្សារត្រូវតែបង្កើតនីតិវិធី និងដំណើរការត្រួតពិនិត្យផ្ទៃក្នុងឱ្យបានគ្រប់គ្រាន់ ដើម្បីការពារការខកខានមិនបានអនុវត្តកាតព្វកិច្ចទាន់ពេលវេលា នៅពេលធ្វើប្រតិបត្តិការ ។ ក៏ប៉ុន្តែ ប្រសិនបើភាគីណាមួយខកខានមិនបានទូទាត់ឬប្រគល់មូលបត្រ ដោយសារតែបញ្ហាប្រតិបត្តិការ ភាគីនោះត្រូវតែជូនដំណឹងភ្លាមទៅភាគីម្ខាងទៀតអំពីបញ្ហាដែលបានកើតឡើង ហើយទទួលខុសត្រូវចំពោះការខូចខាតផ្នែកហិរញ្ញវត្ថុដែលកើតឡើងដោយសារតែការខកខានមិនបានទូទាត់ ឬប្រគល់ ឱ្យទាន់ពេលវេលានោះ តាមលក្ខខណ្ឌនិងខចែងនៃកិច្ចសន្យា ។

ក្នុងករណីបានដឹងមុននូវហេតុការណ៍ខកខានអនុវត្តកិច្ចសន្យាមេ ភាគីម្ខាងទៀតត្រូវតែជូនដំណឹងទៅភាគីខកខានអំពីការបញ្ចប់មុនពេលកំណត់ នូវប្រតិបត្តិការទាំងអស់ក្រោមកិច្ចសន្យាមេ និងគណនាចំនួនបំណុលសុទ្ធតាមតម្លៃទីផ្សារនៃគ្រប់កាតព្វកិច្ចពាក់ព័ន្ធទាំងអស់របស់ប្រតិបត្តិការ ដែលកំពុងអនុវត្ត នៅថ្ងៃខកខាន ។ បំណុលសុទ្ធដែលនៅសល់នេះ ត្រូវតែប្រគល់ទៅឱ្យអភិបាលបណ្តោះអាសន្ន ឬអ្នកជម្រះបញ្ជី និងតុលាការដើម្បីដោះស្រាយ ដោយយោងទៅលើកាលៈទេសៈនៃការខកខាននោះ ។ ប្រសិនបើភាគីម្ខាងទៀត ត្រូវសងបំណុលសុទ្ធចុងក្រោយទៅឱ្យភាគីខកខាន ការទូទាត់សងត្រូវតែធ្វើទៅឱ្យអភិបាលបណ្តោះអាសន្ន ឬអ្នកជម្រះបញ្ជីនៃភាគីខកខាន ដែលជាការទូទាត់បំណុលនៅសល់ចុងក្រោយ ដែលត្រូវជំនួសឱ្យកាតព្វកិច្ចសុទ្ធទៅវិញទៅមក ដោយសារការបញ្ចប់មុនពេលកំណត់បណ្តាលមកពីការខកខាន ។

**ប្រការ ៥ .-**

ដើម្បីធានា កុំឱ្យមានការជំទាស់លើការគណនាសមតុល្យសុទ្ធចុងក្រោយ និងយន្តការនៃការជំនួសមូលបត្រក្នុងប្រតិបត្តិការទទួលទិញវិញក្រោមកិច្ចសន្យាមេ អ្នកចូលរួមក្នុងទីផ្សារត្រូវតែប្រើប្រាស់គំរូកិច្ចសន្យាមេដែលជាឧបសម្ព័ន្ធនៃប្រកាសនេះទាំងស្រុង ។

**ប្រការ ៦ .-**

ដើម្បីអនុវត្តន៍គោលនយោបាយរូបិយវត្ថុ ធនាគារជាតិនៃកម្ពុជានឹងតម្រូវឱ្យអ្នកចូលរួមក្នុងទីផ្សារចុះហត្ថ-លេខាជាមុនលើកិច្ចសន្យាមេសម្រាប់ប្រតិបត្តិការទទួលទិញវិញជាមួយធនាគារជាតិនៃកម្ពុជា ដើម្បីធ្វើប្រតិបត្តិការ

ទីផ្សារ ចំហរ ឬប្រតិបត្តិការអប្បហារ ។

**ប្រការ ៧ .-**

មុនពេលចុះហត្ថលេខាលើកិច្ចសន្យាមេសម្រាប់ប្រតិបត្តិការទទួលទិញវិញ អ្នកចូលរួមក្នុងទីផ្សារត្រូវតែធានាថា ពួកគេបានបង្កើតគោលនយោបាយ នីតិវិធី និងដំណើរការត្រួតពិនិត្យផ្ទៃក្នុងគ្រប់គ្រាន់ ក្នុងការវាយតម្លៃទីផ្សារ ពិនិត្យនិងគ្រប់គ្រងហានិភ័យគូភាគីរបស់ខ្លួន ដែលពាក់ព័ន្ធនឹងកិច្ចសន្យាមេ ឱ្យបានគ្រប់ជ្រុងជ្រោយ ។

ធនាគារជាតិនៃកម្ពុជានឹងចេញផ្សាយផងដែរ នូវសេចក្ដីណែនាំលើបទប្បញ្ញត្តិស្ដីអំពីការចុះកិច្ចបញ្ជិកាគណនេយ្យ និងរបាយការណ៍ចាំបាច់ដែលពាក់ព័ន្ធនឹងប្រតិបត្តិការទទួលទិញវិញ និងធ្វើបច្ចុប្បន្នកម្មជាបន្តបន្ទាប់លើទម្រង់របាយការណ៍តាមបទប្បញ្ញត្តិ ។

ធនាគារជាតិនៃកម្ពុជា នឹងចេញផ្សាយសេចក្ដីណែនាំបន្ថែមស្ដីពីការគណនាស្ថានភាពថ្លឹងហានិភ័យ ដែលពាក់ព័ន្ធដោយស្ថានភាពហានិភ័យនៃឥណទាននៅសល់ដែលមានការធានា ពាក់ព័ន្ធនឹងប្រតិបត្តិការទទួលទិញវិញ ។

**ប្រការ ៨ .-**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាព និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ៩ .-**

រាល់ប្រកាស ឬលិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ១០ .-**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។៚

រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ តុលា ឆ្នាំ២០០៩

**ជា-ចាន់តូ**

<u>កន្លែងទទួល:</u>

-ដូចប្រការ ៨

" ដើម្បីអនុវត្ត "

-កាលប្បវត្តិ

-ឯកសារ

<u>ចម្លងជូន:</u>

-សមាជិកក្រុមប្រឹក្សាភិបាល

-ទីស្ដីការគណៈរដ្ឋមន្ត្រី

" ដើម្បីជូនជ្រាបជាព័ត៌មាន "

-នាយកដ្ឋានរដ្ឋបាលទីស្ដីការគណៈរដ្ឋមន្ត្រី

"ដើម្បីចុះផ្សាយក្នុងរាជកិច្ច "

# កិច្ចសន្យាមេ
## សម្រាប់ប្រតិបត្តិការទទួលទិញវិញ
## របស់ធនាគារជាតិ នៃ កម្ពុជា

ភាគី ក :.........................

តំណាងពេញសិទ្ធិដោយលោក ..............................មានឋានៈជា.....................................................................និង

ភាគី ខ :.........................

តំណាងពេញសិទ្ធិដោយលោក ..............................មានឋានៈជា.....................................................................

ភាគី ក និង ភាគី ខ បានយល់ព្រមចុះហត្ថលេខានៅលើកិច្ចសន្យាមេក្នុងគោលបំណងដើម្បីធានាថា គ្រប់ប្រតិបត្តិការឱ្យខ្ចី/សុំខ្ចីត្រូវមានវត្ថុធានា។ វត្ថុធានាទាំងនេះត្រូវតែមានទម្រង់ជាឧបករណ៍បំណុលអាចជួញដូរបាន មានកំណត់កាលវសាន ដូចជា ប័ណ្ណ មូលបត្រ និងសញ្ញាប័ណ្ណ ដោយមិនរាប់បញ្ចូលនូវភាគហ៊ុននិងឧបករណ៍កូនកាត់ (Hybrid) អាចជួញដូរបាន ព្រមទាំងឧបករណ៍បំណុលអាចជួញដូរបានមិនមានកំណត់កាលវសាន ឬមូលបត្រដែលបានដកការប្រាក់មួយចំណែករួចហើយ (Stripped or perpetual debt instrument) ។

កិច្ចសន្យាមេនេះនឹងអនុវត្តដោយស្វ័យប្រវត្តិចំពោះរាល់ប្រតិបត្តិការទទួលទិញវិញ ដែលនឹងត្រូវធ្វើដោយភាគីនៃកិច្ចសន្យា លើកលែងតែភាគីទាំងពីរយល់ព្រមដកចេញនូវប្រតិបត្តិការជាក់លាក់ណាមួយក្នុងពេលអនាគត ឬក៏លុបចោលនូវសុពលភាពនៃកិច្ចសន្យាមេ។ កិច្ចសន្យាមេមិនត្រូវបានលុបចោល ដោយឯកតោភាគីទេ លើសពីនេះទៀត កិច្ចសន្យាមេនឹងនៅតែមានសុពលភាពពេញលេញ ដរាបណាប្រតិបត្តិការទាំងឡាយនៅក្រោមកិច្ចសន្យានេះនៅតែមានបន្ត ។

### ប្រការ១ : កម្មវត្ថុ និងគោលការណ៍ទូទៅ

១-១ : ក្នុងការចុះហត្ថលេខាលើកិច្ចសន្យាមេនៃប្រតិបត្តិការទទួលទិញវិញនេះ ភាគីទាំងពីរយល់ព្រមអនុវត្តតាមកម្មវត្ថុច្បាស់លាស់ទាំងឡាយ ដូចខាងក្រោម:

- ក្នុងករណីដែលកិច្ចសន្យាមេត្រូវបានបញ្ចប់មុនកាលកំណត់ គ្រប់ប្រតិបត្តិការទទួលទិញវិញនីមួយៗ ដែលត្រូវបានធ្វើរវាងភាគីទាំងពីរនៅក្រោមកិច្ចសន្យានេះ ត្រូវតែបានចាត់ទុកថាជាធាតុមួយនៃសំណុំប្រតិបត្តិការទាំងមូល និងដើម្បីគណនាចំនួនទូទាត់សុទ្ធនៃសមតុល្យ ដែលភាគីមួយជំពាក់ភាគីមួយទៀត។

- នៅពេលដែលភាគីណាមួយគ្មានលទ្ធភាពសង ភាគីម្ខាងទៀតមានសិទ្ធិពេញលេញក្នុងការបញ្ចប់រាល់ប្រតិបត្តិការក្រោមកិច្ចសន្យាមេ និងផាត់ទាត់រកចំនួនប្រាក់ជំពាក់សុទ្ធដោយភាគីណាមួយ គិតត្រឹមថ្ងៃដែលគ្មានលទ្ធភាពសងនោះ។

ฑน

- ចំនួនប្រាក់ជំពាក់សុទ្ធដោយភាគីណាមួយខាងលើនេះ នឹងត្រូវកំណត់ដោយតម្លៃសេដ្ឋកិច្ចផ្អែកលើមូលដ្ឋាននៃតម្លៃទីផ្សាររបស់មូលបត្រ លើរាល់ផ្នែកទិញ ឬលក់នៃប្រតិបត្តិការ រួមទាំងម៉ាជីនខល (Margin Calls) ដែលបានបង់ដោយភាគីទាំងពីរនៅពេលចាប់ផ្តើមអនុវត្តកិច្ចសន្យា។

- នៅពេលដែលភាគីណាមួយក្ស័យធន ភាគីទាំងពីរយល់ព្រមថា ចំនួនប្រាក់ជំពាក់សុទ្ធដោយភាគីណាមួយ គឺជាបំណុលតែមួយគត់ដែលត្រូវយកទៅទាមទារនៅតុលាការ ឬជាបំណុលតែមួយគត់ដែលត្រូវទាមទារពីភាគីម្ខាងទៀត ដោយអភិបាលបណ្តោះអាសន្នរបស់ភាគីដែលក្ស័យធន ឬដោយតុលាការ។ សមតុល្យបញ្ចប់ចុងក្រោយគឺជាបំណុលតែមួយគត់ដែលត្រូវទាមទារដោយភាគីណាមួយ។ រាល់បំណុលនៃប្រតិបត្តិការនិមួយៗក្រោមកិច្ចសន្យាមេ ត្រូវបានផុតរលត់នៅពេលដែលបានទូទាត់ ឬដែលរកឃើញចំនួនប្រាក់បំណុលសុទ្ធនោះ។

១-២ : ភាគីទាំងពីរព្រមព្រៀងថា ការកែប្រែលក្ខខណ្ឌ និងខចែងនៃកិច្ចសន្យាមេ អាចនឹងធ្វើទៅបាន ក៏ប៉ុន្តែការកែប្រែនេះត្រូវតែអនុលោមតាមគោលការណ៍ និងកម្មវត្ថុដែលបានចែងក្នុងប្រការ១នៃកិច្ចសន្យាមេនេះ។

១-៣ : នៅពេលដែលមានការព្រមព្រៀងគ្នាកែប្រែ ភាគីទាំងពីរត្រូវចុះហត្ថលេខាលើកិច្ចសន្យាបន្ថែមភ្ជាប់ជាមួយកិច្ចសន្យាមេ។ ក្នុងករណីនេះ លក្ខខណ្ឌ និងខចែងដែលមាននៅក្នុងកិច្ចសន្យាបន្ថែមនេះ ត្រូវចាត់ទុកជាអាទិភាពទៅលើលក្ខខណ្ឌ និងខចែងនៅក្នុងកិច្ចសន្យាមេ។

១-៤ : នៅពេលចុះកិច្ចសន្យាមេ ភាគីទាំងពីរដែលសុទ្ធតែអ្នកមានវិជ្ជាជីវៈ បានយល់ដឹងអំពីផលវិបាកទាំងឡាយដែលពាក់ព័ន្ធនឹងប្រតិបត្តិការទទួលទិញវិញដែលគ្រប់គ្រងដោយកិច្ចសន្យាមេ និងប្រកាសថា ត្រូវតែធ្វើសកម្មភាពដោយសុចរិតទៀងត្រង់។ លើសពីនេះទៀត តំណាងទាំងអស់ដែលបានចុះហត្ថលេខាលើកិច្ចសន្យាមេត្រូវតែទទួលបានការផ្ទេរសិទ្ធិអំណាចចាំបាច់ ដើម្បីបំពេញតួនាទីជួសមុខភាគីណាមួយដែលខ្លួនតំណាងឱ្យ។ ក្នុងន័យនេះ ភាគីទាំងពីរមិនអាចប្តឹងទៅតុលាការ ឬតាមមធ្យោបាយផ្សេងទៀតដើម្បីជំទាស់សុពលភាព ឬលុបចោលកិច្ចសន្យាមេបានឡើយ លើកលែងតែមានការព្រមព្រៀងគ្នារវាងភាគីទាំងពីរ។

## ប្រការ២ : និយមន័យ

ពាក្យមួយចំនួននៃកិច្ចសន្យាមេនេះ ត្រូវមាននិយមន័យដូចខាងក្រោម :

- **ប្រតិបត្តិការទទួលទិញវិញ :** ជាប្រតិបត្តិការណាមួយដែលត្រូវបានព្រមព្រៀងដោយទ្វេភាគីដែលក្នុងនោះ ភាគីអ្នកលក់យល់ព្រមលក់មូលបត្រដែលអាចទទួលយកបានឱ្យភាគីអ្នកទិញ ហើយយល់ព្រមផ្ទេរកម្មសិទ្ធិពេញលេញលើមូលបត្រនោះឱ្យអ្នកទិញដើម្បីធានាប្រាក់ដែលខ្លួនបានខ្ចី ដោយមានការសន្យាយ៉ាងម៉ឺងម៉ាត់ថា នឹងទិញយកវិញនូវមូលបត្រនោះនាកាលវសាននៃកិច្ចសន្យា (កាលបរិច្ឆេទទទួលទិញវិញ) ទៅតាមថ្ងៃដែលបានព្រមព្រៀងគ្នា (ថ្ងៃទទួលទិញវិញ) នៅពេលចាប់ផ្តើមប្រតិបត្តិការទទួលទិញវិញ។ ប្រតិបត្តិការទិញនិងលក់នេះមិនអាចផ្តាច់ចេញពីគ្នាបានឡើយ ដោយសារតែប្រតិបត្តិការទាំង

ពីរនេះជាការធានាឱ្យគ្នាទៅវិញទៅមក ក្នុងគោលបំណងកាត់បន្ថយជាអតិបរមា ឬលុបបំបាត់ចោលនូវហានិភ័យនៃគូភាគី ដែលកើតឡើងពីភាគីណាមួយក្នុងចំណោមភាគីទាំងពីរ ។

- **ហេតុការណ៍ខកខានក្នុងការបំពេញកាតព្វកិច្ច** (Event of Default) :ត្រូវបានចាត់ទុកថាហេតុការណ៍ខកខានក្នុងការអនុវត្តកិច្ចសន្យាមេ នៅពេលដែលមានករណីដូចខាងក្រោម :
  - តុលាការបានសម្រេចដាក់ភាគីណាមួយឱ្យស្ថិតនៅក្រោមនីតិវិធីក្ស័យធន
  - អាជ្ញាធរត្រួតពិនិត្យសម្រេចដកហូតអាជ្ញាប័ណ្ណរបស់ភាគីណាមួយ
  - ការមិនអាចសងបំណុលបានរបស់អ្នកបោះផ្សាយមូលបត្រដែលបានលក់ចេញ
  - ការទូទាត់សងប្រាក់ ឬការប្រគល់មូលបត្រ មិនទាន់ពេលវេលា ដែលកើតមកពីទំនាក់ទំនងធុរៈកិច្ចរវាងភាគីទាំងពីរ ទោះជាស្ថិតក្រោមកិច្ចសន្យាមេនេះ ឬក្រោមប្រតិបត្តិការដទៃទៀតក៏ដោយ លើកលែងតែការខកខាននេះកើតចេញពីកំហុសផ្នែកបច្ចេកទេសដែលត្រូវបានដោះស្រាយលឿនបំផុត និងភាគីទាំងពីរមិនមានបញ្ហាខាងផ្លូវច្បាប់ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួន
  - ការព្យួរ ឬការដកភាគីណាមួយពីសភាជាត់ទាត់ ឬពីប្រព័ន្ធទូទាត់សងប្រាក់
  - ការខកខានមិនទូទាត់សងប្រាក់ដែលកើតចេញពីទំនាក់ទំនងធុរៈកិច្ចរវាងភាគីណាមួយនៃភាគីទាំងពីរជាមួយនឹងតតិយភាគីលើកលែងតែការមិនបានទូទាត់សងប្រាក់នោះកើតចេញចេញពីកំហុសផ្នែកបច្ចេកទេស ភាគីទាំងពីរមិនមានបញ្ហាខាងផ្លូវច្បាប់ក្នុងការទូទាត់សងប្រាក់ និងការមិនទូទាត់សងប្រាក់នេះជាសញ្ញានៃការចុះថយនៃស្ថានភាពសាធនភាព និង
  - ករណីប្រធានសក្តិដទៃទៀតកំណត់ដោយភាគីទាំងពីរ ដែលភាពធ្ងន់ធ្ងរនៃករណីប្រធានសក្តិនោះ នាំឱ្យមានការបញ្ចប់មុនកាលកំណត់នូវប្រតិបត្តិការទទួលទិញវិញទាំងអស់ក្រោមកិច្ចសន្យាមេ ព្រមទាំងកិច្ចសន្យាមេខ្លួនឯងផងដែរ និងជាត់ទាត់បញ្ចប់នូវរាល់កាតព្វកិច្ចហិរញ្ញវត្ថុរបស់ភាគីទាំងពីរ ។

- **ការបញ្ជាក់** (Confirmation): ជាឯកសារលាយលក្ខណ៍អក្សរ ចេញដោយភាគីណាមួយដើម្បីទទួលស្គាល់ការសន្យារបស់ខ្លួនទៅឱ្យភាគីមួយទៀត និងប្តេជ្ញាបំពេញរាល់កាតព្វកិច្ចដែលកើតចេញពីប្រតិបត្តិការទទួលទិញវិញក្រោមកិច្ចសន្យាមេ ។ ការបញ្ជាក់ត្រូវតែបានធ្វើឡើងដោយភាគីនីមួយៗ ដើម្បីបញ្ជាក់អំពីការព្រមព្រៀងគ្នា ជាពិសេស នៅពេលដែលមានប្រតិបត្តិការទទួលទិញវិញថ្មី ការកែប្រែចរិតលក្ខណៈធំៗណាមួយ ការជំនួសនូវមូលបត្រដែលបានលក់ ឬការព្រមព្រៀងណាមួយ ដើម្បីកែតម្រូវតម្លៃសេដ្ឋកិច្ចនៃប្រតិបត្តិការទទួលទិញវិញ និងបន្ទាប់មកម៉ាជីនដែលត្រូវបង់ ឬត្រូវទទួល ឬហ៊ែខាត់ (Haircut) ។ ចរិតលក្ខណៈធំៗត្រូវមានជាពិសេសនូវកាលវសានកាលបរិច្ឆេទប្រតិបត្តិការ ថ្ងៃប្រសិទ្ធិភាព អត្រាការប្រាក់ រូបិយប័ណ្ណ រូបិយប័ណ្ណគោល អត្តសញ្ញាណនៃមូលបត្រ មូលបត្រដែលតម្រូវឱ្យបន្ថែមហ៊ែខាត់ (Haircut) កំរិតកំណត់នៃម៉ាជីនខល (Margin Calls) និងម៉ាជីនខលដែលត្រូវបង់ ឬត្រូវទទួលក្រោមកិច្ចសន្យាមេ និងថ្ងៃទទួលទិញវិញ ។ ភាគីនីមួយៗ ត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់អំពីប្រតិបត្តិការថ្មី និង

យោងកិច្ចសន្យាមេ ឬការកែប្រែណាមួយដែលបានព្រមព្រៀងជាមួយភាគីម្ខាងទៀត ដោយយកតម្កល់ទុកដាក់។ កិច្ចសន្យាមេអាចចាត់ទុកថាមានលក្ខណៈពេញលេញសម្រាប់ភាគីទាំងពីរ លុះត្រាតែលក្ខខណ្ឌនៃការបញ្ជាក់ដែលត្រូវបានចេញ ឆ្លើយតបពេញលេញទៅនឹងលក្ខខណ្ឌនៃការបញ្ជាក់ ដែលបានទទួល។

- **កិច្ចសន្យាបំពេញបន្ថែម** : ជាការកែប្រែណាមួយទៅលើកិច្ចសន្យាមេ ដែលបានព្រមព្រៀងរវាងភាគីទាំងពីរ។ ការកែប្រែនេះត្រូវតែអនុលោមតាមគោលការណ៍ទូទៅ និងកម្មវត្ថុនានាដែលបានចែងក្នុងប្រការ១ នៃកិច្ចសន្យាមេនេះ។ ការកែប្រែដែលត្រូវបានធ្វើឡើងជាផ្លូវការ ដោយមានហត្ថលេខារបស់ភាគីទាំងពីរលើកិច្ចសន្យាបំពេញបន្ថែមនោះ ត្រូវតែបានអនុវត្តជាអាទិភាព ដោយសារថា កិច្ចសន្យាបំពេញបន្ថែមនោះមានអានុភាពលើ ឬនាំឱ្យមានការលើកលែងបញ្ញត្តិទូទៅនៃកិច្ចសន្យាមេ។

- **ហ៊ែរ៉ខាត់** (Haircut) : គឺជាការតម្រូវឱ្យដាក់មូលបត្របន្ថែមសម្រាប់ធានា ប្រតិបត្តិការទទួលទិញវិញ ហើយការដាក់បន្ថែមនេះត្រូវបានគិតជាភាគរយ។ ហ៊ែរ៉ខាត មានគោលបំណងធានាដល់ការប្រែប្រួលថ្លៃនៃមូលបត្រដែលបានលក់ ក្នុងរយៈពេលនៃប្រតិបត្តិការទទួលទិញវិញ និងដើម្បីចៀសវាងការកែតម្រូវខាសម៉ាជីនញឹកញាប់។ ដូច្នេះ ហ៊ែរ៉ខាត់ គឺជាការដាក់វត្ថុធានាលើសពីពេលចាប់ផ្តើមនៃប្រតិបត្តិការទទួលទិញវិញ និងនាំទៅកែតម្រូវថ្លៃមូលបត្រ។

- **ការកែតម្រូវថ្លៃមូលបត្រ** ( Adjusted Securities'Price ) : ថ្លៃមូលបត្រ គឺជាថ្លៃគោល ដែលយោងតាមនោះ មូលបត្រអាចទទួលយកបាននៃប្រតិបត្តិការទទួលទិញវិញ ត្រូវបានជួញដូរនៅក្នុងទីផ្សារ។ សម្រាប់គោលបំណងនៃកិច្ចសន្យានេះ ភាគីទាំងពីរព្រមព្រៀងគ្នាប្រើប្រាស់ថ្លៃមធ្យមទីផ្សារ (មធ្យមភាគនៃថ្លៃទិញ-លក់)។ ការកែតម្រូវថ្លៃមូលបត្រ ឆ្លុះបញ្ចាំងអំពីហ៊ែរ៉ខាត់ដែលភាគីទាំងពីរបានព្រមព្រៀងគ្នាមានគោលបំណងធានាដល់ការប្រែប្រួលនៃថ្លៃមូលបត្រដែលបានលក់ ក្នុងរយៈពេលនៃប្រតិបត្តិការទទួលទិញវិញ និងដើម្បីចៀសវាងការកែតម្រូវខាសម៉ាជីនញឹកញាប់។

- **ម៉ាជីន** (Margin) : គឺជាផលបូកនៃប្រាក់តម្កល់ជាមូលបត្រ (Securities Margin) និងខាសម៉ាជីន (Cash Margin) ក្នុងចំណុចណាមួយនៃរយៈពេលប្រតិបត្តិការ។ ប្រាក់តម្កល់ជាមូលបត្រ (Securities Margin) សមមូលទៅនឹងតម្លៃសេដ្ឋកិច្ច ឬតម្លៃទីផ្សារ នៃហ៊ែរ៉ខាត់ (Haircut) នាពេលផ្តើមប្រតិបត្តិការ។

- **ខាសម៉ាជីន** ( Cash Margin) : ជាចំនួនប្រាក់ដែលទូទាត់សងដោយភាគីមួយឱ្យភាគីមួយទៀត ដើម្បីបង្កើតឡើងវិញនូវសមតុល្យនៃស្ថានភាពហានិភ័យឥណទាន ឬហានិភ័យគូភាគី បន្ទាប់ពីមានចំណេញ ឬខាត ដោយសារតែការវាយតម្លៃឡើងវិញនៃមូលបត្រដែលបានលក់ក្រោមប្រតិបត្តិការទទួលទទួលទិញវិញ។

- **ម៉ាជីនខល** (Margin Calls) : ជាប្រាក់តម្កល់ជាសាច់ប្រាក់ដែលបានទាមទារដោយភាគីណាមួយ ដើម្បីកែតម្រូវឡើងវិញនូវម៉ាជីន។ អាស្រ័យទៅលើការព្រមព្រៀងរវាងភាគីទាំងពីរ ម៉ាជីនខលអាចជាសាច់ប្រាក់ឬជាការលក់បន្ថែមនូវមូលប័ត្រដែលមានលក្ខណៈដូចគ្នា។ ជាទូទៅ ម៉ាជីនខលត្រូវមាន

ក៏វិតកំណត់ដែលបានព្រមព្រៀងដោយភាគីទាំងពីរ ។

**- កាលបរិច្ឆេទជួញដូរ** : ជាកាលបរិច្ឆេទដែលភាគីទាំងពីរ ព្រមព្រៀងធ្វើប្រតិបត្តិការទទួលទិញវិញថ្មី ហើយក៏ជាកាលបរិច្ឆេទដែលភាគីទាំងពីរត្រូវធ្វើការបញ្ជាក់ផងដែរ ។

**- កាលបរិច្ឆេទទិញ** : ជាកាលបរិច្ឆេទនៃកិច្ចសន្យាដែលមូលបត្រត្រូវបានលក់ទៅឱ្យភាគីអ្នកឱ្យខ្ចីប្រាក់ ហើយក៏ជាពេលចាប់ផ្តើមគិតការប្រាក់បង្គរសម្រាប់ប្រតិបត្តិការទទួលទិញវិញផងដែរ ។

**- កាលបរិច្ឆេទទទួលទិញវិញ ឬកាលវសាននៃប្រតិបត្តិការទទួលទិញវិញ** : ជាកាលវសាននៃកិច្ចសន្យាដែលប្រតិបត្តិការទទួលទិញវិញត្រូវបានបញ្ចប់ ការប្រាក់បង្គរត្រូវបានបញ្ឈប់ ភាគីខ្ចីប្រាក់សន្យាទិញយកវិញនូវមូលបត្រដែលបានលក់ ដោយទូទាត់សងវិញនូវប្រាក់ដែលបានខ្ចី (ប្រាក់ដើម) និងការប្រាក់បង្គរតាមអត្រាទទួលទិញវិញ ។

**- កាលបរិច្ឆេទវាយតម្លៃ** : ជាកាលបរិច្ឆេទដែលភាគីទាំងពីរសម្រេចៈ

១) ធ្វើការវាយតម្លៃសេដ្ឋកិច្ចទៅលើប្រតិបត្តិការទទួលទិញវិញ ដើម្បីកំណត់នូវតម្លៃនៃម៉ាជីន និងដើម្បីកែតម្រូវតម្លៃនេះតាមរយៈម៉ាជីនខល និងការទូទាត់ ឬ

២) ដើម្បីគណនាតម្លៃសុទ្ធនូវរាល់គណនេយ្យ និងបំណុល ដែលស្ថិតក្រោមកិច្ចសន្យាមេនេះ ក្នុងគោលបំណងបញ្ចប់មុនកាលវសានឬដោយសារតែការខកខានមិនបានសងបំណុលដោយភាគីណាមួយ ។

**- រូបិយប័ណ្ណ** : ជារូបិយប័ណ្ណដែលអាចផ្ទេរប្តូរ និងជួញដូរបានដោយសេរី រួមទាំងរូបិយវត្ថុក្នុងស្រុកផង ។ ក្នុងករណីដែលមូលបត្រត្រូវបានចេញផ្សាយជារូបិយប័ណ្ណផ្សេងខុសពីរូបិយប័ណ្ណដែលបានខ្ចី ភាគីទាំងពីរត្រូវតែប្រើរូបិយប័ណ្ណគោលមួយដើម្បីវាយតម្លៃឡើងវិញនូវមូលបត្រ និងការទូទាត់ម៉ាជីនខល ។ ការគណនា និងដំណើរការទូទាត់នេះ ត្រូវតែធ្វើឡើងដោយប្រើអត្រាប្តូរប្រាក់ផ្លូវការប្រចាំថ្ងៃ ដែលកំណត់ដោយធនាគារជាតិនៃកម្ពុជា ។

**- រូបិយប័ណ្ណគោល** : ជារូបិយប័ណ្ណដែលភាគីទាំងពីរបានព្រមព្រៀងប្រើប្រាស់សម្រាប់ដំណើរការវាយតម្លៃ ការទូទាត់សងនូវប្រាក់តម្កល់ជាសាច់ប្រាក់ និងការកំណត់នូវការជាត់ទាត់សមតុល្យសុទ្ធ ក្នុងករណីដែលមានការខកខានមិនបានទូទាត់ ឬការបញ្ចប់ដោយភាគីទាំងពីរនូវរាល់ប្រតិបត្តិការទទួលទិញវិញ ដែលស្ថិតនៅក្រោមកិច្ចសន្យាមេ ឬការបញ្ចប់នូវកិច្ចសន្យាមេខ្លួនឯង ។

**-អត្រាការប្រាក់ប្រតិបត្តិការទទួលទិញវិញ**: ជាអត្រាការប្រាក់ដែលត្រូវបង់ដោយភាគីខ្ចីប្រាក់ "អ្នកលក់មូលបត្រ" ឱ្យទៅភាគីឱ្យខ្ចី "អ្នកទិញមូលបត្រ" គិតលើប្រាក់ដើមដែលបានឱ្យខ្ចី ចាប់ពីថ្ងៃផ្តើមប្រតិបត្តិការរហូតដល់កាលវសាន ។

**- អត្រាការប្រាក់គោល** : ជាអត្រាការប្រាក់ដែលភាគីទាំងពីរបានព្រមព្រៀងគ្នា ហើយដែលត្រូវបានអនុវត្តតាមសមាមាត្រលើរាល់ការទូទាត់សងខាសម៉ាជីន ដោយភាគីណាមួយទៅភាគីមួយទៀត ។ ប្រសិនបើគ្មានការកំណត់អត្រាការប្រាក់គោលនេះនៅក្នុងកិច្ចសន្យាទទួលទិញវិញ ក្រោមកិច្ចសន្យាមេនេះទេ ខាសម៉ាជីនបានចាត់ទុកថាគ្មានការប្រាក់ ។

- **មូលបត្រ** : ជារាល់ឧបករណ៍បំណុលអាចជួញដូរបាន ដែលភាគីទាំងពីរបានព្រមព្រៀងប្រើសម្រាប់ប្រតិបត្តិការទទួលទិញវិញ។ យោងតាមលក្ខខណ្ឌដែលបានព្រមព្រៀង ភាគីទាំងពីរអាចព្រមព្រៀងផងដែរថា មូលបត្រមួយអាចត្រូវបានជំនួសដោយមូលបត្រមួយផ្សេងទៀត ក្នុងអំឡុងពេលប្រតិបត្តិការទទួលទិញវិញ។ ក៏ប៉ុន្តែ ការជំនួសត្រូវតែមានការបញ្ជាក់ពីភាគីទាំងពីរ ហើយសិទ្ធិនៃការជំនួសមិនត្រូវកំណត់ដោយភាគីដែលផ្តួចផ្តើមការជំនួសនោះឡើយ។

- **ការជំនួសមូលបត្រ** : ក្នុងអំឡុងពេលអនុវត្តប្រតិបត្តិការទទួលទិញវិញ ដែលស្ថិតក្រោមកិច្ចសន្យាមេ ភាគីទាំងពីរអាចព្រមព្រៀងថា មូលបត្រដែលត្រូវប្រគល់អាចជាមូលបត្រផ្សេងក្រៅពីមូលបត្រដែលបានលក់ដំបូង។ ការជំនួសនេះ មិនត្រូវធ្វើឡើងដោយអ្នកលក់មូលបត្រជាឯកតោភាគីឡើយ។ ភាគីទាំងពីរ ត្រូវយល់ព្រម និងបញ្ជាក់ថាមូលបត្រដែលត្រូវជំនួសនោះអាចទទួលយកបាន។ តាមវិធានជាទូទៅ ការជំនួសបែបនេះ នឹងធ្វើឱ្យមានការវាយតម្លៃឡើងវិញនូវប្រតិបត្តិការ និងកែតម្រូវឡើងវិញនូវម៉ាជីន ។

- **ការប្រគល់មូលបត្រ** :ប្រតិបត្តិការទទួលទិញវិញដែលស្ថិតក្រោមកិច្ចសន្យាមេ នាំឱ្យមានការផ្ទេរកម្មសិទ្ធិពេញលេញដោយគ្មានការរារាំងលើមូលបត្រទៅឱ្យភាគីឱ្យខ្ចី ចាប់ពីកាលបរិច្ឆេទទិញរហូតដល់កាលវសាននៃប្រតិបត្តិការ។ ការផ្ទេរកម្មសិទ្ធិនេះ ត្រូវតែកត់ត្រាក្នុងបញ្ជីភាគីលក់មូលបត្រ។ ជាទូទៅការផ្ទេរកម្មសិទ្ធិនេះ នាំឱ្យមានការផ្ទេរមូលបត្រទៅក្នុងគណនីរក្សាមូលបត្ររបស់អ្នកឱ្យខ្ចី ដែលចង្អុលបង្ហាញដោយភាគីទិញមូលបត្រ។ ក៏ប៉ុន្តែ ដោយសារប្រតិបត្តិការទិញយកវិញមានរយៈពេលខ្លី ហើយការផ្ទេរមូលបត្រពាក់ព័ន្ធនឹងចំណាយប្រតិបត្តិការ ភាគីទាំងពីរអាចព្រមព្រៀងថា ភាគីខ្ចីប្រាក់អាចរក្សាទុកមូលបត្រក្នុងនាមភាគីឱ្យខ្ចីដែលទិញមូលបត្រនោះ។ ក្នុងករណីនេះ ភាគីខ្ចីប្រាក់ដើរតួនាទីជាអ្នកថែរក្សាមូលបត្ររបស់ភាគីទិញ។ ភាគីខ្ចីប្រាក់ត្រូវបានហាមឃាត់មិនឱ្យលក់នូវមូលបត្រនោះម្តងទៀត ភាគីខ្ចីប្រាក់ត្រូវចុះកិច្ចបញ្ជិកានៅក្នុងខ្ទង់ក្រៅតារាងតុល្យការ និងកត់ត្រាជាទ្រព្យសម្បត្តិពេញលេញរបស់ភាគីឱ្យខ្ចី។ ក្នុងអំឡុងពេលអនុវត្តប្រតិបត្តិការទទួលទិញវិញ ភាគីឱ្យខ្ចីអាចតម្រូវឱ្យភាគីខ្ចីប្រាក់ប្រគល់មូលបត្រតាមសំណើរបស់ខ្លួន។ បើអ្នកខ្ចីប្រាក់មិនអាចប្រគល់មូលបត្រទៅឱ្យភាគីឱ្យខ្ចីនោះទេ ករណីនេះត្រូវបានចាត់ទុកថា ជាហេតុការណ៍ខកខាន។ ត្រូវបានចាត់ទុកថាជាហេតុការណ៍ខកខានមិនបានអនុវត្តតាមកិច្ចសន្យាផងដែរ ប្រសិនបើភាគីឱ្យខ្ចីរកឃើញថា គ្មានមូលបត្រដែលបានលក់ ហើយការអះអាងរបស់ភាគីខ្ចីប្រាក់ជាចេតនាមិនស្មោះត្រង់ ក្នុងគោលបំណងឆបោកភាគីឱ្យខ្ចីប្រាក់ និងចេតនាបំភ័ន្តអំពីចរិតលក្ខណៈ តម្លៃ ឬអត្ថិភាពរបស់មូលបត្រដែលបានលក់។

- **ហានិភ័យនៃការទូទាត់** : ជាហានិភ័យដែលកើតឡើងចំពោះភាគីលក់មូលបត្រ ដោយមិនបានទទួលការទូទាត់សងប្រាក់ នៅពេលដែលខ្លួនបានធ្វើការផ្ទេរដោយមិនអាចលប់ចោលបាននូវមូលបត្រជាស្ថាពរទៅឱ្យភាគីទិញមូលបត្ររួចហើយ ។

- **ហានិភ័យនៃការប្រគល់** : ជាហានិភ័យដែលកើតឡើងចំពោះភាគីទិញមូលបត្រ ដោយមិនបានទទួលមូលបត្រនៅពេលដែលខ្លួនបានចេញបញ្ជាទូទាត់ដែលមិនអាចលប់ចោលបាន ដើម្បីសងប្រាក់

ជាស្ថាពរទៅឱ្យភាគីលក់មូលបត្ររួចហើយ ។

- **ការទូទាត់ទល់នឹងការប្រគល់** : ជាការតម្រូវរបស់ភាគីទាំងពីរ ដែលបានព្រមព្រៀងដើម្បីផ្តល់លក្ខខណ្ឌលើការទូទាត់ទល់នឹងការប្រគល់ដោយប្រសិទ្ធភាព ដើម្បីលុបបំបាត់នូវហានិភ័យនៃការទូទាត់ និងហានិភ័យនៃការប្រគល់ពាក់ព័ន្ធនឹងប្រតិបត្តិការទទួលទិញវិញ ។

- **អ្នកថែរក្សា** : ជាអន្តរការីហិរញ្ញវត្ថុ ឬស្ថាប័នហិរញ្ញវត្ថុ ដែលផ្តល់សេវាថែរក្សាសុវត្ថិភាពឧបករណ៍អាចជួញដូរបាន។ អ្នកថែរក្សាបំពេញតួនាទីក្នុងនាម និងអនុវត្តតាមបញ្ជារបស់ម្ចាស់ឧបករណ៍។ អ្នកថែរក្សាមិនត្រូវលក់ឧបករណ៍អាចជួញដូរបានដែលបានដាក់ផ្ញើ ដោយគ្មានបញ្ជាជាផ្លូវការពីម្ចាស់គណនីឡើយ ។

## ប្រការ៣ : មូលបត្រអាចទទួលយកបាន/ការជំនួសមូលបត្រ

### ៣-១ មូលបត្រអាចទទួលបាន (Eligible Security)

ដើម្បីអាចធ្វើប្រតិបត្តិការទទួលទិញវិញក្រោមវិធានកិច្ចសន្យាមេបាន មូលបត្រដែលត្រូវលក់ ឬទិញត្រឡប់វិញត្រូវតែស្ថិតក្នុងទម្រង់ជាឧបករណ៍បំណុលអាចជួញដូរបាន ដោយមានកំណត់នូវកាលវសាន ដូចជា លិខិតដែលចេញដោយធនាគារជាតិនៃកម្ពុជា ប័ណ្ណបំណុលរយៈពេលមធ្យម មូលបត្រ និងសញ្ញាប័ណ្ណ តែមិនរាប់បញ្ចូលនូវភាគហ៊ុន និងឧបករណ៍ជួញដូរមានលក្ខណៈជាកូនកាត់ (Hybrid ) ព្រមទាំងឧបករណ៍បំណុលអាចជួញដូរបានមិនមានកំណត់កាលវសាន ឬ មូលបត្រដែលបានដកការប្រាក់មួយមួយចំណែក (Stripped or perpetual debt instrument) ។

មូលបត្រអាចជួញដូរបាននោះ ត្រូវតែបានជួញដូរនៅក្នុងទីផ្សារសាច់ប្រាក់ងាយស្រួល អាចជាទីផ្សារដែលបានរៀបចំឬទីផ្សារវិលងបញ្ជរ (OTC) ដោយមានការកំណត់ថ្លៃ (price quotations) ប្រចាំថ្ងៃដែលធ្វើឱ្យងាយស្រួលទទួលបានដោយភាគីទាំងពីរ ។ ភាគីទាំងពីរអាចបង្កើតបញ្ជីសង្ខេបនៃមូលបត្រអាចជួញដូរបាន ដែលត្រូវភ្ជាប់ជាមួយកិច្ចសន្យាមេ និងត្រូវបានចុះហត្ថលេខាដោយភាគីទាំងពីរ ។

### ៣-២ ការជំនួសមូលបត្រ

នៅអំឡុងពេលអនុវត្តប្រតិបត្តិការទទួលទិញវិញ ភាគីទាំងពីរអាចព្រមព្រៀងជំនួសមូលបត្រមួយដោយមូលបត្រមួយទៀតបាន។ ការព្រមព្រៀងនេះត្រូវតែបានបញ្ជាក់ជាលាយលក្ខណ៍អក្សរដោយភាគីទាំងពីរ ហើយដាច់ខាតមិនត្រូវសន្មតដោយភាគីតែម្ខាងឡើយ ។

ក៏ប៉ុន្តែ ការជំនួសនេះគឺជាការផ្លាស់ប្តូរមូលបត្រដែលបានលក់ពីដំបូង ដោយមូលបត្រដែលមានលក្ខណៈនិងតម្លៃសេដ្ឋកិច្ចប្រហាក់ប្រហែលគ្នា យ៉ាងហោចណាស់ក៏សមមូលទៅនឹងមូលបត្រដែលត្រូវបានផ្លាស់ប្តូរនោះដែរ ។

ការជំនួសត្រូវបានធ្វើឡើងដោយការប្រគល់មូលបត្រថ្មីទៅឱ្យភាគីឱ្យខ្ចី ដែលត្រូវប្រគល់វិញនូវមូលបត្រដែលបានលក់លើកដំបូងទៅភាគីខ្ចីប្រាក់។ ការជំនួសមូលបត្រមិនមានការប៉ះពាល់ខាងផ្លូវច្បាប់

ឬខាងកិច្ចសន្យាទៅលើកាតព្វកិច្ចរបស់ភាគីទាំងពីរឡើយ ។ ក៏ប៉ុន្តែ ការជំនួសនេះអាចនាំឱ្យភាគីទាំងពីរ វាយតម្លៃឡើងវិញនូវប្រតិបត្តិការទទួលទិញវិញ និងកែតម្រូវម៉ាជីនទៅតាមនោះ ។

## ប្រការ៤ : ហេតុការណ៍ដែលមានឥទ្ធិពលលើមូលបត្រ ក្នុងពេលធ្វើប្រតិបត្តិការទទួលទិញវិញ

ជាវិធានទូទៅ ភាគីទាំងពីរព្រមព្រៀងនិងសន្យាថាមិនលក់ ឬមិនទិញវិញនូវមូលបត្រដែលអាចត្រូវបានសងរំលោះ ឬសងជាគូប៉ុងនៅក្នុងរយៈកាលនៃប្រតិបត្តិការទទួលទិញវិញ ក្រោមកិច្ចសន្យាមេនេះឡើយ ។

ក៏ប៉ុន្តែ បើមូលបត្រត្រូវបានសងជាគូប៉ុងនៅក្នុងអំឡុងពេលនៃប្រតិបត្តិការទទួលទិញវិញ គូប៉ុងនោះត្រូវតែបានសងទៅឱ្យភាគីខ្ចីប្រាក់វិញ លើកលែងតែមានខចែងផ្សេងពីនេះ ។

បើមូលបត្រត្រូវបានសងរំលោះមុនកាលវសាននៃប្រតិបត្តិការទទួលទិញវិញ ភាគីខ្ចីប្រាក់ត្រូវជំនួសមូលបត្រអាចជួញដូរបានសំរាប់ការរំលោះនោះ ។ បន្ថែមលើនេះ ប្រសិនបើភាគីឱ្យខ្ចីប្រាក់ត្រូវតែសងមូលបត្រវិញ ភាគីឱ្យខ្ចីប្រាក់នោះត្រូវផ្ទេរចំនួនប្រាក់រំលោះដែលទទួលបាននោះទៅឱ្យភាគីខ្ចីប្រាក់នៅពេលដែលការជំនួសមូលបត្រត្រូវបានព្រមព្រៀងគ្នា ។

## ប្រការ៥ : ការសម្រេចពេញលេញ/ការបញ្ជាក់នៃប្រតិបត្តិការទទួលទិញវិញ

ប្រតិបត្តិការទទួលទិញវិញ ត្រូវបានចាត់ទុកថាសម្រេចពេញលេញនៅពេលដែលភាគីទាំងពីរបានព្រមព្រៀងគ្នាលើរាល់ចរិតលក្ខណៈនៃប្រតិបត្តិការនេះ ។ ក៏ប៉ុន្តែ ប្រតិបត្តិការនេះត្រូវតែបានបញ្ជាក់ជាលាយលក្ខណ៍អក្សរដោយភាគីទាំងពីរ ។ កាលបរិច្ឆេទដែលក្នុងនោះប្រតិបត្តិការទទួលទិញវិញត្រូវបានចរចា និងសម្រេច គឺជាកាលបរិច្ឆេទនៃប្រតិបត្តិការ (Transaction Date) ។

ភាគីទាំងពីរត្រូវត្រួតពិនិត្យឱ្យបានលឿនបំផុតលើការបញ្ជាក់ ដែលចេញដោយភាគីម្ខាងទៀត ដើម្បីរកឱ្យឃើញនូវភាពខុសគ្នា និងកំហុសជាសក្តានុពល ។ ភាគីទាំងពីរប្តេជ្ញាដោះស្រាយភាពខុសគ្នា និងកំហុសទាំងនោះជាបន្ទាន់ ដោយសុច្ឆរិតនិងមិត្តភាព ។ ភាគីដែលចេញការបញ្ជាក់ខុសត្រូវតែចេញការបញ្ជាក់ថ្មីឡើងវិញភ្លាម ក្នុងករណីដែលបញ្ហាអាចត្រូវបានដោះស្រាយដោយភាគីទាំងពីរ ។ ដើម្បីសម្រួលដល់ការដោះស្រាយទំនាស់ ភាគីទាំងពីរប្តេជ្ញានឹងផ្តល់និងផ្លាស់ប្តូរគ្រប់មធ្យោបាយជាភស្តុតាងទាំងអស់ ដូចជា សក្ខីបត្រជួញដូរ កំណត់ត្រា ការថតសម្លេង បញ្ជារបស់ការិយាល័យជួរមុខចេញឱ្យទៅការិយាល័យជួរក្រោយ និងឯកសារផ្សេងៗទៀតដែលយល់ថាចាំបាច់ ។

ភាគីទាំងពីរចាត់ទុកថា រាល់ប្រតិបត្តិការទទួលទិញវិញត្រូវតែស្ថិតនៅក្រោមកិច្ចសន្យាមេ លើកលែងតែមានការបញ្ជាក់ផ្សេងពីនេះ ។ រាល់ប្រតិបត្តិការទទួលទិញវិញរវាងភាគីទាំងពីរត្រូវបានចាត់ទុកថាជាសមាសធាតុនៃសំណុំប្រតិបត្តិការដែលត្រូវតែបានទូទាត់សរុប នៅក្នុងករណីនៃការបញ្ចប់កិច្ចសន្យាមុនកាលកំណត់ និងដើម្បីគណនាចំនួនបំណុលសុទ្ធសរុប ក្នុងគោលបំណងកំណត់នូវសមតុល្យចុងក្រោយដែលភាគីមួយជំពាក់ភាគីមួយទៀត ។

## ប្រការ៦ : ការប្រគល់និងការផ្ទេរ មូលបត្រ

ចាប់ពីថ្ងៃទិញវិញរហូតដល់កាលវសាន ភាគីឱ្យខ្ចីប្រាក់ត្រូវបានចាត់ទុកថាជាម្ចាស់កម្មសិទ្ធិតែមួយគត់នៃមូលបត្រដែលត្រូវបានលក់ឱ្យខ្លួន ដែលជាកម្មសិទ្ធិគ្មានការរារាំងលើមូលបត្រដែលបានទិញ។ ជាវិធានទូទៅ ភាគីខ្ចីប្រាក់ត្រូវផ្ទេរមូលបត្រទៅក្នុងគណនីថែរក្សាមូលបត្ររបស់ភាគីឱ្យខ្ចីប្រាក់ ឬទៅក្នុងគណនីផ្សេងទៀតដែលកំណត់ដោយភាគីឱ្យខ្ចីប្រាក់។

នៅកាលវសាន ភាគីឱ្យខ្ចីប្រាក់ត្រូវប្រគល់មូលបត្រទៅឱ្យភាគីខ្ចីប្រាក់វិញ រីឯភាគីខ្ចីប្រាក់ត្រូវទូទាត់សងនូវចំនួនប្រាក់ថ្លៃទិញវិញដូចដែលបានព្រមព្រៀង រួមទាំងការប្រាក់បង្គរក្នុងអំឡុងពេលធ្វើប្រតិបត្តិការទៅភាគីឱ្យខ្ចីប្រាក់។

ភាគីទាំងពីរអាចព្រមព្រៀងថា មូលបត្រមិនចាំបាច់ផ្ទេរទៅឱ្យភាគីឱ្យខ្ចីក៏បាន។ ក្នុងកាលៈទេសៈនេះ ភាគីខ្ចីប្រាក់អាចដើរតួជាអ្នកថែរក្សាមូលបត្រជំនួសភាគីឱ្យខ្ចីប្រាក់ ឬភាគីទិញមូលបត្រ។ ប៉ុន្តែ ការផ្ទេរកម្មសិទ្ធិត្រូវតែកត់ត្រានៅក្នុងបញ្ជីរបស់ភាគីខ្ចីប្រាក់ ឬភាគីលក់មូលបត្រ និងកត់ត្រាផងដែរនៅក្នុងបញ្ជីរបស់ភាគីឱ្យខ្ចី ឬភាគីទិញមូលបត្រ។ លើសពីនេះ ការសន្យាថាទិញមកវិញ ឬលក់ទៅវិញ នូវមូលបត្រត្រូវតែកត់ត្រាក្នុងខ្ទង់ក្រៅតារាងតុល្យការ តាមថ្លៃទិញ និងលក់វិញដែលបានព្រមព្រៀង។

ក្នុងនាមជាអ្នកថែរក្សាមូលបត្រឱ្យភាគីឱ្យខ្ចីប្រាក់ ភាគីខ្ចីប្រាក់ត្រូវបានហាមឃាត់មិនឱ្យលក់មូលបត្រនោះម្តងទៀត ដោយគ្មានការព្រមព្រៀងជាមុនជាមួយភាគីឱ្យខ្ចីប្រាក់ ក្នុងការជំនួសមូលបត្រនោះឡើយ។ ក្នុងអំឡុងពេលនៃប្រតិបត្តិការទទួលទិញវិញ ភាគីឱ្យខ្ចីប្រាក់អាចទាមទារឱ្យប្រគល់មូលបត្រនៅពេលណាក៏បាន ដោយជូនដំណឹងអំពីការទាមទារនោះ និងផ្តល់បញ្ជាច្បាស់លាស់អំពីគណនីដែលមូលបត្រនោះត្រូវផ្ទេរចូល។

## ប្រការ៧ : ការមិនទូទាត់ ការមិនប្រគល់ ការប្រគល់ទល់នឹងការទូទាត់ ការពិន័យតាមកិច្ចសន្យា

ភាគីទាំងពីរអាចព្រមព្រៀងគ្នាប្រើប្រាស់សេវាប្រគល់ទល់នឹងការទូទាត់ នៅទីកន្លែង និងនៅពេលណាដែលមានសេវានោះ ដើម្បីការពារហានិភ័យនៃការប្រគល់ឬការទូទាត់។

រាល់ការមិនទូទាត់ ឬមិនប្រគល់មូលបត្រឱ្យទាន់ពេល និងអនុលោមតាមលក្ខខណ្ឌដែលបានព្រមព្រៀងពីមុន ឬសេចក្តីជូនដំណឹងសុំឱ្យប្រគល់ ត្រូវបានចាត់ទុកថាជាហេតុការណ៍នៃការខកខាន។ ហេតុការណ៍នៃការខកខានណាមួយនឹងនាំទៅដល់ការបញ្ចប់មុនកាលកំណត់នូវរាល់ប្រតិបត្តិការទទួលទិញវិញដែលស្ថិតក្រោមកិច្ចសន្យាមេ ហើយនឹងនាំដល់ការវាយតម្លៃឡើងវិញនូវប្រតិបត្តិការទាំងអស់នៅថ្ងៃដែលខកខាន ដើម្បីកំណត់ចំនួនសមតុល្យសុទ្ធចុងក្រោយ ដែលត្រូវទូទាត់តាមមធ្យោបាយសមស្របណាមួយដែលអាចធ្វើទៅបាន រួមទាំងមធ្យោបាយទាមទារបំណុលមុនពេលដំណើរការក្ស័យធននៅតុលាការ។

ក៏ប៉ុន្តែ បើការមិនទូទាត់ ឬការមិនប្រគល់មូលបត្រកើតឡើងពីកំហុស ឬការភ័ន្តច្រឡំណាមួយ ភាគីទាំងពីរត្រូវធ្វើការស្រាវជ្រាវជាបន្ទាន់ ដើម្បីរកមូលហេតុនៃការខកខាននោះ និងដោះស្រាយបញ្ហា

បញ្ហាដោយធ្វើការទូទាត់ ឬការប្រគល់ភ្នាម។ ភាគីដើមហេតុនៃការខកខានត្រូវជូនដំណឹងជាបន្ទាន់ទៅភាគីម្ខាងទៀត បញ្ជាក់អំពីមូលហេតុនៃការខកខាន និងផ្តល់ព័ត៌មានអំពីថ្ងៃប្រសិទ្ធភាពនៃការទូទាត់ ឬការប្រគល់មូលបត្រ។

នៅពេលដែលការខកខានដែលបណ្តាលមកពីបញ្ហាប្រតិបត្តិការ បង្កឱ្យមានការយឺតយ៉ាវ និងការខាតបង់ខាងហិរញ្ញវត្ថុជាបន្តបន្ទាប់ ឬថ្លៃឱកាស ភាគីទាំងពីរត្រូវប្រឹងប្រែងដោះស្រាយបញ្ហា និងព្រមព្រៀងគ្នាលើការពិន័យសមស្រប សំដៅទូទាត់សងការខូចខាតដែលកើតឡើងចំពោះភាគីណាមួយ។

ភាគីទាំងពីរអាចគិតទុកមុននូវការពិន័យដែលត្រូវសងគ្នាទៅវិញទៅមកនៅក្នុងកិច្ចសន្យាបំពេញបន្ថែម ក្នុងករណីការខកខានបណ្តាលមកពីបញ្ហាប្រតិបត្តិការ ដោយមិនគិតដល់បញ្ហាអសាធនភាព ឬសាច់ប្រាក់ងាយស្រួល ដែលភាគីណាមួយជួបប្រទះ។

**ប្រការ៨ :ការគាមជានហានិភ័យឥណទាន ឬ ហានិភ័យគូភាគី ម៉ាជីន(Margins) ហ៊ែរខាត់ (Haircuts) ខាសម៉ាជីន (Cash Margins) ម៉ាជីនខល (Margin Calls)**

ដោយមូលបត្រជាកម្មវត្ថុនៃហានិភ័យថ្លៃ តម្លៃនៃមូលបត្រដែលបានលក់អាចនឹងប្រែប្រួលក្នុងអំឡុងពេលធ្វើប្រតិបត្តិការទទួលទិញវិញ ដែលបណ្តាលឱ្យមានការប្រែប្រួលនូវស្ថានភាពហានិភ័យឥណទាន ឬហានិភ័យគូភាគី។

